**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Mar-2011, 10:35
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# អញ្ញត្រកម្មរួមបញ្ចូលគ្នា

---

**ដាក់ដោយ:**

**សហមេធាវីរបស់លោក នួន ជា**

សុន អរុណ
Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
ព្រំ ផល្លា
Göran SLUITER
Annebrecht VOSSENBERG

**ផ្ញើជូន:**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីការពារក្ដីទាំងអស់**

## I. សេចក្ដីផ្ដើម

1. អនុលោមតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") និងយោងតាមអនុស្សរណៈជាច្រើន ដែលអង្គជំនុំជម្រះបានផ្ញើទៅកាន់ភាគី[1] ក្រុមមេធាវីការពារក្ដីជនជាប់ចោទ នួន ជា ("សហមេធាវី") សូមដាក់ជូនអញ្ញត្រកម្មរួមបញ្ចូលគ្នានេះ[2]។

2. នៅមុនថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ សហមេធាវីបានដាក់ជូនអញ្ញត្រកម្មចំនួនបីដាច់ដោយឡែកពីគ្នា ដោយអញ្ញត្រកម្មនីមួយៗទាក់ទងនឹងចំណុចនីមួយៗនៃចំណុចសម្រាប់ប្ដឹងអញ្ញត្រកម្មក្នុងវិធាន៨៩(១)៖ (i) "អញ្ញត្រកម្មពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង"[3] ដាក់ជូនដោយអនុលោមតាម វិធាន៨៩(១)(ក) (ii) "អញ្ញត្រកម្មពាក់ព័ន្ធនឹងបញ្ហាតម្រូវឲ្យរំលត់បណ្ដឹងអាជ្ញា ដោយសារពុំមានការស៊ើបអង្កេតដោយយុត្តិធម៌"[4] ដាក់ជូនដោយអនុលោមតាមវិធាន៨៩(១)(ខ) និង(iii) "អញ្ញត្រកម្មពាក់ព័ន្ធនឹងនីត្យានុកូលភាពវិធានផ្ទៃក្នុង និងប្រសិទ្ធិភាពនៃដីការបស់អង្គជំនុំជម្រះសាលាដំបូងចេញថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១"[5] ដាក់ជូនដោយអនុលោមតាម វិធាន៨៩(១)(គ)។ តាមការណែនាំ អញ្ញត្រកម្មលើបញ្ហាផ្សេងៗគ្នាទាំងនេះត្រូវច្របាច់បញ្ចូលគ្នា ដើម្បីឲ្យអង្គជំនុំជម្រះធ្វើការពិចារណាមុនពេលមានសវនាការបឋម។

---

1 *សូមមើល ជាឧទាហរណ៍* ឯកសារលេខ **E-51** អនុស្សរណៈរបស់លោកស្រី Susan Lamb ផ្ញើជូនរាល់ភាគីនៅក្នុងសំណុំរឿងក្ដី០០២ ពាក់ព័ន្ធនឹង "វិសោធនកម្មលើនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ការដាក់ជូនករណីអញ្ញត្រកម្ម និងការបញ្ជាក់អំពីកាលបរិច្ឆេទផុតកំណត់របស់ការឆ្លើយតបដែលបានថែង" ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ERN 00644105-00644106 ("អនុស្សារណៈស្ដីពីករណីអញ្ញត្រកម្ម")។

2 *កំណត់សម្គាល់* នួន ជា ត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ចោទប្រកាន់ជាផ្លូវការ នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០។ រយៈពេលបួនខែក្រោយមក អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានបញ្ជាក់ថាមានបណ្ដឹងជំទាស់នឹងដីកាដំណោះស្រាយ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាស្ថាពរ។ អង្គជំនុំជម្រះនេះ បានទទួលយកសំណុំរឿងក្ដីនេះជាផ្លូវការ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១។ *សូមមើល* ឯកសារលេខ **E-9** "ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ" នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ERN 00635754-00635759 ("ដីកាបង្គាប់ឲ្យរៀបចំ")។

3 ឯកសារលេខ **E-36** "ករណីអញ្ញត្រកម្មពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រសាលាដំបូង" ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ERN 00642561-00642576 ("អញ្ញត្រកម្មលើយុត្តាធិការ")។

4 "ករណីអញ្ញត្រកម្មពាក់ព័ន្ធនឹងបញ្ហាតម្រូវឲ្យរំលត់បណ្ដឹងអាជ្ញា - ដោយមិនមានការស៊ើបអង្កេតដោយយុត្តិធម៌" ("អញ្ញត្រកម្មលើសវនាការដោយយុត្តិធម៌")។ *កំណត់សម្គាល់* ឯកសារនេះត្រូវបានដាក់ជូនជាភាសាអង់គ្លេស កាលពីថ្ងៃ ច័ន្ទ ទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ នៅមិនបានដាក់បញ្ចូលទៅក្នុងសំណុំរឿងក្ដី និងមិនទាន់មានលេខឯកសារផ្លូវការនៅឡើយ។

5 ឯកសារលេខ **E-42** "ករណីអញ្ញត្រកម្មពាក់ព័ន្ធនឹងនីត្យានុកូលភាពវិធានផ្ទៃក្នុង និងប្រសិទ្ធិភាពនៃដីការបស់អង្គជំនុំជម្រះសាលាដំបូង ចេញកាលពីថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១" ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១ ERN 00643756-00643767 ("អញ្ញត្រកម្មលើវិធានផ្ទៃក្នុង")។

3. ដោយមានសំអាងហេតុដូចបានរៀបរាប់នៅទីនេះ សហមេធាវីសូមស្នើថា អញ្ញត្រកម្មនីមួយៗដែលមេធាវីបានដាក់ជូន គឺអាចទទួលយកបាន ហើយចំពោះអង្គសេចក្តី៖ (i) ការពន្យារអាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មនានាដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ក៏ដូចជា សវនាការរបស់ នួន ជា ដើម្បីជំនុំជម្រះលើបទចោទពីការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ (តទៅនេះហៅថា "ឧក្រិដ្ឋកម្មសង្គ្រាម") តាមរយៈទម្រង់នៃការទទួលខុសត្រូវផ្សេងៗគ្នា ដែលត្រូវបានទទួលស្គាល់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[6] នឹងរំលោភបំពានលើគោលការណ៍នីត្យានុកូលភាពក្នុងលក្ខណៈចង្អៀតរបស់កម្ពុជា (ii) ការស៊ើបអង្កេតរបស់តុលាការដែលមានវិការៈជាមូលដ្ឋាន និងមិនយុត្តិធម៌យ៉ាងជាក់ច្បាស់ លើសំណុំរឿងក្តី០០២ នាំឲ្យមានវិការៈជាសត្យានុម័តជាច្រើន ដោយវិការៈនីមួយៗ និងលើសពីនេះទៀត (*fortiori*) នៅពេលពិចារណាលើវិការៈទាំងអស់ជារួម បណ្តាលឲ្យមានព្យសនកម្មដែលមិនអាចជួសជុលបានចំពោះសិទ្ធិរបស់ នួន ជា ទាំងក្រោមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិជាធរមាន និង (iii) ដោយសារការអនុម័តលើវិធានផ្ទៃក្នុងពីដើមដំបូង និងវិសោធនកម្មក្រោយៗមកទៀតទៅលើវិធាននៅឯ "កិច្ចប្រជុំពេញអង្គ" របស់ អ.វ.ត.ក ផ្ទុយនឹងរដ្ឋធម្មនុញ្ញ និង*លើសពីសមត្ថភាព(ultra vires)* ហើយការបន្តអនុវត្តវិធានជាក់លាក់មួយចំនួន ជាពិសេសវិធានទាំងឡាយដែលគ្រប់គ្រងលើការជំនុំជម្រះ និងដំណើរការនីតិវិធីប្តឹងឧទ្ធរណ៍[7] ក៏ដូចជាការអនុវត្តដីការបស់អង្គជំនុំជម្រះ"បង្គាប់ឲ្យភាគីដាក់នូវសម្ភារៈដើម្បីរៀបចំសវនាការ" ("ដីកាបង្គាប់ឲ្យរៀបចំ")[8] នឹងរំលោភដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបាននូវសច្ចភាពផ្លូវច្បាប់ និងការជំនុំជម្រះក្តីដោយយុត្តិធម៌។

## II. អង្គហេតុដែលពាក់ព័ន្ធ

### ក. ប្រព័ន្ធយុត្តិធម៌ដែលមានបញ្ហាជាមូលដ្ឋាន

---

[6] *សូមមើល* ឯកសារលេខ **D-427** "ដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១ ERN 00604508-00605246 កថាខណ្ឌ១២៩៩។ *កំណត់សម្គាល់* ដីកាដំណោះស្រាយចូលជាស្ថាពរនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ *សូមមើល* ឯកសារលេខ **D-427/2/12** "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ របស់ នួន ជា និង អៀង ធីរិទ្ធ" ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ERN 00634916-00634922 ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដីកាដំណោះស្រាយ")។

[7] ផ្នែក ង នៃវិធានផ្ទៃក្នុង (វិធាន៧៩-១០៣) គ្របដណ្តប់ដោយសង្ខេប "កិច្ចដំណើរការនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" និងផ្នែក ច (វិធាន១០៤-១១៤) ហាក់បីដូចជាចែងពី "បណ្តឹងឧទ្ធរណ៍ចេញពីអង្គជំនុំជម្រះសាលាដំបូង"។

[8] ដីកាបង្គាប់ឲ្យរៀបចំ កថាខណ្ឌ ១-៩។

4. ចាប់ពីកិច្ចដំណើរការនីតិវិធីតុលាការប្រឆាំងនឹង នួន ជា បានចាប់ផ្តើមមក សហមេធាវី និងអ្នកសង្កេតការណ៍ឯករាជ្យជាច្រើនរូបទៀត បានបង្ហាញនូវការព្រួយបារម្ភជាច្រើន ពាក់ព័ន្ធនឹងលទ្ធភាព និង/ឬឆន្ទៈរបស់តុលាការកម្ពុជាក្នុងការបំពេញការងារដោយឯករាជ្យពីស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល")[9]។ ការព្រួយបារម្ភនេះគឺផ្អែកលើសាវតារនៃការស្តាប់បង្គាប់របស់តុលាការនៅក្នុងព្រះរាជាណាចក្រនេះ[10] ក៏ដូចជាការស្តែងឲ្យឃើញដោយចំហរ និងជាប្រចាំនូវអរិភាពរបស់មន្ត្រីរាជរដ្ឋាភិបាលចំពោះកិច្ចការរបស់តុលាការមួយនេះ[11]។ ពាក់ព័ន្ធនឹងលទ្ធភាព និងឆន្ទៈរបស់តុលាការកម្ពុជា គ្មានអ្វីប្រែប្រួលគួរឲ្យកត់សំគាល់ចំពោះការទាយទុកពីដំបូងដែលថា ការជំនុំជម្រះលើ "រឿងក្តីបទចោទប្រកាន់ពាក់ព័ន្ធនឹងនយោបាយ" ដូចជារឿងក្តីក្នុងដៃយើងនេះ ការកាត់សេចក្តីយ៉ាងច្រើនអាចទទួលត្រឹមតែយុត្តិធម៌ក្នុងកម្រិត"ប្រហាក់ប្រហែល"មួយតែប៉ុណ្ណោះ[12]។ ជាការពិត រឿងក្តីពាក់ព័ន្ធ

---

[9] *សូមមើល ឧទាហរណ៍,* ឯកសារលេខ **C-11/21**, 'បណ្តឹងជំទាស់លើដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន' — 

[9] *សូមមើល ឧទាហរណ៍,* ឯកសារលេខ **C-11/21**, 'បណ្តឹងជិតចិត្តជាបន្ទាន់ចំពោះចៅក្រម ន័យ ថុល', ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨, ERN 00159595–00159618 ('បណ្តឹងជិតចិត្តចៅក្រម ន័យ ថុល'), កថាខណ្ឌ២៨-៤៨។

[10] *សូមមើល ឧទាហរណ៍,* សេចក្តីថ្លែងការណ៍របស់លោក ឡៅ ម៉ុងហៃ (Lao Mong Hay) មានចំណងជើងថា៖ ស្ថាប័នវិធាននៃច្បាប់ និងសិទ្ធិមនុស្សនៅកម្ពុជា, ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦, ទំព័រ៨។

[11] *សូមមើល* កថាខណ្ឌ៦-១២, *យោងខាងក្រោម*។

[12] *សូមមើល* Steven Heder គម្រោងយុត្តិធម៌សង្គមសេរី "អង្គជំនុំជម្រះវិសាមញ្ញ, បុគ្គលដែលត្រូវយកទៅជំនុំជម្រះ៖ មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត" ('The Extraordinary Chambers, Players: The Senior Leaders and Those Most Responsible') ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦ ទំព័រ៥៣ ("បញ្ហាដំបូងគឺថា តុលាការនេះនឹងប្រហែលជាដំណើរការជម្រះក្តីប្រកបដោយត្រឹមកម្រិតអប្បរមាប៉ុណ្ណោះ ដោយសារមានការជ្រៀតជ្រែតយ៉ាងខ្លាំងក្លាពីអ្នកនយោបាយ រួមមានមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា [...]។ ខ្ញុំនិយាយថា "ប្រហែល" ដោយផ្អែកលើបទពិសោធន៍ពីអតីតកាលនៃអំណាចយុត្តាធិការនៅកម្ពុជា ដែលមានភាពលម្អៀង និងឯករាជភាពដែលថា រឿងក្តីដែលត្រូវបានចោទប្រកាន់រឿងនយោបាយមិនអាចយកទៅជំនុំជម្រះប្រកបដោយយុត្តិធម៌បានទេ។ មានឧទាហរណ៍តែមួយគត់កាលពីទសវត្សរ៍មុនដែលតុលាការមួយដែលបានជំនុំជម្រះក្តីលើរឿងនយោបាយដែលមានលក្ខណៈរសើបដោយភាពត្រឹមត្រូវគឺថា ពឹងផ្អែកលើភ័ស្តុតាងទាំងស្រុង ហើយសម្រេចសេចក្តីផ្អែកលើភ័ស្តុតាងតែប៉ុណ្ណោះ")។ *សូមមើលផងដែរ* របាយការណ៍របស់អគ្គលេខាធិការស្តីពីសាលាក្តីខ្មែរក្រហម ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ឯកសារលេខ A/57/769 កថាខណ្ឌ២៨-២៩ ("តាមរយៈសេចក្តីសន្និដ្ឋានរបស់មហាសន្និបាតនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ 57/225 ដែលថា នៅមានបញ្ហាទាក់ទិននឹងនីតិរដ្ឋ និងដំណើរការរបស់អំណាចយុត្តាធិការនៅប្រទេសកម្ពុជា ដោយសារការជ្រៀតជ្រែករបស់អំណាចនីតិប្រតិបត្តិទៅក្នុងឯករាជភាពរបស់អំណាចយុត្តាធិការនោះ ខ្ញុំសូមស្នើថា សេចក្តីព្រាងនៃកិច្ចព្រមព្រៀងសម្រាប់ [sic] អង្គជំនុំជម្រះវិសាមញ្ញទាំងពីរថ្នាក់នេះ គួរតែមានចៅក្រមបរទេសភាគច្រើនជាង")។ ការយល់ឃើញបែបនេះក៏ត្រូវបានគាំទ្របន្ថែមទៀតដោយ Louise Arbour ជាឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នៅឯសន្និសិទសារព័ត៌មានមួយដែលបានរៀបចំនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៦។ អ្នកស្រីបានមានប្រសាសន៍ថា "កង្វះការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈ ការធានាមិនពេញលេញចំពោះឯករាជភាព និងកង្វះ ឬទស្សនៈដែលខ្វះសុច្ចរិតភាព គឺជាចំណុចសំខាន់ដែលត្រូវយកមកដោះស្រាយ ទាំងផ្នែកច្បាប់ផង និងទាំងផ្នែកវប្បធម៌ផង"។ លិខិតចំហរបស់គណៈកម្មការសិទ្ធិមនុស្សប្រចាំទ្វីបអាស៊ី ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ

នឹងនយោបាយខ្លាំង[13]ជាច្រើនបានបង្ហាញថា ប្រព័ន្ធតុលាការកម្ពុជានៅតែ (ទោះបីជាមានភាពស្ទាក់ស្ទើរក្តី) បម្រើដល់និន្នាការនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដដែល។

## ខ. ការជ្រៀតជ្រែកនយោបាយនៅក្នុងកិច្ចការរបស់តុលាការ

### *១. អំពើពុករលួយនៅ អ.វ.ត.ក*

5. ដោយមានការលើកឡើងថា ការចោទប្រកាន់ពីអំពើពុករលួយនៅតុលាការអាចធ្វើឲ្យប៉ះពាល់ដល់ភាពស្របច្បាប់របស់តុលាការ និងការអះអាងថា ការរៀបចំឲ្យមានអំពើពុករលួយជាស្ថាប័ន គឺជាសញ្ញាណនៃបញ្ហាដ៏ធំមួយនៃការជ្រៀតជ្រែករបស់រដ្ឋាភិបាល សហមេធាវីបានស្វែងរកដើម្បីបង្ហាញការចូលរួមរបស់ រ.រ.ក តាមរយៈការបង្ហាញពីនីតិវិធីនៅតុលាការជាតិ និងនៅ អ.វ.ត.ក[14]។ មកទល់ពេលបច្ចុប្បន្ននេះ បញ្ហានេះនៅមិនទាន់ត្រូវបានដោះស្រាយឲ្យបានជ្រះស្រឡះនៅឡើយទេ ហើយ "បរិយាកាសនៃអំពើពុករលួយ"[15]នៅតែបន្តនៅជាមួយតុលាការនេះដដែល[16]។ ក្រៅពីការដាក់ចេញនូវដំណោះស្រាយឲ្យតែឃើញថាមានមួយចំនួននោះ[17] គ្មានសញ្ញាណបង្ហាញឲ្យឃើញថា រ.រ.ក អង្គការសហប្រជាជាតិ ប្រទេសផ្តល់ជំនួយ ឬមន្ត្រីតុលាការបម្រើការងារនៅតុលាការនេះផ្ទាល់តែម្តង មានចេតនា និង/ឬ លទ្ធភាពចាត់វិធានការចាំបាច់ ដើម្បីលុបបំបាត់បរិយាកាសបែបនេះឡើយ។ នៅក្នុងកាលៈទេសៈណាក៏ដោយ ការខិតខំប្រឹងប្រែងដោះស្រាយដ៏តិចតួចបែបនេះមិនមានប្រយោជន៍អ្វីឡើយ ដោយសារតែ

---

"ប្រទេសកម្ពុជា៖ តុលាការខ្មែរក្រហម: សំណើសុំឲ្យមានការលើតម្កើងឯករាជភាពរបស់អំណាចយុត្តាធិការនៅប្រទេសកម្ពុជា" ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦។

[13] *សូមមើល ឧទាហរណ៍,* របាយការណ៍របស់ អង្គការឃ្លាំមើលសិទ្ធិមនុស្ស, មានចំណងចើងថា៖ 'Cambodia: End Assault on Opposition, Critics', ចេញផ្សាយថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ មាននៅ៖ http://www.hrw.org/en/news/2009/07/14/cambodia-end-assault-opposition-critics ។

[14] *សូមមើល* ឯកសារលេខ **D-158**, 'សំណើលើកទី១១ ស្នើសុំបើកកិច្ចស៊ើបសួរ', ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, ERN 00294816–00294830 ('សំណើលើកទី១១'), កថាខណ្ឌ៤-១២។ ឯកសារ **D-158/5/1/1**, 'បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទី១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ', ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩, ERN 00323238–00323255 ('បណ្តឹងឧទ្ធរណ៍ទាក់ទងនឹងរឿងពុករលួយ'), កថាខណ្ឌ៥-៦។ *កំណត់សម្គាល់ពិសេស* នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៨, សមាជិកបីរូបរបស់ក្រុមមេធាវីការពារក្តី នួន ជា បានដាក់ពាក្យបណ្តឹងទៅតុលាការក្រុងភ្នំពេញ ចោទប្រកាន់ពីសកម្មភាពពុករលួយនៅ អ.វ.ត.ក។ ដោយត្រូវបានច្រានចោលនៅក្នុងសាលាដំបូង ករណីនោះត្រូវប្តឹងឧទ្ធរណ៍ទៅការិយាល័យអគ្គព្រះរាជអាជ្ញា នៃសាលាឧទ្ធរណ៍ អស់រយៈពេលជិតបីឆ្នាំហើយ។

[15] អត្ថបទរបស់ Ian Andrews, *l'Osservatore Romano*, មានចំណងជើងថា 'Swiss Guard implicated in Vatican kick-back scandal', ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧៤។

[16] *សូមមើល* សំណើលើកទី១១, កថាខណ្ឌ១៨-១៩។

[17] *សូមមើល ឧទាហរណ៍,* ការបង្កើតការិយាល័យអ្នកផ្តល់ប្រឹក្សាឯករាជ្យ។

ប្រព័ន្ធដែលមានការរីករាលដាលដែលរៀបចំ និងផ្តួចផ្តើមដោយលោក ស៊ាន វិសុទ្ធ រួមជាមួយបុគ្គលិកក្រោមបង្គាប់របស់គាត់ក្នុងរយៈពេលបួនឆ្នាំនោះនៅតែបន្តមានរហូតមកទល់ពេលបច្ចុប្បន្ន ដែលធ្វើឱ្យមានការបំពេញហោប៉ៅឯកជនរបស់មន្ត្រីរដ្ឋាភិបាល និងអាចធ្វើឱ្យមានការប៉ះពាល់ដល់សុចរិតភាពរបស់បុគ្គលទាំងឡាយដែលជាប់ពាក់ព័ន្ធផងដែរ។ សរុបមក ចំពោះសហាមេធាវី ក៏ដូចជាអ្នកផ្តល់អត្ថាធិប្បាយឯករាជ្យជាច្រើនរូប អ.វ.ត.ក នៅតែជាស្ថាប័នដែលមានកេរ្តិ៍ឈ្មោះមិនល្អដដែល។ ក្នុងន័យនេះ ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាត្រូវបានចាត់ទុកជាប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធដែលពុករលួយខ្លាំងជាងគេបំផុតនៅលើពិភពលោក[18] ហើយ អ.វ.ត.ក គឺជាផ្នែកមួយនៃប្រព័ន្ធនេះ[19] ដូច្នេះក៏មានការពុករលួយដែរ។

*២. ការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាល ក្នុងសំណុំរឿងក្តី ០០២*

6. ការព្រួយបារម្ភរបស់សហាមេធាវីជាទូទៅពាក់ព័ន្ធនឹងការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាល ទីបំផុតបានប្រែប្រួលពីការប៉ាន់ស្មានទៅជាភាពជាក់ស្តែង។ ដោយសារវិធីសាស្ត្រមិនច្បាស់លាស់របស់អង្គការសហប្រជាជាតិចំពោះអំពើពុករលួយនេះ រដ្ឋាភិបាលបានបង្ហាញឱ្យឃើញថាការវាយប្រហាររបស់រដ្ឋាភិបាលមកលើប្រព័ន្ធយុត្តិធម៌នៅតុលាការ អាចធ្វើក្នុងទម្រង់មួយបើកចំហរ និងជាក់ច្បាស់ខ្លាំងជាងមុន[20]៖

ក. នៅខែកក្កដា ឆ្នាំ២០០៩ សម្តេចចៅហ្វាវាំង គង់ សំអុល រដ្ឋមន្ត្រីព្រះបរមរាជវាំង បានចូលជ្រៀតជ្រែកយ៉ាងសកម្មចំពោះការព្យាយាមស្នើសុំស្តាប់ចម្លើយព្រះបាទ នរោត្តម សីហនុ ដែលបានបង្អាក់ភាគីនានានៅ អ.វ.ត.ក មិនឱ្យមានឱកាសស្តាប់សក្ខីកម្មដ៏មានសារៈសំខាន់របស់ទ្រង់[21]។ លើសពីនេះទៀត សហាចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ដែលខ្លួនគាត់ផ្ទាល់

---

[18] *កំណត់សម្គាល់ពិសេស*រឿងនេះសំអាងលើរបាយការណ៍ជាច្រើនរបស់អ្នកយកការសម្ងាត់។

[19] *សូមមើល ឧទាហរណ៍*, អង្គការតម្លាភាពអន្តរជាតិ, របាយការណ៍អំពីពុករលួយសកលលោក ឆ្នាំ២០០៨ (ចាត់ថ្នាក់ប្រទេសកម្ពុជាជាប្រទេសពុករលួយបំផុតទីប្រាំបីនៅក្នុងពិភពលោក) (មាននៅ http://www.transparency.org , បើកមើលនៅ ខែកញ្ញា ឆ្នាំ២០០៨)។

[20] Sebastian Strangio "អំពើពុករលួយអាចធ្វើឱ្យអន្តរាយដល់យុត្តិធម៌នៅសាលាក្តីខ្មែរក្រហម" ('Corruption may undermine Khmer Rouge justice') ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ (អាចរកបាននៅគេហទំព័រ៖ http://www.eurekastreet.com.au/article.aspx?aeid=11895) (ដកស្រង់សំដីរបស់ Yash Ghai អតីតប្រេសិតរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាដែលមានប្រសាសន៍ថា៖ "ភាពទន់ខ្សោយ និងអំពើពុករលួយនៅក្នុងប្រព័ន្ធច្បាប់ជាតិបានជះឥទ្ធិពលដល់ អ.វ.ត.ក ផ្ទុយពីការប្រើឥទ្ធិពលរបស់ អ.វ.ត.ក ទៅ [...] [ប្រព័ន្ធ]ជាតិវិញ")។

[21] *សូមមើល* ឯកសារ **D-254**, 'សំណើរសុំបំពេញកិច្ចស៊ើបសួរ', ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, ERN 00410838–00410848 ('សំណើរសុំតាមវិធាន៣៥ ឆ្នាំ២០០៩'), កថាខណ្ឌ៥។

ជាមន្ត្រីជាន់ខ្ពស់មួយរូបរបស់ រ.រ.ក បានបដិសេធមិនព្រមចុះហត្ថលេខាលើលិខិតនានារបស់ ក.ស.ច.ស ស្នើសុំស្តាប់ចម្លើយអតីតព្រះមហាក្សត្រ [22]។

ខ. ក្នុងខែកញ្ញា ឆ្នាំ២០០៩ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានលើកឡើង ជាសាធារណៈថា គាត់ជំទាស់នឹងការស្តាប់ចម្លើយរបស់មន្ត្រីជាន់ខ្ពស់ រ.រ.ក ទាំងប្រាំមួយរូប (“សាក្សីខាងក្នុងប្រាំមួយរូប”) ជាសាក្សីនៅក្នុងសំណុំរឿងក្តី០០២[23]។ ឯកឧត្តម ខៀវ កាញារីទ្ធ អ្នកនាំពាក្យរាជរដ្ឋាភិបាល បានថ្លែងជាសាធារណៈ នៅក្នុងខែតុលា ឆ្នាំ២០០៩ គាំទ្រដល់ការយល់ ឃើញរបស់នាយករដ្ឋមន្ត្រី ព្រមទាំងមានហេតុផលសំខាន់មួយទៀតដែលធ្វើឲ្យជឿថា ដោយ ផ្ទាល់ ឬប្រយោល ជំហររបស់រដ្ឋាភិបាលបណ្តាលឲ្យសាក្សីខាងក្នុងទាំងប្រាំមួយរូបនោះមិនមក បង្ហាញខ្លួន[24]។ “ប្រភពព័ត៌មានពីតុលាការ” ដែលមិនបញ្ជាក់ប្រភព បញ្ជាក់ចំពោះការសង្ស័យនេះ [25]។

7. នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ សហមេធាវីបានដាក់សំណើជាផ្លូវការអំពីបញ្ហាទាំងនេះជូនទៅ ក.ស.ច.ស និងបានស្នើឲ្យសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) ធ្វើការស៊ើបអង្កេតនូវលទ្ធភាពនៃការជ្រៀតជ្រែកដោយចេតនាទៅក្នុងកិច្ចការរដ្ឋបាលតុលាការរបស់មន្ត្រី រ.រ.ក ព្រមទាំងចាត់វិធានសមស្របតាមវិធាន៣៥[26]។ ប៉ុន្តែ ក.ស.ច.ស មិនបានចាត់វិធានការដោះស្រាយឡើយ[27]។ នៅក្នុង បណ្តឹង

[22] *សូមមើល* សំណុំរឿងលេខ០០២/១៧-០៦-២០១០-អ.វ.ត.ក-អ.ប.ជ (០៩), ឯកសារលេខ 1, ‘បណ្តឹងជំទាស់ចិត្តលោកចៅក្រម យូ ប៊ុនឡេង’, ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០, ERN 00535168–00515181 (‘បណ្តឹងជំទាស់ចិត្តចៅក្រម យូ ប៊ុនឡេង’), កថាខណ្ឌ៥។

[23] *សូមមើល* សំណើរសុំតាមវិធាន៣៥ ឆ្នាំ២០០៩, កថាខណ្ឌ៦។

[24] *សូមមើល* សំណើរសុំតាមវិធាន៣៥ ឆ្នាំ២០០៩, កថាខណ្ឌ៧។.

[25] *សូមមើល* សំណើរសុំតាមវិធាន៣៥ ឆ្នាំ២០០៩, កថាខណ្ឌ៤។ *សូមមើលផងដែរ* ឯកសារលេខ **D-314/2/9**, ‘សារណាបណ្តឹងឧទ្ធរណ៍បន្ថែមប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីសំណើរបស់ នួន ជា និង អៀង សារី សុំឲ្យកោះហៅសាក្សី’, ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០, ERN 0539820–0539827, កថាខណ្ឌ១៣-១៦។

[26] ឯកសារ **D-254**, ‘សំណើសុំបំពេញកិច្ចស៊ើបសួរ’ ’, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩, ERN 00410838–00410848 (“សំណើឆ្នាំ២០០៩”)។ *សូមមើលផងដែរ* ឯកសារ **D-254/2**, “សេចក្តីបន្ថែមទៅលើសំណើលើកទី១ ស្នើសុំកិច្ចស៊ើបសួរ” ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១០, ERN 00410958–00410960។

[27] *សូមមើល* ឯកសារ **D-314**, “ដីកាសម្រេចលើសំណើកោះហៅសាក្សី ដែលដាក់ដោយក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី”, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០, ERN 00446652–00446658។ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០, អ.ប.ជ បានសម្រេចថា ក.ស.ច.ស មានការភាន់ច្រឡំផ្នែកផ្នែកច្បាប់ ក្នុងការច្រានចោលសំណើនោះ ដោយសំអាងលើការបកស្រាយដោយភាន់ច្រឡំនៃវិធាន៣៥។ *សូមមើល* ឯកសារ **D-314/2/7**, “សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី”, ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០, ERN 00527392–00527420។ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១០, ក.ស.ច.ស បានចេញដីកាថ្មីមួយ (ឯកសារ **D-314/3**, “ដីកាឆ្លើយតបចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើសុំ

ឧទ្ធរណ៍ ការមិនបានចាត់វិធានការបែបនេះពិតជាត្រូវបានថ្កោលទោសនៅក្នុងសេចក្តីសម្រេច មួយដាច់ដោយឡែក ("យោបល់ជំទាស់") របស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ[28] ដោយមិន ចាំបាច់ភ្ញាក់ផ្អើលទេ ចៅក្រមកម្ពុជាដែលជាសហការីរបស់ពួកគាត់នោះ បានប្រកាន់ខ្ជាប់ទៅនឹងមាគ៌ា នយោបាយរបស់រដ្ឋាភិបាល[29]។ យោងតាមវិធានក្នុងការបោះឆ្នោតនៅ អ.វ.ត.ក ការយល់ឃើញរបស់ ចៅក្រមកម្ពុជាមានអាទិភាពជាង ហើយចៅក្រមអន្តរជាតិ ដែលអាចថាចេញដីកាអនុលោមតាមវិធាន ៣៥នៃវិធានផ្ទៃក្នុងឲ្យស៊ើបអង្កេតពី ការចោទប្រកាន់ "ដ៏ធ្ងន់ធ្ងរ"[30] ត្រូវបានបដិសេធដោយប្រសិទ្ធិភាព។

8. ទោះបីជាយ៉ាងណាក៏ដោយ មតិយោបល់ជំទាស់របស់ចៅក្រមអន្តរជាតិ នៅតែស្តីបន្ទោសយ៉ាងខ្លាំង ចំពោះការប៉ុនប៉ង "មិនមានលក្ខណគួរឲ្យពេញចិត្ត" របស់ ក.ស.ច.ស ក្នុងការ "បង្វែរការទទួលខុសត្រូវ [របស់ខ្លួន] ទៅឲ្យអង្គបុរេជំនុំជម្រះ" [31]៖

> នៅពេលយើងពិនិត្យមើល [ឯកសារដាក់ជូនដោយសហមេធាវី] យើងយល់ឃើញថា *អង្គហេតុដែលបានដាក់ដោយសមហេតុផលបាននាំឲ្យយើងពិចារណាថា អង្គហេតុដែលបានលើកឡើងខាងលើ និងហេតុការណ៍ជាបន្តបន្ទាប់ បង្កើតជាហេតុផលជឿថា សមាជិកនៃរាជរដ្ឋាភិបាលម្នាក់ ឬច្រើន អាចជ្រៀតជ្រែកដោយចេតនាពិតប្រាកដលើសាក្សី ដែលអាចមកផ្តល់សក្ខីកម្មនៅចំពោះមុខ ស.ច.ស។* ការរកឃើញនេះនៅតែបង្ហាញឲ្យឃើញដោយមិនគិត ថាតើសាក្សីដែលត្រូវបានកោះហៅ អាចឬមិនអាចមានហេតុផលច្រើនជាងមួយដើម្បីមិនមកផ្តល់សក្ខីកម្ម។ អង្គហេតុសំខាន់ជាងនេះមួយនោះគឺ យោបល់របស់លោក ខៀវ

---

កោះហៅសាក្សីរបស់ក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី", ERN 00532792–00532794), ជាការឆ្លើយតបទៅនឹងសារណាជាលាយលក្ខណ៍អក្សរបន្ថែម ដែលត្រូវបានដាក់ដោយមេធាវីការពារក្តី នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០។ *សូមមើល* លេខ២៥ *យោងខាងលើ*។

[28] *សូមមើល* ឯកសារ **D-314/1/12**, "សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី", ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០, ERN 00600748–00600774 ('សាលដីកាលស្តីពីសាក្សី អ.ប.ជ'); ជាពិសេស, យោបល់របស់ចៅក្រម Catherine Marchi-Uhel និង Rowan Downing"។

[29] *សូមមើល ដូចជើងទំព័រខាងលើ* ជាពិសេសគឺ 'យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ន័យ ធុល, និង ហួត វុទ្ធី'។

[30] មតិជំទាស់ កថាខណ្ឌ៥ ("ដោយសារ ស.ច.ស ខកខានមិនបានបំពេញម្តងហើយម្តងទៀត យើងយល់ថា ដោយសារពិចារណាលើលក្ខណៈធ្ងន់ធ្ងរនៃការចោទប្រកាន់អំពីការចូលជ្រៀតជ្រែក អង្គបុរេជំនុំជម្រះត្រូវតែធ្វើអន្តរាគមន៍")។

[31] មតិជំទាស់ កថាខណ្ឌ៤។ *សូមមើលផងដែរដូចជើងទំព័រខាងលើ* កថាខណ្ឌ១១ ("នៅពេលចៅក្រមជឿថា ព័ត៌មាននៅចំពោះមុខខ្លួនមានហេតុផលជឿថា ការជ្រៀតជ្រែកដូចបានកំណត់នៅក្នុងវិធានផ្ទៃក្នុងបានកើតឡើង ការអនុវត្តឆន្ទានុសិទ្ធិរបស់តុលាការមានការថយចុះ")។

> កាញារីទ្ធ ដែលបានផ្សាយនៅក្នុងកាសែត *ភ្នំពេញប៉ុស្តិ៍* ថា "ជំហររបស់រដ្ឋាភិបាល គឺគាត់មិនគួរផ្តល់សក្ខីកម្មនោះទេ" នៅពេលនិយាយយោងដល់មន្ត្រីប្រាំមួយនាក់។ បរិបទដែលសេចក្តីថ្លែងការណ៍នេះបានលើកឡើង បាននាំឲ្យមានការជឿយ៉ាងខ្លាំងថា សេចក្តីថ្លែងការណ៍នេះអាចជាការជ្រៀតជ្រែក ឬឆ្លុះបញ្ចាំងអំពីកិច្ចប្រឹងប្រែងដទៃៗទៀត ក្នុងការរារាំងការស្តាប់សក្ខីកម្មរបស់មន្ត្រីទាំងប្រាំមួយរូបនេះ។ [...] យោបល់របស់ ខៀវ កាញារីទ្ធ ធ្វើឲ្យយើងជឿថា មានហេតុផលជឿថា គាត់ ឬបុគ្គលដែលគាត់ផ្តល់យោបល់ ដោយ ជំនួសមុខឲ្យនោះអាចប៉ុនប៉ងដោយចេតនាពិតប្រាកដនៅក្នុងការគម្រាមកំហែង ឬបំភិតបំភ័យមន្ត្រីទាំងប្រាំមួយរូប ឬបើមិនដូច្នោះទេ ជ្រៀតជ្រែកលើការសម្រេចចិត្តរបស់មន្ត្រីទាំងប្រាំមួយរូបនេះ ទាក់ទងនឹងការអញ្ជើញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឲ្យមកផ្តល់សក្ខីកម្ម[32]។

ជាក់ស្តែង ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានផ្តល់មតិយោបល់បែបនេះថា ក.ស.ច.ស ទោះបីជា "អង្គភាពស៊ើបសួររបស់ អ.វ.ត.ក"[33] ក៏ដោយ គឺមិនមែនជាអង្គភាពដែលមានអាជីពសមស្រប "ដើម្បីដឹកនាំកិច្ចស៊ើបអង្កេតទៅលើការចោទប្រកាន់ថាមានការជ្រៀតជ្រែកទាំងនេះ"[34] ឡើយ។

9. នៅទីបំផុត ទាំងព្រះវរបិតា និងសាក្សីខាងក្នុងទាំងប្រាំមួយរូប មិនបានផ្តល់សក្ខីកម្មដល់ ក.ស.ច.ស ឡើយ។

### *៣. ការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលនៅក្នុងសំណុំរឿងក្តី០០៣ និង០០៤*

10. អស់រយៈកាលជាងមួយទសវត្សរ៍ហើយ សម្តេច ហ៊ុន សែន បានបន្តប្រកាសថា "មានជនសង្ស័យតែប្រាំរូបប៉ុណ្ណោះ ដែលត្រូវរងការចោទប្រកាន់ដោយ [អ.វ.ត.ក] ដោយគាត់បានព្រមានជាច្រើនលើកច្រើនគ្រាថា អាចបណ្តាលឲ្យមានការប៉ះពាល់ដល់ការចរចារសន្តិភាពនៅក្នុងទសវត្សរ៍ឆ្នាំ៩០ និងបង្កឲ្យមានសង្គ្រាមស៊ីវិលថ្មីមួយទៀត"[35]។ មាគ៌ានយោបាយបើកចំហរជាសាធារណៈមួយនេះត្រូវបានមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលជាច្រើនរូប ក៏ដូចជា "មន្ត្រីតុលាការកម្ពុជាបម្រើការងារនៅអង្គជំនុំជម្រះ"

---

[32] មតិជំទាស់ កថាខណ្ឌ៦ (គូសបញ្ជាក់បន្ថែម)

[33] មតិជំទាស់ កថាខណ្ឌ៨។

[34] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៨។

[35] អត្ថបទរបស់ Douglas Gillison, មានចំណងជើងថា៖ 'សាលាក្តីខ្មែរក្រហមចាប់ផ្តើមស៊ើបអង្កេតជនសង្ស័យថ្មី ៥នាក់បន្ថែមទៀត', សារព័ត៌មាន *The Cambodia Daily*, ចេញផ្សាយថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ ទំព័រ២៦។

អនុវត្តតាមដោយចំហរ និងយ៉ាងខ្ជាប់ខ្ជួនផងដែរ[36]។ គួរឲ្យកត់សម្គាល់ផងដែរ លោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិ រួមជាមួយចៅក្រមជាតិដែលជាសមាជិកនៅអង្គបុរេជំនុំជម្រះនោះ បានជំទាស់ចំពោះការចាត់ឲ្យមានការស៊ើបសួរបន្ថែមទៅលើជនសង្ស័យដែលសហព្រះរាជអាជ្ញាអង្គការសហប្រជាជាតិបានស្នើឡើង ដោយផ្អែកលើមូលដ្ឋានដែលស្រដៀងទៅនឹងមូលហេតុនានាដែលរដ្ឋាភិបាលបានលើកឡើងជាប្រចាំ និងដោយចំហរ[37]។

11. នៅខែមិថុនា ឆ្នាំ២០១០ ចៅក្រម យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិបានបង្ហាញពីយកវិជ្ជាជីវៈរបស់គាត់ដើម្បីគាំទ្របុព្វហេតុរបស់រាជរដ្ឋាភិបាល។ បន្ទាប់ពីបានចុះហត្ថលេខាលើដីកាចាត់ឲ្យស៊ើបសួរជំនួស ដែលមានប្រសិទ្ធិភាពអាចឲ្យកិច្ចស៊ើបសួរនៅទីតាំងឧក្រិដ្ឋកម្មមួយចំនួន អាចចាប់ផ្តើមបាននោះ សហចៅក្រម យូ ប៊ុនឡេង បាន "លុបចោល" ហត្ថលេខាលើឯកសារទាំងនោះ ហើយបញ្ជូនឯកសារត្រលប់ទៅដៃសហការីអន្តរជាតិរបស់លោក គឺលោកចៅក្រម Lemonde វិញ[38]។ តាមរយៈការពន្យល់បកស្រាយ គាត់គ្រាន់តែបានផ្តល់យុត្តិកម្មដូចតទៅនេះ៖ "នៅពេលពិចារណាឲ្យបានស៊ីជម្រៅ និងដោយយកចិត្តទុកដាក់ទៅលើសំណើ ខ្ញុំយល់ថា នៅមិនទាន់ដល់ពេលត្រូវចាត់វិធានការនៅក្នុងសំណុំរឿងក្តី០០៣ និង០០៤ឡើយ"[39]។ នៅល្ងាចថ្ងៃដដែលនោះ លោក រាជ សម្បត្តិ ជាមន្ត្រីនាំពាក្យជាតិនៃអង្គជំនុំជម្រះ "បានដាក់ចេញនូវសេចក្តីថ្លែងការណ៍មួយ ជូនដំណឹងពីការមិនពាក់ព័ន្ធនឹងដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ចៅក្រម យូ ប៊ុនឡេង"[40]។ គួរឲ្យកត់សម្គាល់ផងដែរថា ដីកាចាត់ឲ្យស៊ើប

---

[36] អត្ថបទរបស់ Douglas Gillison, មានចំណងជើងថា៖ 'ចៅក្រមសាលាក្តីខ្មែរក្រហមមិនបានចុះហត្ថលេខាឲ្យមានការស៊ើបអង្កេតទេ', សារព័ត៌មាន *The Cambodia Daily*, ចេញផ្សាយថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០ ទំព័រ២៦។

[37] *សូមមើល* សំណុំរឿងលេខ ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ, 'ឧបសម្ព័ន្ធ I: ឯកសារកូសលុបសារធារណៈ – ការពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាអនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង', ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ២៨–៣៧ និង 'យោបល់ដោយឡែករបស់ចៅក្រម៖ ប្រាក់ គឹមសាន, ន័យ ថុល, និង ហួត វុទ្ធី'។

[38] អនុស្សារណៈផ្ទៃក្នុង ក.ស.ច.ស ពីចៅក្រម យូ ប៊ុនឡេង ទៅកាន់ ចៅក្រម Marcel Lemonde, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, កម្មវត្ថុ 'សំណុំរឿងលេខ ០០៣ និង ០០៤' (បកប្រែក្រៅផ្លូវការពីឯកសារដើមភាសាបារាំង)។

[39] *ដូចជើងទំព័រខាងលើ* (បកប្រែក្រៅផ្លូវការពីឯកសារដើមភាសាបារាំង)។ *សូមមើលផងដែរ* អត្ថបទរបស់Douglas Gillinson, មានចំណងជើងថា៖ 'សាលាក្តីខ្មែរក្រហមប្រកាសពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត', សារព័ត៌មាន*The Cambodia Daily*, ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ទំព័រ២។

[40] អត្ថបទរបស់ Douglas Gillinson, មានចំណងជើងថា៖ 'សាលាក្តីខ្មែរក្រហមប្រកាសពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត', សារព័ត៌មាន *The Cambodia Daily*, ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ទំព័រ២។ *សូមមើលផងដែរ* អត្ថបទរបស់ Douglas Gillison, មានចំណងជើងថា៖ 'ចៅក្រមសាលាក្តីខ្មែរក្រហមមិនបានចុះហត្ថលេខាឲ្យមានការស៊ើបអង្កេតទេ', សារព័ត៌មាន *The Cambodia Daily*, ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០, ទំព័រ២៦។

សួរទាំងនោះ ត្រូវបានបដិសេធ *បន្ទាប់ពី* "ឧត្តមសេនីយ៍ឯក ខៀវ សុភ័ក្ត្រ មន្ត្រីនាំពាក្យក្រសួងមហាផ្ទៃ [រាជរដ្ឋាភិបាល] បានលើកឡើងជាសាធារណៈនូវជំហរ [របស់រាជរដ្ឋាភិបាល] ជំទាស់នឹងការបើកកិច្ចស៊ើបសួរថ្មី [...] ដោយដកស្រង់ការព្រមានជាបន្តបន្ទាប់របស់សម្ដេច ហ៊ុន សែន ពីការកើតមាននូវការជ្រួលច្របល់៖ "មានតែថ្នាក់ដឹកនាំកំពូលតែប្រាំរូបប៉ុណ្ណោះ ដែលត្រូវយកមកជំនុំជម្រះ" ឧត្តមសេនីយ៍ឯក ខៀវ សុភ័ក្ត្រ បាននិយាយថា៖ "មិនមែនប្រាំមួយទេ គឺប្រាំ។ តុលាការត្រូវតែធានានូវស្ថេរភាព និងសន្តិភាពរបស់ជាតិ"។ គាត់បាននិយាយទៀតថា៖ "យើងមិនចង់បានជម្លោះ និងអស្ថេរភាពផ្ទៃក្នុងនោះទេ"" [41]។

12. ឆ្លើយតបទៅនឹងព្រឹត្តិការណ៍ជាបន្តបន្ទាប់នេះ និងដោយសារការបន្តពាក់ព័ន្ធរបស់សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង នៅក្នុងសំណុំរឿងក្តី០០២ សហមេធាវីសូមដាក់សំណើដកសិទ្ធិជាសហចៅក្រមស៊ើបអង្កេតរបស់គាត់[42] និងសូមដាក់បន្ថែមនូវសំណើឲ្យបើកកិច្ចស៊ើបសួរអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង[43]។ សំណើទាំងពីរត្រូវបានអង្គបុរេជំនុំជម្រះច្រានចោល ដោយសារព័ត៌មានបញ្ជាក់ពីអង្គហេតុមិនគ្រប់គ្រាន់[44]។

*៤. ការវាយតម្លៃដោយឯករាជ្យបន្ថែមទៀត និងប្រតិកម្មរបស់រដ្ឋាភិបាល*

13. ក្នុងខែមីនា ឆ្នាំ២០១០ គម្រោងយុត្តិធម៌សង្គមសេរី ("OSJI") បានចេញផ្សាយរបាយការណ៍មួយដែលនៅក្នុងនោះ បានលើកឡើងពីការពាក់ព័ន្ធជ្រៀតជ្រែករបស់រដ្ឋាភិបាលនៅ អ.វ.ត.ក៖

> នៅក្នុងរយៈពេលប្រាំមួយខែកន្លងទៅ អន្តរាគមន៍មិនប្រក្រតីបានបង្ហាញឲ្យឃើញ នៅក្នុងការឆ្លើយតបរបស់មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ទៅនឹងការកោះហៅមន្ត្រីជាន់ខ្ពស់របស់សហចៅក្រម

---

[41] អត្ថបទរបស់ Douglas Gillison, មានចំណងជើងថា៖ 'សាលាក្តីខ្មែរក្រហមចាប់ផ្តើមស៊ើបអង្កេតជនសង្ស័យថ្មី ៥នាក់បន្ថែមទៀត', សារព័ត៌មាន *The Cambodia Daily*, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ ទំព័រ២៦។

[42] *សូមមើល* បណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង។

[43] *សូមមើល* សំណុំរឿង០០២/០៧-០៧-២០១០-អ.វ.ត.ក-អ.ប.ជ (០១), ឯកសារលេខ 1, 'សំណើលើកទី២ សុំបំពេញកិច្ចស៊ើបសួរ' ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០, ERN 00553229-00553250។

[44] *សូមមើល* ឯកសារលេខ **D-384/5/1**, 'បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទីពីរ របស់លោក នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ (វិធាន៣៥)', ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០, ERN 00598096–00598113។ ឯកសារលេខ **D-384/5/2**, 'សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទីពីររបស់ លោក នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ (វិធាន៣៥)', ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០, ERN 00608821–00608839។ សំណុំរឿងលេខ០០២/១៧-០៦-២០១០-អ.វ.ត.ក-អ.ប.ជ (០៩), ឯកសារលេខ 8, 'សាលដីកាលើបណ្តឹងជំទាស់ ចៅក្រម យូ ប៊ុនឡេង', ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០, ERN 00600686–00600706។

> ស៊ើបអង្កេតនៅក្នុងសំណុំរឿងក្តី០០២ និងការបើកកិច្ចស៊ើបសួរមួយដើម្បីចោទប្រកាន់ទៅលើជនត្រូវចោទចំនួនប្រាំនាក់បន្ថែមទៀតនៅក្នុងសំណុំរឿងក្តី០០៣ និង០០៤។ មន្ត្រីរដ្ឋាភិបាលដែលមានឥទ្ធិពលមួយចំនួន រួមទាំងសម្តេចនាយករដ្ឋមន្ត្រីផង បានបញ្ជាក់ពីគោលជំហរច្បាស់លាស់របស់ខ្លួនថា សាក្សីទាំងនោះដែលត្រូវកោះហៅទាំងនោះនឹងមិន មកបង្ហាញខ្លួនឡើយ ហើយសំណុំរឿងក្តី០០៣ និង០០៤ នឹងមិនបន្តទេ[45]។

ក្រោយមកនៅក្នុងឆ្នាំនោះដែរ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកខាងសិទ្ធិមនុស្សនៅកម្ពុជា លោក Surya Subedi បានរិះគន់យ៉ាងចាស់ដៃអំពីការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលចំពោះការងារតុលាការកម្ពុជា ដោយបានលើកឡើងថា៖ "ការលូកដៃទាំងខាងនយោបាយ និងខាងហិរញ្ញវត្ថុ បានធ្វើឲ្យអន្តរាយដល់សេចក្តីទុកចិត្តរបស់ប្រជាជនកម្ពុជាចំពោះស្ថាប័នយុត្តិធម៌" [46]។

14. មានការរាយការណ៍ជាសាធារណៈ អំពីការឲ្យយោបល់ពីចៅក្រមកម្ពុជាម្នាក់ នៅក្នុងតុលាការកម្ពុជាថា ការរាំងស្ទះបណ្តាលមកពីរាជរដ្ឋាភិបាលនោះ គឺជាជីវិតពិតមួយដែលកើតមានជាធម្មតាទៅហើយនៅអ.វ.ត.ក៖ "តើយើងអាចនិយាយថា តុលាការនេះជាគម្រូតំណាងឲ្យឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌បានយ៉ាងដូចម្តេច បើរាជរដ្ឋាភិបាលមិនឲ្យយើងធ្វើកិច្ចការរបស់យើងផង នោះ?"[47]។ ពាក់ព័ន្ធនឹងបញ្ហានេះ សម្តីចុងក្រោយនេះគឺជាសម្តីរបស់ សម្តេច ហ៊ុន សែន ដែលអាចជារាប់បញ្ចូលជាចំហរអំពីការជ្រៀតជ្រែកនៅក្នុងកិច្ចការតុលាការនាពេលបច្ចុប្បន្ននេះ ប្រាប់ទៅលោកអគ្គលេខាអង្គការសហប្រជាជាតិ បាន គីមូន ដែលបានមកទស្សនកិច្ចកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ ថា នឹងមិនមានការចោទប្រកាន់បន្ថែមទៀតទេ ក្រៅតែពីបុគ្គលទាំងឡាយដែលកំពុងស្ថិតក្នុងចំណាត់ការ ហើយដែលរាជរដ្ឋាភិបាល "បានអនុញ្ញាត" នោះឡើយ[48]។

---

[45] របាយការណ៍របស់ OSJI, មានចំណងជើងថា៖ 'ការវិវត្តថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា', បច្ចុប្បន្នភាពខែមីនា ឆ្នាំ២០១០, ទំព័រ៦ មាននៅ៖http://www.soros.org/initiatives/justice/focus/international_justice/articles_publications/publications/cambodia-20100324/cambodia-court-20100324.pdf ។

[46] អត្ថបទរបស់ Mark Worley & Neou Vannarin, មានចំណងជើងថា៖ 'UN Envoy Says Judiciary "Compromised"', សារព័ត៌មាន *The Cambodia Daily*, ចេញផ្សាយថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១០, ទំព័រ១, ២។

[47] អត្ថបទរបស់ James Goldston, ព្រឹត្តិប័ត្រសារព័ត៌មាន*The Wall Street Journal*, OP-ED, មានចំណងជើងថា៖ 'Cambodia's Court at a Crossroads', ចេញផ្សាយថ្ងៃទី១ ខែមិនា ឆ្នាំ២០១០។

[48] *សូមមើល* របាយការណ៍របស់ AFP ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១០ ("លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានជម្រាបប្រាប់អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គី-មូន ដែលកំពុងដំណើរទស្សនកិច្ចកាលពីថ្ងៃពុធថា សវនាការជំនុំជម្រះពួកខ្មែរពីបទឧក្រិដ្ឋកម្មសង្គ្រាមក្នុងសំណុំរឿង០០២ គ្រោងនឹងចាប់ផ្តើមនៅដើមឆ្នាំក្រោយ និងជាសវនាការចុងក្រោយ។ លោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេសបានប្រាប់បណ្តាអ្នកយកសារព័ត៌មាន បន្ទាប់ពីជំនួបរវាងលោក បាន គី-មូន និង លោកនាយករដ្ឋមន្ត្រីថា

## គ. ការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត

### *១. វិធានសាស្ត្រទូទៅ*

15. ថ្វីត្បិតតែអាណត្តិការងាររបស់សហចៅក្រមស៊ើបអង្កេតគឺត្រូវធ្វើការស៊ើបអង្កេតមួយប្រកបដោយអនាគតិនោះ[49] ក៏សំណុំរឿងដែលបញ្ជូនឲ្យអង្គជំនុំជម្រះសាលាដំបូងនោះ ពិបាកនឹងនិយាយថា វាជាសមិទ្ធិផលមានតុល្យភាពរបស់អាជ្ញាកណ្តាលមួយរូបដែលអព្យាក្រិត្យចំពោះការពិតនោះដែរ។ ប៉ុន្តែសំណុំរឿងក្តី ដែលទំហំ និងខ្លឹមសារបានមកពីការស្រាវជ្រាវដ៏ទូលំទូលាយរយៈពេល១៥ឆ្នាំរបស់អង្គការដ៏សំខាន់មួយដែលឧទ្ទិសសម្រាប់តែការបង្កើតអ្វីដែលកើតឡើងថាជា "អំពីរបបប្រល័យពូជសាសន៍" នៅកម្ពុជា គឺមជ្ឈមណ្ឌលឯកសារ កម្ពុជា ("DC-Cam") បង្ហាញថា ការិយាល័យចៅក្រមមានការលំអៀងទៅលើលទ្ធផលជាប្រវត្តិសាស្ត្រ ដែលបានកំណត់ទុកមុនរួចជាស្រេចហើយនោះ។ នៅពេលដែលវិធានការរបស់រាជរដ្ឋាភិបាលក្នុងការ ចូលជ្រៀតជ្រែកត្រូវបានបង្ហាញដោយចំហរយ៉ាងកម្រោលបែបនេះ (ប្រហែលជាដោយសារធ្លាប់មាន បទពិសោធន៍ជាមួយនឹងការកាត់សេចក្តីឲ្យតែមាន) រឿងប្រឌិតផ្នែកយុត្តិធម៌របស់ ក.ស.ច.ស បាន បានអនុវត្តទៅដោយមានការលាក់កំបាំង។

### *២. កង្វះតម្លាភាព*

16. ពាក់ព័ន្ធនឹងតម្រូវការក្នុងការរក្សាការសម្ងាត់ ក.ស.ច.ស បានបដិសេធជាបន្តបន្ទាប់ក្នុងការការផ្តល់ព័ត៌មានអំពីវិធីនៃការបើកកិច្ចស៊ើបអង្កេត។ មិនមានការផ្តល់ព័ត៌មានអំពី៖ (i) សមត្ថភាពរបស់មន្ត្រីស៊ើបអង្កេត អ្នកវិភាគ ឬអ្នកបកប្រែភាសាផ្ទាល់មាត់ (ii) វិធីសាស្ត្រនៃការធ្វើការ ឬ (iii) ការអនុវត្តវិធីសាស្ត្រក្នុងការការកំណត់សាក្សី និងភស្តុតាង។ ក្រុមសហមេធាវីការពារក្តី បានព្យាយាមយ៉ាងខ្លាំងដើម្បីបើករបាំងការសម្ងាត់នេះ ប៉ុន្តែការខិតខំប្រឹងប្រែងទាំងនោះមិនបានប្រយោជន៍ឡើយ[50]។ ការមិនឆ្លើយតបបែបនេះ ក៏ដូចជាកាលៈទេសៈផ្សេងទៀត ធ្វើឲ្យសហមេធាវីកំណត់ឃើញនូវការព្រួយ

---

លោក ហ៊ុន សែន "បានបញ្ជាក់យ៉ាងច្បាស់ថា មិនអនុញ្ញាតឲ្យមានរឿងក្តី០០៣ ទេ"។ គាត់បានមានប្រសាសន៍ថា "យើងត្រូវតែគិតគូរពីសន្តិភាពនៅកម្ពុជា")។

[49] *សូមមើល* វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង ('ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ។')

[50] *សូមមើល, ឧទាហរណ៍,* ឯកសារ **D-171**, "សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីបី របស់លោក អៀង សារី", ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៩, ERN 00330819–00330834។ ឯកសារ **D-171/2**, "សេចក្តីជូនដំណឹងពីការចូលរួមជាមួយសំណើលើកទី៣ ស្នើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីលោក អៀង សារី", ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០០៩, ERN 00337488–00337489។

បារម្ភជាក់លាក់ជាច្រើនពាក់ព័ន្ធនឹងដំណើរការស៊ើបអង្កេត[51] ហើយបានដាក់ជូននូវសំណើសុំប្តឹងជំទាស់ចៅក្រម Marcel Lemonde[52]។

*៣. កង្វះខាតភ្នាក់ងារគ្រប់គ្រាន់*

17. ក.ស.ច.ស បានបញ្ជាក់យ៉ាងច្បាស់រួចមកហើយតាំងពីដំបូងទីនៃកិច្ចដំណើរការនីតិវិធីថា មិនអនុញ្ញាតឱ្យសហមេធាវីធ្វើការស៊ើបអង្កេតដោយខ្លួនឯងនោះទេ[53]។ ជាងនេះទៅទៀត ក្រុមមេធាវីការពារក្តីមិនអនុញ្ញាតឱ្យចូលរួមស្តាប់ចម្លើយសាក្សី*ណាទាំងអស់* ដែលធ្វើឡើងដោយ ក.ស.ច.ស ឬដោយមន្ត្រីស៊ើបអង្កេតដែលទទួលបានការចាត់តាំងដោយ ក.ស.ច.ស ឡើយ។ ផ្ទុយទៅវិញ ស.ច.ស បានផ្តល់ឱ្យភាគីទាំងឡាយនូវសិទ្ធិក្នុងការ*ដាក់សំណើឱ្យក.ស.ច.ស* ធ្វើការស៊ើបអង្កេតជាក់លាក់ផ្សេងៗជំនួសឱ្យភាគី ដែលនេះជាការបញ្ជាក់ឱ្យឃើញច្បាស់នូវឋានៈរបស់ចៅក្រមជាភ្នាក់ងាររបស់សហមេធាវី។

18. យោងលើមូលដ្ឋាននេះ សហមេធាវីបានដាក់ជូននូវសំណើមួយចំនួនជួសឱ្យ នួន ជា៖ សរុបមានចំនួនម្ភៃប្រាំមួយសំណើ ដែលគេហៅថា សំណើសុំបើកកិច្ចស៊ើបសួរ (“RIA”)[54]។ ប៉ុន្តែ ស្ទើរតែគ្រប់សំណើទាំងនោះ ត្រូវបាន ក.ស.ច.ស បដិសេធចោល ឬបានធ្វើការស៊ើបអង្កេតមិនគ្រប់គ្រាន់តាមការស្នើសុំឡើយ[55]។ គួរឱ្យកត់សម្គាល់ថា ក្នុងចំណោមសំណើស្នើឱ្យបើកកិច្ចស៊ើបសួរដែលមានជាប់ពាក់ព័ន្ធទាំងស្រុងជាមួយសាក្សី និងកិច្ចសម្ភាសន៍សាក្សីទាំងនោះ សហមេធាវីបានស្នើឱ្យ ក.ស.ច.ស កែតម្រូវនូវការស្តាប់ចម្លើយរបស់សាក្សីមួយចំនួនដែលមានវិការៈជាច្រើន ហើយកំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ៖ “វិធីសាស្ត្ររបស់ ស.ច.ស ក្នុងការស្តាប់ចម្លើយសាក្សី ត្រូវបានជិតដាមទៅដោយវិការៈ និងការខកខានមិនបានស្តាប់ចម្លើយសាក្សីជាច្រើន ជាពិសេស អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស តែងតែមិនអើពើក្នុងការបង្ហាញអំពីប្រភពនៃការដឹងអំពីអង្គហេតុរបស់សាក្សី និងព្រមទាំងខកខានមិនបានលើកឡើងអំពីបញ្ហានៃតម្លាភាព ភាពពិតប្រាកដ

---

[51] *សូមមើល* ឯកសារ **D-221**, លិខិតជូន ក.ស.ច.ស កម្មវត្ថុ “ កង្វះទំនុកចិត្តនៃការស៊ើបសួរ”, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៨។

[52] *សូមមើល* សំណុំរឿងលេខ ០០២/២៩-១០-២០០៨-អវតក/អបជ(០៤), ឯកសារលេខ ១, ‘បណ្តឹងជំទាស់ចិត្តលោកចៅក្រម Marcel Lemonde’, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨, ERN 00398693–00398704 (‘បណ្តឹងជំទាស់ចិត្តលោកចៅក្រម Lemonde’)។

[53] *សូមមើល* ឯកសារ **A-110/I**, អនុស្សរណៈពី ក.ស.ច.ស ជូនចំពោះសហមេធាវីការពារក្តី, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៨, ERN 00157729–00157730។

[54] *សូមមើល* ឯកសារ **D-80, 100, 101, 102, 105, 113, 122, 126, 128, 136, 158, 173, 179, 194, 130/11, 253, 265, 273, 318, 319, 320, 336, 338, 339, 340, និង 356**។

[55] *កំណត់សម្គាល់ពិសេស៖* នៅក្នុងករណីបែបនេះ កិច្ចស៊ើបសួរតាមដានដែលបង្គាប់ដោយ អបជ មិនស្របទៅនឹងសំណើរបស់មេធាវីការពារក្តីទេ មិនសម្រេចបានលទ្ធផលអ្វី ឬមិនត្រូវបានបើកស៊ើបសួរតែម្តង។

និងភាពត្រឹមត្រូវ នៅពេលធ្វើការចងក្រងកំណត់ហេតុចម្លើយរបស់សាក្សី"[56]។ ប៉ុន្តែទោះបីជាមានហេតុផលពិតប្រាកដគ្រប់គ្រាន់ក៏ដោយ ក៏សំណើសុំឱ្យបើកកិច្ចស៊ើបសួរទាំងនោះ ស្ទើរតែទាំងអស់ត្រូវបាន ក.ស.ច.ស បដិសេធចោល ហើយវិធីសាស្ត្រនេះត្រូវអង្គបុរេជំនុំជម្រះ គាបសង្កត់នៅពេលប្តឹងឧទ្ធរណ៍[57]។ មានតែករណីមួយចំនួនតូចប៉ុណ្ណោះ ដែល*ភស្តុតាងដាក់បន្ទុក* បន្ថែម ទំនងជាអាចទទួលបានតាមរយៈការស្តាប់ចម្លើយសាក្សី ទើប ក.ស.ច.ស ចេញដីកាឱ្យស្តាប់ចម្លើយសាក្សីនោះឡើងវិញ ទៅតាមការស្នើសុំរបស់សហមេធាវី[58]។

*៤. ភាពលម្អៀងក្នុងការគាំទ្រភស្តុតាងដាក់បន្ទុក*

19. ព័ត៌មានផ្ទៃក្នុងរបស់ ក.ស.ច.ស បង្ហាញឱ្យដឹងថា ចៅក្រម Lemonde បានចូលរួមប្រជុំជាមួយមន្ត្រីសំខាន់ៗមួយចំនួនរបស់គាត់ ដោយបង្ហាញពីការព្យាយាមស្វែងរកភស្តុតាងបន្ថែមសម្រាប់តែការដាក់បន្ទុក ជាជាងស្វែងរកភស្តុតាងដោះបន្ទុក[59]។ ជាការឆ្លើយតបចំពោះបញ្ហានេះ សហមេធាវីបានសុំប្តឹងជំទាស់ចៅក្រម Lemonde[60]។ សំណើនោះត្រូវបាន អ.ប.ជ បដិសេធចោល[61] បើទោះជាការថ្លែងពីភាពលម្អៀងរបស់ចៅក្រម Lemonde មានភស្តុតាងនៅក្នុងវិធីសាស្ត្ររបស់ ក.ស.ច.ស ក្នុងការឆ្លើយតបទៅនឹងសំណើសុំឱ្យបើកកិច្ចស៊ើបសួរនានា[62]។ បន្ថែមលើនេះទៀត ចៅក្រម Lemonde បានអនុញ្ញាតឱ្យមានការចែកចាយផ្ទៃក្នុងនៅក្នុងរង្វង់ ក.ស.ច.ស នូវឯកសារមិនផ្លូវការមួយដែលផ្តល់ដោយ

---

[56] *សូមមើល,* ឧទាហរណ៍, ឯកសារ **D-318**, "សំណើទី១៩ សំណើសុំបំពេញកិច្ចស៊ើបសួរ" ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០, , ERN 00417064–00417072, កថាខណ្ឌ ៩។

[57] *សូមមើល* ឯកសារលេខ **D-375**, កសចស 'ដីកាលើសំណើ នួន ជា សុំឱ្យសម្ភាសសាក្សី (D318, D319, D320, D336, D339 & D340)' [RIAs 19-25], ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១០ , ERN 00495898-00495911 ('ដីការ កសចស លើសំណើសុំស្តាប់ចម្លើយសាក្សី'); សូមមើលឯកសារលេខ **D-375/1/4**, 'សេចក្តីសម្រេច អបជ លើដីកា សចស លើសំណើ នួន ជា សុំស្តាប់ចម្លើយសាក្សី '), ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០, ERN 00531133-00531138។

[58] *សូមមើល* ឯកសារ **D-375**, "ដីកាសម្រេចលើសំណើរបស់ នួន ជា សុំស្តាប់ចម្លើយសាក្សី" ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១០, ERN 00495898–00495911។

[59] *សូមមើល* បណ្តឹងជំទាស់លោកចៅក្រម Lemonde។

[60] *ដូចជើងទំព័រខាងលើ។*

[61] *សូមមើល* សំណុំរឿងលេខ ០០២/២៩-១០-២០០៩-អ.វ.ត.ក/អ.ប.ជ (០៤), ឯកសារលេខ 4, 'សាលដីកាលើបណ្តឹងរបស់ នួន ជា សុំប្តឹងជំទាស់ចៅក្រម Marcel Lemonde', ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០, ERN 00485317–00485329។

[62] *សូមមើល* កថាខណ្ឌ៥៦-៥៩, *យោងខាងក្រោម។*

លោក Craig Etcheson ដែលជាមន្ត្រីនៅការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") ពាក់ព័ន្ធនឹងវិធីសាស្ត្រសំខាន់សម្រាប់ការស៊ើបសួរ[63]។

## ឃ. ការអនុម័ត និងការអនុវត្តវិធាន

20. នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិ ('អ.ស.ប") និងរាជរដ្ឋាភិបាលកម្ពុជា ('រដ្ឋាភិបាល") បានព្រមព្រៀងគ្នាឈានដល់កិច្ចព្រមព្រៀងមួយ 'ពាក់ព័ន្ធនឹងការកាត់សេចក្តីក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ" ('កិច្ចព្រមព្រៀង អ.វ.ត.ក")។ គោលបំណងដូចមានចែងនៅក្នុងសន្ធិសញ្ញាទ្វេភាគីនេះ គឺដើម្បីផ្តល់នូវ 'មូលដ្ឋានគតិយុត្តិ គោលការណ៍ និងបែបបទ"[64] សម្រាប់បង្កើតឲ្យមានកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនានា ដូចពេលបច្ចុប្បន្ន *'ក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់"*[65]។ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ[66] កិច្ចព្រមព្រៀង អ.វ.ត.ក បានចូលជាធរមាននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ បន្ទាប់ពីទទួលបានការអនុម័តដោយស្ថាប័ននីតិបញ្ញត្តិកម្ពុជា ទទួលបានសច្ចាប័នពីប្រមុខរដ្ឋស្តីទី និងត្រូវបានប្រកាសដាក់ឲ្យប្រើដោយព្រះមហាក្សត្រនរោត្តម សីហនុ[67]។ យោងមាត្រា២(២) កិច្ចព្រមព្រៀង អ.វ.ត.ក 'ត្រូវអនុវត្តក្នុងប្រទេសកម្ពុជា តាមរយៈច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ [ក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ]" ('ច្បាប់ អ.វ.ត.ក") [68]។

---

63 *សូមមើល* សណ្ណុំរឿងលេខ ០០២/០៧-១២-២០០៩-អ.វ.ត.ក/អ.ប.ជ (០៥), ឯកសារលេខ 1, 'ពាក្យបណ្តឹងរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ប្តឹងជិតចិត្តសហចៅក្រមស៊ើបអង្កេត លោក Marcel Lemonde', ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩, ERN 00411010–00411026, កថាខណ្ឌ១១(ង)។

64 កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា១។

65 កិច្ចព្រមព្រៀង អ.វ.ត.ក អារម្ភកថា កថាខណ្ឌ ៤ (បញ្ជាក់បន្ថែម)។

66 កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា៣០ ('ដើម្បីភ្ជាប់កាតព្វកិច្ចជាមួយបណ្តាភាគី កិច្ចព្រមព្រៀងនាពេលបច្ចុប្បន្ន ត្រូវតែមានការយល់ព្រមពីមហាសន្និបាតរបស់អង្គការសហប្រជាជាតិ និងផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា') *សូមមើលផងដែរ* មាត្រា៣១ (កិច្ចព្រមព្រៀងបច្ចុប្បន្ន ត្រូវអនុវត្តជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោយពីផ្តល់សច្ចាប័ន អនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងសិទ្ធិក្នុងការចុះសន្ធិសញ្ញានានា')។ មាត្រា៣២ ('កិច្ចព្រមព្រៀងបច្ចុប្បន្ន ត្រូវចូលជាធរមាន នៅថ្ងៃដែលភាគីទាំងពីរបានផ្តល់ការជូនដំណឹងគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរ ដែលជាការតម្រូវតាមច្បាប់ដើម្បីត្រូវអនុវត្តតាម')។

67 *សូមមើល* រាជក្រម នស/ករម/១០០៤/០៤ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤; លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤។

68 ច្បាប់ អ.វ.ត.ក ត្រូវបានអនុម័តដាក់ឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ និងធ្វើវិសោធនកម្ម នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។ *សូមមើល* រាជក្រម នស/ករម/០៨០១/១២; រាជក្រម នស/ករម/១០០៤/០៦។

21. នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៦ លេខាធិការដ្ឋានគណៈកម្មាធិការវិធាន និងនីតិវិធី នៃ អ.វ.ត.ក បានបញ្ជូនសេចក្ដីព្រាងវិធានផ្ទៃក្នុង ចំនួន១១៣ច្បាប់ ដើម្បីទទួលយកអនុសាសន៍ពីសាធារណជន ('សេចក្ដីព្រាងវិធាន") [69]។ គួរឲ្យកត់សម្គាល់ដែរថា ឯកសារនេះ មិនមានការពន្យល់ណាមួយ ដូចជា វិធីសាស្ត្រអ្វីដែលត្រូវបានយកមកប្រើប្រាស់នៅក្នុងដំណើរការរៀបចំសេចក្ដីព្រាងវិធាន ឬតើអ្នករៀបចំសេចក្ដីព្រាងវិធាន មានការយល់ឃើញបែបណា មុននឹងឈានដល់ការសន្និដ្ឋានថា នីតិវិធីកម្ពុជាជាធរមាន មិនត្រូវយកមកអនុវត្តដោយផ្ទាល់ និងដោយឡែកឡើយ។ សេចក្ដីព្រាងវិធាននោះក៏មិនមានពន្យល់ពីមូលដ្ឋានសម្រាប់ការអនុវត្តអំណាចនីតិបញ្ញត្តិរបស់ អ.វ.ត.ក ដែរ។ ប៉ុន្តែ សេចក្ដីព្រាងវិធានទាំងនោះបានបញ្ចូលជើងទំព័រចំនួន១៩០ ដែលមាន (ភាគច្រើន) គឺជាការយោងខ្លីៗលើប្រភពនានា ដែលដកស្រង់ចេញពីនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ និងនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ដោយផ្អែកលើឯកសារយោងរួមគ្នាទាំងនេះ ដែលរួមបញ្ចូលលក្ខន្តិកៈ និងវិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការពិសេសនៅសៀរ៉ាឡេអូន ('SCSL") និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ('ICC") បង្ហាញឲ្យឃើញថា គ្មានការខិតខំប្រឹងប្រែងឲ្យបានដិតដល់ក្នុងការបកស្រាយ និងអនុវត្តមាត្រា១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដោយពិចារណាទៅលើគោលបំណង និងកម្មវត្ថុនៃកិច្ចព្រមព្រៀង ដើម្បីធានាពីអាទិភាពនៃច្បាប់កម្ពុជានោះឡើយ។

22. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននេះ ('CCP") ត្រូវបានសភាជាតិអនុម័តនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧។ យោងមាត្រា១ ក្រមព្រហ្មទណ្ឌកម្ពុជា 'មានគោលបំណងកំណត់អំពីវិធានទាំងឡាយ *ដែលត្រូវគោរព និងប្រតិបត្តិតាមដោយហ្មត់ចត់* ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។ បទប្បញ្ញត្តិនៃ[ក្រមព្រហ្មទណ្ឌកម្ពុជា] ត្រូវយកទៅអនុវត្តចំពោះរឿងព្រហ្មទណ្ឌ កាលណាពុំមានវិធានដោយឡែក ចែង*ដោយច្បាប់ពិសេសនោះទេ* [70]។

23. នៅឯកិច្ចប្រជុំមួយដែលមានឈ្មោះថា 'កិច្ចប្រជុំពេញអង្គ' ដែលបានប្រព្រឹត្តទៅកាលពីខែមិថុនា ឆ្នាំ២០០៧ មន្ត្រី អ.វ.ត.ក ជាច្រើន បានមកជួបជុំគ្នា ក្នុងគោលបំណងជាច្រើន ប៉ុន្តែមានគោលបំណងមួយគឺដើម្បីអនុម័តវិធាន។ គោលបំណងនៃកិច្ចប្រជុំនេះមានពីរគឺ៖ (i) 'ច្របាច់បញ្ចូលនីតិវិធីជាធរមានរបស់កម្ពុជា សម្រាប់អនុវត្តក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" និង (ii) 'អនុម័តវិធានមួយចំនួនបន្ថែម" អនុលោមទៅតាមបទប្បញ្ញត្តិទាក់ទងនានានឹងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង ('លិខិតុបករណ៍

---

69 *សូមមើល* [សេចក្ដីព្រាងវិធាន]។

70 បញ្ជាក់បន្ថែម

ជាមូលដ្ឋាន") [71]។ វិធានត្រូវបានធ្វើវិសោធនកម្មនៅកិច្ចប្រជុំពេញអង្គក្រោយៗទៀត កាលពីខែកុម្ភៈ ឆ្នាំ២០០៨ ខែកញ្ញា ឆ្នាំ២០០៨ ខែមីនា ឆ្នាំ២០០៩ ខែកញ្ញា ឆ្នាំ២០០៩ ខែកុម្ភៈ ឆ្នាំ២០១០ និងខែកញ្ញា ឆ្នាំ២០១០។ 'នីតិវិធីដែលត្រូវបានច្របាច់បញ្ចូលគ្នា" និង 'វិធានបន្ថែម" ដែលបានអនុម័តនៅកិច្ចប្រជុំក្រៅអំណាចតុលាការដ៏ច្រើនទាំងនោះ ពុំធ្លាប់ត្រូវបានពិនិត្យមើលឡើងវិញ ដោយនីតិវិធីបញ្ញត្តិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ)[72] នោះទេ ហើយវិធានទាំងនោះក៏មិនធ្លាប់បានទទួលការយល់ព្រមពីក្រុមប្រឹក្សាធម្មនុញ្ញផងដែរ។ បន្ថែមលើនេះទៀត គ្មាននរណាដឹងឲ្យបានច្បាស់លាស់ត្រឹមកម្រិតណាមួយនោះទេ ថាតើវិធានជាក់លាក់ណាមួយ ដែលពិតជាកើតចេញពីការអនុវត្តមាត្រា១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដោយពិតប្រាកដ និងគ្មានការសង្ស័យនោះ។ ចុងបញ្ចប់ ដោយយោងទៅលើការវិវឌ្ឍរបស់នីតិវិធីព្រហ្មទណ្ឌកម្ពុជា[73] រួមមានការបង្កើតឲ្យមានច្បាប់សំខាន់ៗមួយចំនួន[74] បញ្ហាដែលវិធានជាក់លាក់មួយចំនួនមិនអាចយកមកអនុវត្តបាន - ក្នុងន័យដែលក្រមព្រហ្មទណ្ឌកម្ពុជាបច្ចុប្បន្ន ផ្តល់នូវដំណោះស្រាយតាមនីតិវិធីមានប្រសិទ្ធភាព និងសមស្របនានា - មិនធ្លាប់ដែលបានលើកយកមកពិភាក្សាឲ្យបានស៊ីជម្រៅនោះទេ។

24. នួន ជា ត្រូវបានចាប់ខ្លួន និងឃុំខ្លួន ដោយមន្ត្រី អ.វ.ត.ក កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។ បន្ទាប់ពីនោះមិនយូរប៉ុន្មាន ក្រុមមេធាវីការពារក្តី បានលើកឡើងថា នៅពេលវិធានបំពានលើបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌកម្ពុជាជាធរមាននោះ ក្រមព្រហ្មទណ្ឌកម្ពុជាត្រូវចាត់ទុកជាអាទិភាព ហើយវិធានត្រូវចាត់ទុកជាមោឃៈ[75]។ អង្គបុរេជំនុំជម្រះ ('អ.ប.ជ") បានបដិសេធការលើកឡើងនេះ ហើយបានប្រកាសថា នៅ អ.វ.ត.ក វិធានមានអាទិភាពលើក្រម ព្រហ្មទណ្ឌកម្ពុជា៖

> ដូច្នេះ វិធានផ្ទៃក្នុងបង្កើតជាប្រព័ន្ធច្បាប់នីតិវិធីដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេស របស់ អ.វ.ត.ក ហើយត្រូវបានអនុម័ត និងមានការយល់ស្របពីកិច្ចប្រជុំពេញអង្គនៃ

---

71 វិធានផ្ទៃក្នុង អារម្ភកថា កថាខណ្ឌ៥។

72 *កំណត់សម្គាល់* ចាប់ពីពេលដែលរដ្ឋធម្មនុញ្ញត្រូវបានអនុម័ត ក្នុងខែកញ្ញា ឆ្នាំ១៩៩៣ មក រដ្ឋធម្មនុញ្ញត្រូវបានធ្វើវិសោធនកម្មលើសពីមួយដង។ ប៉ុន្តែ ក្រុមមេធាវីការពារក្តី មិនមានលទ្ធភាពក្នុងការស្វែងរករដ្ឋធម្មនុញ្ញដែលដាក់ឲ្យប្រើប្រាស់នាពេលបច្ចុប្បន្ននេះ ជាភាសាអង់គ្លេសបានឡើយ។ ដូច្នេះ អំណះអំណាងនៅទីនេះ គឺយោងឯកសារដែលមាននៅក្នុងកម្រងឯកសារច្បាប់ អ.វ.ត.ក (ឯកសារលេខ C070E-1993)។

73 *សូមមើល* កថាខណ្ឌ ៤ *ដូចឯកសារខាងលើ*។

74 ឧទាហរណ៍ ក្រមព្រហ្មទណ្ឌថ្មី ត្រូវបានអនុម័តនៅឆ្នាំ២០១០។

75 សូមមើលឯកសារលេខ D-55/I/1, 'បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធបណ្តឹងសុំមោឃភាព', ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៨, ERN 00165047-00165056 ('ដីកា'), កថាខណ្ឌ ១២។

> អ.វ.ត.ក។ វិធានផ្ទៃក្នុងនេះមិនផ្ទុយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ ប៉ុន្តែគោលបំណង របស់ អ.វ.ត.ក ខុសគ្នាជាសំខាន់ពីដំណើរការសាមញ្ញរបស់តុលាការព្រហ្មទណ្ឌកម្ពុជា ដែល តម្រូវឱ្យ អ.វ.ត.ក មានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស។ ដូច្នេះ វិធានផ្ទៃក្នុងជាលិខិតុបករណ៍ចម្បង ដែលយើងគួរនឹងយកមកពិនិត្យមើល ក្នុងការកំណត់នីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក្នុងករណីមានភាពខុសគ្នា រវាងនីតិវិធីវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[76]។
>
> បទប្បញ្ញត្តិនៃក្រមនីតិវិធីកម្ពុជាគួរយកមកអនុវត្ត ក្នុងករណីមានបញ្ហាចោទណាមួយ ដែល វិធាន ផ្ទៃក្នុងមិនមានចែងតែប៉ុណ្ណោះ[77]។

អ.ប.ជ មិនបានគាំទ្រ ដោយមានសំអាងផ្លូវច្បាប់ ចំពោះការដកចេញ*ជាទូទៅ* នូវការអនុវត្តផ្ទុយពីនីតិវិធីកម្ពុជាដែលមានស្រាប់នោះឡើយ។ លើសពីនេះទៀត អ.ប.ជ ខកខានមិនបានបកស្រាយ និង អនុវត្តមាត្រា១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដោយអនុលោមទៅតាមអត្ថន័យដ៏សាមញ្ញ និង ដោយពិចារណាដល់កម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងនេះទេ។ ជាក់ស្តែង អ.ប.ជ បាន ចាត់ទុកមាត្រា១២(១) ថាជាមាត្រាថ្មីដាច់ដោយឡែក។ ដោយមិនស្នើឱ្យអនុវត្តបទប្បញ្ញត្តិនានានៃ ក្រមព្រហ្មទណ្ឌកម្ពុជា តែចំពោះករណីណា ដែលមិនមានចែងក្នុងវិធានផ្ទៃក្នុងនោះ (ទស្សនៈរបស់ អ.ប.ជ) មាត្រា១២(១) *ចែង* អត្ថន័យផ្ទុយពីនេះយ៉ាងច្បាស់ថា៖ វិធានអាចនឹងត្រូវបានអនុម័ត និងយកមកអនុវត្ត ចំពោះតែករណី ដែលមិនមានចែងនៅក្នុងនីតិវិធីជាធរមានរបស់កម្ពុជា-ជាពិសេស គឺក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ដោយការសម្រេចអនុម័តយកវិធីសាស្ត្រផ្ទុយគ្នានេះ អ.ប.ជ បានប្រព្រឹត្តផ្ទុយនឹងច្បាប់សំខាន់ជាធរមាន និងអាចយកមកអនុវត្ត នៅតុលាការនេះ៖ ពោលគឺច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

25. ការស៊ើបអង្កេតផ្នែកតុលាការ បានបញ្ចប់ទៅ ដោយអនុលោមតាមវិធាន និងការបកស្រាយ (មិនត្រឹមត្រូវ) របស់ អ.ប.ជ ទាក់ទងនឹងការចាត់ទុកវិធានទាំងនោះ នៅក្នុងបទដ្ឋានច្បាប់កម្ពុជា។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ នួន ជា ត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ពីបទប្រល័យពូជសាសន៍

---

[76] ឯកសារលេខ D-55/I/8, 'សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាបដិសេធពាក្យសុំមោឃភាព', ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨, ERN 00219322-00219333 ('បណ្តឹងឧទ្ធរណ៍'), កថាខណ្ឌ ១៤។

[77] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៥។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការបំពារបំពានក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[78]។ អង្គជំនុំជម្រះនេះ បានទទួលសំណុំរឿងជាផ្លូវការ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១[79]។

## III. អង្គច្បាប់ពាក់ព័ន្ធ

### ក. យុត្តាធិការរបស់តុលាការ

26. សហមេធាវីសូមដាក់បញ្ចូលនូវសារណាមួយចំនួនដែលមាននៅក្នុង "បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ"[80] ដែលបានដាក់ពីពេលមុន និង "ចម្លើយតបទៅនឹងចម្លើយតបរួមរបស់ការិយាល័យព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ"[81]។

### ខ. ការរំលត់បណ្តឹងអាជ្ញា

27. យុត្តិសាស្ត្រអន្តរជាតិ និងច្បាប់ករណីនៅ អ.វ.ត.ក បានទទួលស្គាល់ថា ក្នុងតួនាទីជាអាណាព្យាបាលនៃកិច្ចដំណើរការយុត្តិធម៌ តុលាការមានអំណាចឆន្ទានុសិទ្ធក្នុងការពន្យារកិច្ចដំណើរការនីតិវិធី ជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន ក្នុងករណីដែលមានការចោទប្រកាន់ថាមានការរំលោភបំពានក្នុងកម្រិតធ្ងន់ធ្ងរខ្លាំងខុសប្រក្រតី ដោយការបំពានទាំងនោះ "អាចនឹងឲ្យមានការប៉ះពាល់ដល់សុចរិតភាពរបស់តុលាការ""[82]។ ជាក់ស្តែង យោងតាមរឿងក្តី *Lubanga* និងសំអាងផ្សេងៗទៀត

---

[78] *សូមមើល* ឯកសារលេខ D-427/2/12, 'សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ', ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១, ERN 00634916-00634922; *សូមមើលផងដែរ* ឯកសារលេខ D-427, 'ដីកាដំណោះស្រាយ', ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០, ERN 00604508-00605246

[79] *សូមមើល* ឯកសារលេខ E-9, 'ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ', ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១, ERN 00635754-00635759, កថាខណ្ឌ ២។

[80] *សូមមើល*ឯកសារលេខ D-427/3/1 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១០ ERN 00614048-00614065 កឋាខណ្ឌ ៦ ដល់ ២២។

[81] *សូមមើល*ឯកសារលេខ D-427/3/11 ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០ ERN 00629679-00629687 កឋាខណ្ឌ 4 ដល់ 5។

[82] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Radovan Karadzic សំណុំរឿងលេខ IT-95-5/18-AR73.4 "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Karadzic ទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីកិច្ចព្រមព្រៀង Holbrooke" ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០០៩ កថាខណ្ឌ៤៥។ ទាក់ទិននឹងការទទួលយកអំណាចបន្តកិច្ចដំណើរការនីតិវិធីរបស់ អបជ *សូមមើល* ឯកសារលេខ **D264/2/6** "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី (D264/1)" ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១០ ERN 0054379–00543799 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ") កថាខណ្ឌ២២-២៨។ *សូមមើល រឿងក្តី* *Jean-Bosco Barayawiza* *តទល់នឹង រដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-97-19-AR72 "សេចក្តីសម្រេច" ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ កថាខណ្ឌ៧៤ ៧៧។ នៅក្នុងរឿងក្តីនេះ អង្គជំនុំជម្រះ

អង្គបុរេជំនុំជម្រះបានសម្រេចនាពេលថ្មីៗនេះថា វិធានការបែបនោះអាចជាការចាំបាច់ក្នុង "ករណីដែលការរំលោភលើសិទ្ធិរបស់ជនជាប់ចោទមានលក្ខណៈធ្ងន់ធ្ងរមិនអាចកែតម្រូវបាន ឬវាបានរំលោភទៅនឹងស្មារតីយុត្តិធម៌របស់តុលាការ"[83]។ ក្នុងកាលៈទេសៈបែបនេះ អ.ប.ជ បានផ្តល់សំអាងហេតុថា វាអាស្រ័យលើតុលាការក្នុងការ "ពុះពាររកឲ្យបាននូវតុល្យភាពដ៏ត្រឹមត្រូវរវាងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ និងផលប្រយោជន៍របស់សហគមន៍ជាតិ និងអន្តរជាតិ ក្នុងការកាត់សេចក្តីបុគ្គលទាំងឡាយដែលបានចោទប្រកាន់ពីការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ជាតិ"[84]។

28. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ថ្មីៗនេះ បានសម្រេចថា៖ "ក្នុងកាលៈទេសៈដែលមានការគម្រាមកំហែងដល់សាក្សី [...] វាជាភារកិច្ចរបស់អង្គជំនុំជម្រះក្នុងការបំពេញឲ្យបានប្រុងប្រយ័ត្នបំផុត ដើម្បីធានាឲ្យមានសវនាការមួយប្រកបដោយយុត្តិធម៌" [85]។ ការទប់ទល់ជាមួយនឹងការជ្រៀតជ្រែកបែបនេះ "ជាការសំខាន់នៅពេលមានការកៀបសង្កត់ពីភាគីខាងក្រៅ ដែលចង់ឲ្យរាំងស្ទះដល់លទ្ធភាពក្នុងការផ្តល់ភស្តុតាងរបស់ភាគីនាពេលសវនាការ។ ដូច្នេះ ដើម្បីឲ្យតុលាការបំពេញមុខងារប្រកបដោយប្រសិទ្ធិភាពនោះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែទប់ទល់ចំពោះការគម្រាមកំហែងដល់សាក្សី ដោយត្រូវចាត់វិធានការគ្រប់បែបយ៉ាងទាំងអស់ដែលអាចអនុវត្តបានចំពោះសាក្សីទាំងនោះ [...]"[86]។

---

សាលាដំបូងនៃតុលាការ ICTR សម្រេចថា ដំណោះស្រាយសមរម្យបំផុតចំពោះការរំលោភសិទ្ធិរបស់ជនជាប់ចោទគឺត្រូវផ្អាកនីតិវិធីទាំងអស់ប្រឆាំងនឹង Barayagwiza។ សេចក្តីសម្រេចនេះត្រូវបានច្រានចោលឲ្យពិនិត្យឡើងវិញ តែដោយសារតែដំណោះស្រាយពីមុនត្រូវបានបង្គាប់ឲ្យធ្វើ ដោយផ្អែកលើការខកខានមិនបានបំពេញរបស់ការិយាល័យរដ្ឋអាជ្ញា ហើយអង្គហេតុថ្មីៗត្រូវបាននាំមកបំភ្លឺ ដែលបានលុបបំបាត់នូវតួនាទីនៃការខកខានទាំងនោះ ដែលបណ្តាលឲ្យដំណោះស្រាយមានវិសមមាត្រ *សូមមើល* សំណុំរឿងលេខ "សេចក្តីសម្រេច" (សំណើរបស់រដ្ឋអាជ្ញាសុំពិនិត្យឡើងវិញ ឬពិចារណាសាជាថ្មី) ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០០។ *សូមមើលបន្ថែម រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* សំណុំរឿងលេខ "សេចក្តីសម្រេចកែប្រែជាសាធារណៈ ទៅលើសំណើបន្ទាន់របស់រដ្ឋអាជ្ញា សុំផ្លាស់ប្តូរពេលកំណត់ក្នុងការបង្ហាញអត្តសញ្ញាណរបស់អន្តរការីលេខ 143 ឬត្រូវព្យួរកិច្ចដំណើរការនីតិវិធីដែលនៅសេសសល់" ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ៣១។ នៅក្នុងការករណីនេះ ការព្យួរកិច្ចដំណើរការនីតិវិធីត្រូវបានទទួលយក អាស្រ័យដោយការ *មិនស៊ីសង្វាក់គ្នាផ្អែកសម្ភារៈ* ដោយសារ (i) រដ្ឋអាជ្ញាបដិសេធមិនអនុវត្តតាមដីកាបង្គាប់ដែលចេញដោយអង្គជំនុំជម្រះ និង (ii) "ដោយសារចេតនាច្បាស់លាស់របស់រដ្ឋអាជ្ញា ក្នុងការមិនអនុវត្តតាមដីកាបង្គាប់របស់អង្គជំនុំជម្រះ (...) ប្រសិនបើគាត់យល់ថា ដីកាបង្គាប់ទាំងនោះផ្ទុយពីការបកស្រាយនូវកាតព្វកិច្ចដទៃទៀតរបស់រដ្ឋអាជ្ញា"។

[83] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀងធីរិទ្ធ, កថាខណ្ឌ ២៨។

[84] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ២៨។

[85] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Haradinaj នឹងអ្នកផ្សេងទៀត*, សំណុំរឿងលេខ IT-04-84-A, "សាលដីកា", ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៥។

[86] *ដូចជើងទំព័រខាងលើ*។

29. ពាក់ព័ន្ធនឹងភាពលម្អៀង ទស្សនៈរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះគឺជាការបង្គាប់៖ "ប្រសិនបើមានការជ្រៀតជ្រែកណាមួយ ឬកំពុងមានការជ្រៀតជ្រែក ហើយការជ្រៀតជ្រែកនោះ បង្កការរាំងស្ទះដល់កិច្ចស៊ើបសួរ ជនត្រូវចោទម្នាក់ៗអាចត្រូវបានរារាំងនូវការទទួលបានផលប្រយោជន៍ដែលអាចមាន ដែលអាចទទួលបានពីសក្ខីកម្មរបស់មន្ត្រីទាំងប្រាំមួយរូបនោះ" [87]។

## គ. មោឃភាពដំណើរការនីតិវិធី

30. នៅក្នុងការកំណត់អំពីអ្វីដែលបង្កើតបានជាការរំលោភលើសិទ្ធិជនជាប់ចោទ សម្រាប់គោលបំណងនៃការវិភាគអំពីមោឃៈភាព អង្គបុរេជំនុំជម្រះបានសម្រេចដូចខាងក្រោម៖

> វិធាន ៤៨ នៃវិធានផ្ទៃក្នុងជាភាសាបារាំង ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាជាភាសាខ្មែរ បារាំង និងអង់គ្លេសដែរ (គឺមាត្រា ២៥២ ) មិនបានលើកឡើងអំពីការរំលោភ សិទ្ធិទាំងឡាយឡើយ ប៉ុន្តែបានចែងអំពីផលប្រយោជន៍ ដែលបានប៉ះពាល់។ ដោយធ្វើការពិនិត្យមើលសេចក្ដីណែនាំនៅក្នុង [ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា] [អង្គបុរេជំនុំជម្រះ] និងធ្វើការបកស្រាយថា 'ការរំលោភសិទ្ធិទាំងឡាយ' ជា 'ផលប្រយោជន៍ដែលបានប៉ះពាល់'[88]។
>
> [អង្គបុរេជំនុំជម្រះ] យល់ឃើញថា ការបង្ហាញអំពីការរំលោភសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវ បានទទួលស្គាល់នៅក្នុង ICCPR អាចបង្គ្រប់ជាកំហុសនីតិវិធី ហើយនិងប៉ះពាល់ដល់ផល ប្រយោជន៍របស់ជនត្រូវចោទ។ ក្នុងករណីបែបនេះ កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការ អាចចាត់ ទុកថាមោឃៈ[89]។ [...] នៅក្នុងករណីបទប្បញ្ញត្តិដែលពាក់ព័ន្ធមិនមានចែងអំពីមោឃភាពនៃ កំហុសនីតិវិធី និងក្នុងករណី ICCPR មិនបានទទួលស្គាល់អំពីការរំលោភសិទ្ធិ ភាគីដែលដាក់ពាក្យសុំនឹងត្រូវបង្ហាញថា ផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ដោយសារកំហុសនីតិវិធី[90]។

---

87 មតិទំទាស់ កថាខណ្ឌ១២។

88 សាលដីកាបដិសេធពាក្យសុំមោឃភាព កថាខណ្ឌ៣៦។

89 សាលដីកាបដិសេធពាក្យសុំមោឃភាព កថាខណ្ឌ៤០។

90 សាលដីកា កថាខណ្ឌ៤២។

សរុបមក បទដ្ឋាននៃការទទួលខុសត្រូវដាច់ខាត អនុវត្តចំពោះការរំលោភលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលត្រូវបង្ហាញភស្តុតាង។

## ឃ. សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌

31. យោងតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ព្រមទាំងច្បាប់ និងកិច្ចព្រមព្រៀងបង្កើតអ.វ.ត.ក ជនជាប់ចោទពិតជាទទួលបានសិទ្ធិទទួលបាននូវការស៊ើបអង្កេត និងការជំនុំជម្រះមួយប្រកបដោយយុត្តិធម៌។ ការធានាបែបនេះមានចែងគ្រប់គ្រាន់នៅក្នុងវិធាន២១នៃវិធានផ្ទៃក្នុង ដែលបានបកស្រាយថា៖ (i) ច្បាប់ និងនីតិវិធីជាធរមាន "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនត្រូវចោទ"[91] (ii) "ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ[92]" និង (iii) "បុគ្គលគ្រប់រូប [...] ដែលត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោសដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ"[93]។ នៅគ្រប់ពេលទាំងអស់ អង្គជំនុំជម្រះសាលាដំបូង "ត្រូវស្ថិតក្រោមកាតព្វកិច្ចដើម្បីធានាថាអធិបតេយ្យនៃកិច្ចដំណើរការនីតិវិធីត្រូវបានការពារ" [94]។

## ង. ស្ថាប័នបង្កើតច្បាប់នៅព្រះរាជាណាចក្រកម្ពុជា

32. រដ្ឋធម្មនុញ្ញ ដែលអនុម័តការបែងចែកអំណាចតាមគោលការណ៍ប្រជាធិបតេយ្យ និងបានផ្តល់អំណាចផ្តាច់មុខ[95] ឱ្យស្ថាប័នបង្កើតច្បាប់នៅព្រះរាជាណាចក្រកម្ពុជានូវការទទួលខុសត្រូវ*ផ្តាច់មុខ*របស់រដ្ឋសភា៖ 'រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិបញ្ញត្តិ' អំណាចនេះមិនត្រូវបានផ្ទេរទៅឱ្យអង្គការណាមួយ ឬបុគ្គលណាឡើយ'[96]។ ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ 'ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត' [97]។ ឋានានុក្រមនៃ 'បទដ្ឋានច្បាប់គោល' ដែលមាននៅកម្ពុជា រួមមាន៖ (i) រដ្ឋធម្មនុញ្ញ (ii) ច្បាប់រដ្ឋធម្មនុញ្ញ (រួមមានការកែប្រែ ឬវិសោធនកម្ម

---

[91] វិធាន២១ (១) នៃវិធានផ្ទៃក្នុង (លក្ខខណ្ឌទូទៅ)។

[92] វិធាន២១ (១) (ក)នៃវិធានផ្ទៃក្នុង

[93] វិធាន២១ (១) (ឃ)នៃវិធានផ្ទៃក្នុង។

[94] មតិជំទាស់ កថាខណ្ឌ១០។

[95] *សូមមើល*រដ្ឋធម្មនុញ្ញ មាត្រា៥១ ('អំណាច នីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ត្រូវបែងចែកឱ្យដាច់ស្រឡះ')

[96] រដ្ឋធម្មនុញ្ញ មាត្រា៩០។

[97] រដ្ឋធម្មនុញ្ញ មាត្រា១៣១។

នៃរដ្ឋធម្មនុញ្ញ) (iii) ច្បាប់ (ក្រម) (iv) ក្រឹត្យច្បាប់ (ក្រឹត្យ) (v) អនុក្រឹត្យ (vi) ប្រកាស និង (vii) សារាចរ ជាដើម[98]។

### ច. នីតិវិធីជាធរមាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

33. រដ្ឋធម្មនុញ្ញបានចែងថា៖ 'ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែ*អនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់*[99]' និងការជម្រះក្តីបន្តបន្ទាប់ 'ត្រូវធ្វើ [....] *តាមនីតិវិធី និងច្បាប់ជាធរមាន*[100]'។ និយាយពីអាណត្តិនៃរដ្ឋធម្មនុញ្ញនេះ និងបទបញ្ញត្តិពាក់ព័ន្ធទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[101] ('ICCPR') លិខិតុបករណ៍ជាមូលដ្ឋាននានា បានចែងនូវការធានាដូចគ្នា៖ 'នីតិវិធី' ដែលប្រើនៅ អ.វ.ត.ក '*ត្រូវសមស្របជាមួយច្បាប់កម្ពុជា*' [102] ហើយការចោទប្រកាន់ ការស៊ើបអង្កេត និងការជំនុំជម្រះលើបុគ្គលទាំងឡាយ ត្រូវតែអនុលោមតាម 'នីតិវិធីដែលមានជាធរមាន' [103]។ បទប្បញ្ញត្តិទាំងនេះបង្ហាញពីការព្រួយបារម្ភលើសលប់ ចំពោះការអនុលោមតាមនីតិវិធីផ្សេងៗដែលមាននៅកម្ពុជា -

---

[98] *សូមមើល* ក្រុមប្រឹក្សាអង្គចៅក្រម នៅគេហទំព័រ http://www.bigpond.com.kh/Council_of_Jutists/z/Typolg.htm ។

[99] រដ្ឋធម្មនុញ្ញ មាត្រា៣៨ (បញ្ជាក់បន្ថែម)។

[100] រដ្ឋធម្មនុញ្ញ មាត្រា ១១០ (បញ្ជាក់បន្ថែម)។

[101] *សូមមើល* ICCPR, មាត្រា ១៤(១) ('ក្នុងការកំណត់បទចោទណាមួយទៅលើបុគ្គលម្នាក់នោះ [...] ជនគ្រប់រូបត្រូវមាន [...] សវនាការ [...] ជំនុំជម្រះ *បង្កើតឡើងដោយច្បាប់*), មាត្រា១៤(២) ('ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់*ស្របតាមច្បាប់*។), មាត្រា១៤(៥) ('ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឲ្យសាលាក្តីជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របតាមច្បាប់។'), និងមាត្រា១៦ ('ជនគ្រប់រូប មានសិទ្ធិឲ្យគេទទួលស្គាល់បុគ្គលិកលក្ខណៈ គតិយុត្តិរបស់ខ្លួននៅគ្រប់កន្លែង *នៅចំពោះមុខ ច្បាប់*។')(បញ្ជាក់បន្ថែម)។ *កំណត់សម្គាល់* គ្រប់អង្គជំនុំជម្រះនៃ អ.វ.ត.ក ទាំងអស់ 'ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន ដោយអនុលោមតាមបទដ្ឋានយុត្តិធម៌ ភាពមិនលម្អៀង និងនីតិវិធីត្រឹមត្រូវស្របច្បាប់អន្តរជាតិ ដូចមានចែងនៅក្នុងមាត្រា១៤ និងមាត្រា១៥ នៃ [ICCPR] ឆ្នាំ១៩៦៦ ដែលមានកម្ពុជាជាភាគី'។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(២); *សូមមើលផងដែរ* ច្បាប់ អ.វ.ត.ក មាត្រា៣៥ថ្មី។

[102] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១) (បញ្ជាក់បន្ថែម); *សូមមើលផងដែរ សំណុំរឿងក្តីលេខ* 001/18-07-2007/អវតក/អ.ជ.ស.ជ, ឯកសារលេខ E-188, 'សាលក្រម', ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ERN 00572517-00572797, កថាខណ្ឌ ៣៥។

[103] ច្បាប់ អ.វ.ត.ក មាត្រា២០ថ្មី មាត្រា២៣ថ្មី មាត្រា៣៣ថ្មី (បញ្ជាក់បន្ថែម)។

ក្នុងលក្ខណៈមួយដែលស្របតាមទម្លាប់អន្តរជាតិដែលអាចទទួលយកបាន និងស្របតាមកាតព្វកិច្ច ជាហត្ថលេខីនៃអនុសញ្ញាអន្តរជាតិ របស់ព្រះរាជាណាចក្រកម្ពុជា[104]។

34. ដោយទទួលស្គាល់នូវតម្រូវការក្នុងការធានាថា កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក អនុលោមតាមបទដ្ឋានច្បាប់ដែលទទួលស្គាល់ជាសកលនោះ លិខិតុបករណ៍ជាមូលដ្ឋាន អនុញ្ញាតឲ្យមានការអនុម័តវិធាននីតិវិធីបន្ថែម ក្នុងករណីដូចបានកំណត់ចំនួន៣ គឺចំពោះករណីដែល៖ (i) ច្បាប់ ឬនីតិវិធីជាធរមានរបស់កម្ពុជា 'ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ' (ii) 'មានភាពមិនច្បាស់លាស់ទាក់ទងនឹង''ការបកស្រាយ ឬការអនុវត្ត' បញ្ញត្តិដែលមានស្រាប់ ឬ (iii) 'បញ្ហាពាក់ព័ន្ធនឹង' 'ភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ' [105]។ ក្នុងករណីបែបនេះ - *និងចំពោះតែករណីបែបនេះ* - គេត្រូវស្វែងរក 'ការណែនាំ' 'នៅក្នុងបទដ្ឋាននីតិវិធី ដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ' [106]។ ដូច្នេះ ការទទួលស្គាល់នូវនីតិវិធីថ្មី ឬការអនុវត្តផ្ទុយពី 'នីតិវិធីជាធរមាន' ត្រូវតែកែតម្រូវឲ្យស្របតាមការលើកលែង នៃលក្ខខ័ណ្ឌតិកៈជាក់លាក់ទាំងនេះ។ ការអនុវត្តផ្សេងៗទៀត - ដូចជា ការបង្កើតវិធានថ្មី ដើម្បីគ្រាន់តែភាពងាយស្រួល និងប្រសិទ្ធភាពថែមទៀតនោះ - គឺជាការរំលោភដោយផ្ទាល់លើលក្ខខណ្ឌនៃកិច្ចព្រមព្រៀង អ.វ.ត.ក ត្រង់មាត្រា ១២(១)។

35. លើសពីនេះទៀត ការទទួលស្គាល់ ឬការអនុវត្តផ្ទុយបែបនេះ អាចត្រូវបានអនុវត្ត *ក្នុងករណីពិសេស* ដោយអង្គភាពនានានៃ អ.វ.ត.ក ក្នុងអំឡុងការបំពេញភារកិច្ចរបស់ផ្នែកនីមួយៗតែប៉ុណ្ណោះ។ ពុំមានបទប្បញ្ញត្តិនៅក្នុងលិខិតុបករណ៍ជាមូលដ្ឋាននានា ឬនៅកន្លែងផ្សេងទៀត សម្រាប់ (គឺចង់សំដៅលើ 'កិច្ចប្រជុំពេញអង្គ') បង្កើតស្ថាប័នដែលមានអំណាចក្នុងការតាក់តែងវិធាននៅតុលាការនេះ

---

[104] Lily O'Neill and Göran Sluiter, 'សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍សាលក្រមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា', (ឆ្នាំ២០០៩) លេខ១០ *ទស្សនាវដ្តីច្បាប់អន្តរជាតិ* Melbourne [...]. ('ការបញ្ចូលកិច្ចព្រមព្រៀង អង្គការសហប្រជាជាតិទៅក្នុងច្បាប់កម្ពុជា តាមរយៈច្បាប់បង្កើត អ.វ.ត.ក ត្រូវបានធ្វើឡើងដោយរដ្ឋាភិបាលកម្ពុជា ដើម្បីធានាពីឋានៈគតិយុត្តិរបស់កិច្ចព្រមព្រៀងនៅ អ.វ.ត.ក') (ដកស្រង់ចេញពីស្នាដៃរបស់ Helen Horsington, 'សាលាក្តីខ្មែរក្រហមរបស់កម្ពុជា: ក្តីសង្ឃឹមរបស់តុលាការកូនកាត់' (ឆ្នាំ២០០៤) លេខ៥ *ទស្សនាវដ្តីច្បាប់អន្តរជាតិ* Melbourne 462, 474)។. Göran Sluiter ជាទីប្រឹក្សារបស់ក្រុមមេធាវីការពារ និងជាមាជិក Böhler Advocaten នៅក្រុមហ៊ុនច្បាប់របស់ Pestman and Koppe ។

[105] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា១២(១); ច្បាប់, មាត្រា២០ថ្មី មាត្រា២៣ថ្មី មាត្រា៣៣ថ្មី *សូមមើលផងដែរ* សាលក្រមកថាខណ្ឌ ៣៥។

[106] កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា១២(១); ច្បាប់, មាត្រា២០ថ្មី មាត្រា២៣ថ្មី មាត្រា៣៣ថ្មី *សូមមើលផងដែរ* សាលក្រមកថាខណ្ឌ ៣៥។

ឡើយ[107]។ ពុំដូចជាលិខិតុបករណ៍ដែលស្រដៀងគ្នារបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (‘តុលាការ ICTY’) តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា (‘តុលាការ ICTR’) តុលាការពិសេសសម្រាប់លីបង់ (‘តុលាការ STL’) និងតុលាការ ICC កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនបានចែងអំពីការផ្តល់អំណាចឲ្យបានច្បាស់លាស់ដើម្បីកោះប្រជុំពេញអង្គតាក់តែងវិធានឡើយ[108]។ ដូចជាគណៈកម្មាធិការពិសេសសម្រាប់បទឧក្រិដ្ឋធ្ងន់ធ្ងរ ដែលជាផ្នែកពិសេសនៃតុលាការទីម័រខាងកើត (Dili District Court) អ.វ.ត.ក ស្ថិតនៅក្នុងរចនាសម្ព័ន្ធ

---

[107] *សូមមើល* ច្បាប់ អ.វ.ត.ក មាត្រា២០ថ្មី ២៣ថ្មី និង ៣៣ថ្មី។ *កំណត់សម្គាល់ពិសេស.* អត្ថបទរបស់ Göran Sluiter, មានចំណងជើងថា ‘Due Process and Criminal Procedure in the Cambodian Extraordinary Chambers’, ក្នុងព្រឹត្តិប័ត្រស្រាវជ្រាវឈ្មោះ Journal of International Criminal Justice លេខ 4 (ឆ្នាំ2006), ទំព័រ 314–326, ទំព័រ 320 សរសេរថា (‘ក្របខ័ណ្ឌច្បាប់នាពេលបច្ចុប្បន្ននេះ [របស់ អ.វ.ត.ក] ពុំបានផ្តល់អំណាចឲ្យចៅក្រមដើម្បីតាក់តែងច្បាប់ស្តីពីបញ្ហានីតិវិធីឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានអ្វីរារាំងដល់ចៅក្រមមិនឲ្យធ្វើសេចក្តីសម្រេចលើការបកស្រាយមាត្រា ១២ នៃកិច្ចព្រមព្រៀង នៅមុនការចាប់ ផ្តើមការជំនុំជម្រះឡើយ’)។

[108] *សូមមើល* អត្ថបទស្រាវជ្រាវរបស់ O’Neill & Sluiter, លេខ 27 *យោងខាងលើ* (‘កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងច្បាប់អ.វ.ត.ក ពុំបានចែងអំពីមូលដ្ឋាននៃការអនុម័តវិធានផ្ទៃក្នុងឡើយ’)។ ដូច្នេះ ការប្រៀបធៀបណាមួយរវាងភាពត្រឹមត្រូវតាមច្បាប់នៃការអនុម័តវិធាន និងការអនុវត្តស្មើគ្នានៅតុលាការអន្តរជាតិ ជាការបំភាន់ភ្នែក។ លិខិតុបករណ៍ជាមូលដ្ឋាន របស់តុលាការនីមួយៗនៃតុលាការទាំងនោះ ផ្តល់នូវអំណាចយ៉ាងច្បាស់លាស់សម្រាប់នីតិវិធីតាក់តែងច្បាប់ក្រៅប្រព័ន្ធតុលាការ។ *សូមមើល* លក្ខន្តិកៈតុលាការ ITCY, មាត្រា១៥ (‘ចៅក្រមតុលាការអន្តរជាតិ ត្រូវអនុម័តវិធាន នៃនីតិវិធី និងភស្តុតាងសម្រាប់អនុវត្តន៍ដំណើរការក្តីនៃដំណាក់កាលមុនសវនាការ សវនាការ និងឧទ្ធរណ៍ ការទទួលយកភស្តុតាង ការការពារខ្លួនជនរងគ្រោះនិងសាក្សី និងអង្គហេតុត្រឹមត្រូវផ្សេងៗទៀត’)។ លក្ខន្តិកៈតុលាការ ICTR, មាត្រា១៤ (‘ចៅក្រមតុលាការអន្តរជាតិសម្រាប់ប្រទេស រ្វ៉ាន់ដា ត្រូវអនុម័តវិធាន នៃនីតិវិធី និងភស្តុតាងសម្រាប់អនុវត្តន៍ដំណើរការក្តីនៃដំណាក់កាលមុនសវនាការ សវនាការ និងឧទ្ធរណ៍ ការទទួលយកភស្តុតាង ការការពារខ្លួនជនរងគ្រោះនិងសាក្សី និងអង្គហេតុត្រឹមត្រូវផ្សេងៗទៀតរបស់ តុលាការអន្តរជាតិសម្រាប់អតីតប្រទេស យូហ្គោស្លាវី ដោយមានការផ្លាស់ប្តូរក្នុងករណីចាំបាច់ សម្រាប់គោលបំណងនៃដំណើរការក្តីនៅតុលាការអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា’)។ លក្ខន្តិកៈតុលាការ SCSL មាត្រា១៤ (‘១. វិធាននៃនីតិវិធី និងភស្តុតាងនៃសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដាដែលទទួលបាននៅពេលបង្កើតតុលាការពិសេស ត្រូវអនុវត្តការផ្លាស់ប្តូរបន្តិចបន្តួច លើដំណើរការក្តីនៅចំពោះមុខតុលាការពិសេស។ ២. ចៅក្រមតុលាការពិសេសទាំងអស់អាចធ្វើការកែប្រែវិធាននៃនីតិវិធី និងភស្តុតាង ឬអនុម័តវិធានបន្ថែមក្នុងករណីវិធានដែលត្រូវអនុវត្តនោះ មិនបានចែង ឬចែងមិនគ្រប់គ្រាន់សម្រាប់ស្ថានភាពជាក់លាក់។ ក្នុងករណីនេះ ច្បាប់នៃនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៦៥នៃប្រទេសសៀរ៉ាឡេអូនត្រូវជាមគ្គុទ្ទេសក៍សម្រាប់ចៅក្រមតាមការគួរ’)។ លក្ខន្តិកៈទីក្រុងរូម មាត្រា៥១(៣) (‘ក្នុងករណីនៃការចូលជាធរមានជាប្រញាប់ ដែលមិនមានចែងអំពីស្ថានភាពជាក់លាក់ចំពោះមុខតុលាការ បន្ទាប់ពីការអនុម័តនូវវិធាននៃនីតិវិធីនិងភស្តុតាងនោះដោយមតិភាគច្រើនពីរភាគបី ចៅក្រមអាចបង្កើតឡើងនូវវិធានបណ្តោះអាសន្នដើម្បីអនុវត្តរហូតដល់វិធានបណ្តោះអាសន្ននោះ ត្រូវបានអនុម័ត ត្រូវបានធ្វើវិសោធនកម្ម ឬត្រូវបានបដិសេធចោលនៅក្នុងសម័យប្រជុំពិសេសឬសាមញ្ញ នាពេលបន្ទាប់របស់សន្និបាតនៃរដ្ឋភាគី’)។

តុលាការជាតិ ដូច្នេះហើយត្រូវតែផ្អែកទៅលើច្បាប់ជាធរមាន។ ពុំមានអំណាចក្នុងការតាក់តែងវិធានទូទៅសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ឬដែលមានលក្ខណៈអន្តរជាតិ) ដោយគ្មានមូលដ្ឋានលក្ខន្តិកៈច្បាស់លាស់អំពីអំណាចបែបនេះនោះទេ។

### ង. សមភាពនៅចំពោះមុខច្បាប់

36. យោងទៅលើរដ្ឋធម្មនុញ្ញ ប្រជាពលរដ្ឋខ្មែរ 'មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នា [...] ដោយឥតប្រកាន់ [...] ស្ថានភាពឯទៀតឡើយ'[109]។ ការធានាដូចគ្នានេះដែរមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ICCPR ៖ 'ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី'[110]។

### ឈ. បញ្ហាបន្ថែមទៀត

37. អាស្រ័យដោយកន្លែងសរសេរមានកំណត់[111] សហមេធាវីសូមដាក់បញ្ចូលនូវឯកសារអំណះអំណាងដែលខ្លួនបានលើកឡើងពីពេលមុនលើអង្គច្បាប់ដូចតទៅនេះ៖ (i) ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់[112] (ii) ភាពអាចជឿជាក់ និងតម្លៃជាភស្តុតាង[113] (iii) កាតព្វកិច្ចក្នុងការស្វែងរកភស្តុតាងដោះបន្ទុក[114] (iv) ការផ្ទៀងផ្ទាត់ឡើងវិញភស្តុតាងដាក់បន្ទុក[115] (v) ភាពគ្រប់គ្រាន់នៃភស្តុតាង[116] និង (vi) ឯករាជ្យភាព និងភាពគ្មានលម្អៀងរបស់តុលាការ[117]។ ជាងនេះទៅទៀត ដូចមានបញ្ជាក់ក្នុងចំណុចចុងក្រោយ វាបញ្ជាក់ច្បាស់ថា៖ "ការជ្រៀតជ្រែកចូលក្នុងរដ្ឋបាលតុលាការអាចបង្ហាញពីការមិនគោរពចំពោះឯករាជ្យភាពនៃប្រព័ន្ធតុលាការ" [118]។

## IV. ឧឡឹករណ៍

[109] រដ្ឋធម្មនុញ្ញ មាត្រា៣១។

[110] ICCPR, មាត្រា១៤(១)។

[111] *សូមមើល*លេខ១ *យោងខាងលើ*។

[112] *សូមមើល*សំណើលើកទី១៥ សុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ៦។

[113] *សូមមើល*សំណើលើទី១៩ ស្នើសុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ៥។

[114] *សូមមើល* ឯកសារ D-135/1/1, 'បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំរបស់លោក នួន ជា សុំឱ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស', ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០ , ERN 00456083–00456100, កថាខណ្ឌ ១៤-១៧។

[115] *ដូចជើងទំព័រខាងលើ*។

[116] *សូមមើល*សំណើលើកទី១៩ ស្នើសុំបំពេញកិច្ចស៊ើបសួរ, កថាខណ្ឌ ៥។

[117] *សូមមើល*បណ្តឹងដិតចិត្តចៅក្រម យូ ប៊ុនឡេង កថាខណ្ឌ១២-១៣។

[118] *សូមមើល* បណ្តឹងដិតចិត្តចៅក្រម យូ ប៊ុនឡេង កថាខណ្ឌ ៩។

## ក. អញ្ញត្រកម្មអាចទទួលយកបាន ហើយសហមេធាវីមានចេតនាលើកបញ្ហាទាំងនេះនៅក្នុងសវនាការបឋម

38. ដីកាដំណោះស្រាយ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានចូលជាស្ថាពរនៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១។ ដោយសារអញ្ញត្រកម្មនេះ (ក្នុងទម្រង់ដើម) ត្រូវបានដាក់ជូនក្នុងអំឡុងពេលសាមសិបថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនោះ[119] ហើយពាក់ព័ន្ធនឹង៖ (i) យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង (ii) បញ្ហាដែលតម្រូវឱ្យរំលត់បណ្តឹងអាជ្ញា គឺ៖ ការស៊ើបអង្កេតមិនមានភាពយុត្តិធម៌ និង (iii) សុពលភាពនៃដំណើរការនីតិវិធីបន្ទាប់ពីដាក់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហេតុដូច្នេះ អញ្ញត្រកម្មទាំងនេះអាចទទួលយកបាន ដោយអនុលោមតាមវិធាន ៨៩(១)(ក)-(គ)។

39. យោងតាមវិធាន៨៩ អញ្ញត្រកម្មតម្រូវឱ្យ "លើកឡើង" តែក្នុងរយៈពេលសាមសិបថ្ងៃ នៅក្រោយពេលដែលដីកាដំណោះស្រាយចូលជាស្ថាពរប៉ុណ្ណោះ។ អញ្ញត្រកម្មទាំងនេះ ក្នុងគោលបំណងគោរពតាមលក្ខខណ្ឌតម្រូវនៃវិធាននេះ និងការបង្គាប់នាពេលថ្មីៗនេះរបស់អង្គជំនុំជម្រះនេះ មិនមែនជាសេចក្តីសង្ខេបលម្អិតស្តីពីបញ្ហានានាដែលបានលើកយកបង្ហាញនៅទីនេះនោះទេ។ ប៉ុន្តែ សហមេធាវីមានបំណងលើកឡើងនូវសារណាបន្ថែមលើបញ្ហាទាំងនេះដោយផ្ទាល់មាត់នៅពេលសវនាការបឋម ដែលនៅពេលនោះអង្គជំនុំជម្រះសាលាដំបូងត្រូវតែ "ពិចារណា" ទៅលើអញ្ញត្រកម្ម[120]។

40. បន្ថែមលើនេះទៀត ដោយយោងលើទំហំ និងភាពយឺតយ៉ាវនៃការដាក់ជូននូវ "សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយរបស់ នួន ជា និង អៀង ធីរិទ្ធ"[121] ដែលមាន សំអាងហេតុរបស់ អ.ប.ជ សារណាជាលាយលក្ខណ៍អក្សរបន្ថែមស្តីពីបញ្ហាយុត្តាធិការនានា ដែលបានលើកឡើងនៅទីនេះ អាចនឹងចាំបាច់ដើម្បីឱ្យមានភាពយុត្តិធម៌។

## ខ. ការពន្យារអាជ្ញាយុកាលនៃច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ នឹងរំលោភទៅលើគោលការណ៍នីត្យានុកូលភាព

41. ដោយសារតែអាជ្ញាយុកាលនៃបទល្មើសបានផុតរលត់នៅមុនការពន្យារពេលបន្ថែម ស្របតាម មាត្រា ៣ថ្មីនៃច្បាប់បង្កើត អវតក នោះអង្គជំនុំជម្រះនេះមិនអាចបកស្រាយមាត្រានេះឱ្យសមស្របតាមគោលការណ៍នីត្យានុកូលភាពថា ជាការបង្កើតឡើងវិញនូវសិទ្ធិដើម្បីចោទ ប្រកាន់បទល្មើសនានា

---

[119] *កំណត់សម្គាល់* ពេលវេលាបន្ថែម ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱ្យដើម្បីដាក់ជូនករណីអញ្ញត្រកម្មរួមគ្នាទាំងនេះ។ *សូមមើល*កំណត់សម្គាល់ 1 *ពីខាងលើ*។

[120] *សូមមើល*វិធាន៨០*ស្ទួន* (៣) ("អង្គជំនុំជម្រះត្រូវពិចារណាលើបញ្ហាដែលពាក់ព័ន្ធនឹងវិធាន៨៩")។

[121] ឯកសារលេខ **D-427/2/15** ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ERN 00644462-00644571។

ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦នោះទេ។ ទាក់ទងនឹង បញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងគប្បីប្រកាន់ជំហរពីលើកមុនរបស់ចៅក្រមអន្តរជាតិ[122]។

## គ. ការកាត់ទោស នួន ជា ចំពោះការប្រព្រឹត្តិបទល្មើសអន្តរជាតិដែលមានចែងក្នុងច្បាប់បង្កើត អវតក នឹងរំលោភគោលការណ៍នីត្យានុកូលភាព

### ១. ដោយហេតុថា អ.វ.ត.ក គឺជាសាលាក្តីព្រហ្មទណ្ឌជាតិ ច្បាប់កម្ពុជា រួមទាំងគោលការណ៍នីត្យានុកូលភាពជាតិ ត្រូវអនុវត្តដោយតឹងរឹង

42. អ.វ.ត.ក "ត្រូវបានបង្កើតឡើងដោយច្បាប់ ក្នុងទម្រង់ជាស្ថាប័នយុត្តាធិការ *ដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃតុលាការកម្ពុជា*"[123]។ ខុសពីសាលាក្តី ICTY[124] សាលាក្តី ICTR[125] សាលាក្តី SCSL[126] តុលាការ ICC[127] ដែលសាលាក្តីនីមួយៗមាន "បុគ្គលភាពគតិយុត្តិអន្តរជាតិដោយឡែកៗពីគ្នា"[128] អ.វ.ត.ក ជាចម្បងនោះ គឺជាសាលាក្តីព្រហ្មទណ្ឌជាតិមួយ។ ទោះបីជាមានភាពស្រពិចស្រពិល

---

[122] សូមមើលសេចក្តីស្តីពីអាជ្ញានៃបទល្មើស នៅកថាខណ្ឌទី៩-១៤, ២៧-៣៥, ៣៩-៥៤ ។

[123] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០០ (សេចក្តីបញ្ជាក់បន្ថែម)។

[124] សូមមើល លក្ខន្តិកៈតុលាការ ICTY បុព្វកថា ('ដោយបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ *ដែលប្រតិបត្តិអនុលោមតាមជំពូក VII នៃធម្មនុញ្ញអង្គការសហប្រជាជាតិ* [...]') (សេចក្តីបញ្ជាក់បន្ថែម)។

[125] សូមមើល លក្ខន្តិកៈតុលាការ ICTR បុព្វកថា ('ដោយបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ *ដែលប្រតិបត្តិអនុលោមតាមជំពូក VII នៃធម្មនុញ្ញអង្គការសហប្រជាជាតិ* [...]') (សេចក្តីបញ្ជាក់បន្ថែម)។

[126] សូមមើល កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលប្រទេសសៀរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន បុព្វកថា ('[...] ក្រុមប្រឹក្សាសន្តិសុខបានស្នើឱ្យអគ្គលេខាធិការធ្វើការចចារឱ្យមានកិច្ចព្រម ព្រៀងជាមួយរដ្ឋាភិបាលប្រទេសសៀរ៉ាឡេអូន ដើម្បីបង្កើតតុលាការពិសេស*ឯករាជ្យ*មួយ [...]') (សេចក្តីបញ្ជាក់បន្ថែម) ។ កិច្ចព្រមព្រៀងតុលាការពិសេស, 2002 (Ratification) Act, 2002, ផ្នែក ១១(២) ('តុលាការពិសេសមិនត្រូវបង្កើតឡើងជាផ្នែកនៃប្រព័ន្ធតុលាការប្រទេសសៀរ៉ាឡេអូន ឡើយ')។ ដូចជើងទំព័រខាងលើ ផ្នែក ១៣ ('បទល្មើសដែលត្រូវផ្តន្ទាទោសនៅចំពោះមុខតុលាការពិសេស មិនត្រូវបានផ្តន្ទាទោសក្នុងនាមសាធារណៈរដ្ឋសៀរ៉ាឡេអូន ឡើយ')។

[127] សូមមើល លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៤(១) (' [តុលាការICC] ត្រូវមាននីតិបុគ្គលអន្តរជាតិ')។

[128] Goran Sluiter "ជំនួយផ្នែកច្បាប់ចំពោះតុលាការ និងសាលាជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិ" ('Legal Assistance to Internationalized Criminal Courts and Tribunals'), នៅក្នុង CPR Romano, PA. Nollkaemper, & J.K. Kleffner (eds) តុលាការព្រហ្មទណ្ឌជាអន្តរជាតិ៖ ប្រទេសសេរ៉ា ឡេអូន ប្រទេសទីម័រខាងកើត ខេត្តកូសូវ៉ូ និងប្រទេសកម្ពុជា (INTERNATIONALIZED CRIMINAL COURTS: SIERRA LEONE, EAST TIMOR, KOSOVO AND CAMBODIA) (Oxford 2004), ទំព័រ 396 (កត់សម្គាល់ថា តុលាការ SCSL មាន 'នីតិបុគ្គលអន្តរជាតិ ហើយមិនមែនជាផ្នែក នៃប្រព័ន្ធតុលាការជាតិក្នុងប្រទេសសៀរ៉ាឡេអូន ឡើយ')។

លើបញ្ហានេះ ដោយសារតែលក្ខណៈនៃការិយាល័យ និងអង្គជំនុំជម្រះរបស់សាលាក្តីនេះក៏ដោយ[129] កត្តាមួយចំនួនបានបញ្ជាក់យ៉ាងច្បាស់ថា អ.វ.ត.ក សាលាក្តីជាតិ៖

ក. អ.វ.ត.ក បានបង្កើតឡើងដោយច្បាប់ជាតិ (មិនមែនច្បាប់អន្តរជាតិ)ឡើយ[130]។

ខ. អ.វ.ត.ក "ត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធនៃតុលាការកម្ពុជាដែលមានស្រាប់"[131] ។

គ. រាជរដ្ឋាភិបាលកម្ពុជាបានបដិសេធយ៉ាងច្បាស់លើគោលគំនិតចង់បង្កើតសាលាក្តីអន្តរជាតិមួយ[132]។

ឃ. មន្ត្រីតុលាការរបស់ អ.វ.ត.ក ទាំងអស់ត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ដោយ អ.ស.ប គ្រាន់តែផ្តល់បញ្ជីស្នើបេក្ខជនអន្តរជាតិតែប៉ុណ្ណោះ[133]។

ង. ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានគូសបញ្ជាក់ថា អ.វ.ត.ក ស្ថិតនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ គឺវាការពារអធិបតេយ្យកម្ពុជា[134]។

ច. នៅក្នុងសេចក្តីសម្រេចមួយដែលចេញនាពេលមុន ទោះបីជា អ.ប.ជ បានសម្រេចថា អ.វ.ត.ក "មានលក្ខណៈដោយឡែកពីតុលាការជាតិដទៃៗទៀតនៅក្នុងទឹកដីរដ្ឋភាពមួយចំនួន" អ.ប.ជ បានរកឃើញថា អ.វ.ត.ក ដំណើរការងាររបស់ខ្លួនជា "ស្ថាប័នឯករាជ្យមួយ *នៅក្នុងរចនាសម្ព័ន្ធនៃតុលាការ កម្ពុជា*[135]"។

ឆ. ទោះបីជា (នៅក្នុងករណីលើកលែងមួយចំនួន) គេត្រូវពិនិត្យមើលវិធាននីតិវិធីដែលបានបង្កើតឡើងនៅក្នុងក្របខណ្ឌអន្តរជាតិក៏ដោយ[136] ចំណុចចាប់ផ្តើមនៅ អ.វ.ត.ក ជានិច្ចជាកាល គឺ "នីតិវិធី និងច្បាប់កម្ពុជាដែលមានស្រាប់"[137] ។

---

[129] សូមមើល ឧទាហរណ៍ សាលដីកាស្តីពី JCE កថាខណ្ឌ ៤៧។

[130] សូមមើល ច្បាប់ស្តីពី អ.វ.ត.ក និងកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក ។

[131] ច្បាប់ស្តីពី អ.វ.ត.ក មាត្រា ២។

[132] សូមមើល របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការជំនុំជម្រះទោសខ្មែរក្រហម ឯកសាររបស់អង្គការសហប្រជាជាតិ លេខ A/57/769 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ ៦-៧។

[133] សេចក្តីសម្រេចក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ លេខ 040/002/2001 ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ទំព័រ ៣។

[134] ដូចដើងទំព័រខាងលើ ទំព័រ ៤។

[135] សំណុំរឿង លេខ ០០១/១៨-០៧-២០០៧-អវតក/កសចស ឯកសារលេខ C-5/45 'សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ ១៧-១៩ (សេចក្តីបញ្ជាក់បន្ថែម)។

[136] សូមមើលកិច្ចព្រមព្រៀង នៅមាត្រា ១២(១), ច្បាប់ អវតក នៅមាត្រា ២០ថ្មី, ២៣ថ្មី និង៣៣ថ្មី ។

[137] ការទទួលស្គាល់តម្រូវការដើម្បីធានាថា ដំណើរការនីតិវិធីរបស់ អ.វ.ត.ក ប្រកាន់ខ្ជាប់ទៅនឹងបទដ្ឋានគតិយុត្តិដែលត្រូវបានទទួលស្គាល់ជាសកល លិខិតុបករណ៍ជាមូលដ្ឋានអនុញ្ញាតឲ្យមានការអនុម័តបទដ្ឋាននីតិវិធីបន្ថែមនៅក្នុងករណីកំណត់ ចំនួនបីពោលគឺនៅពេលដែល ៖ (i) ច្បាប់កម្ពុជា ឬនីតិវិធីដែលមានស្រាប់ 'ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេស ណាមួយ' (ii) 'មានភាពមិនច្បាស់លាស់ទាក់ទងនឹង' 'ការបកស្រាយ ឬការអនុវត្ត' បទប្បញ្ញត្តិជាធរមាន ឬ (iii) 'មានបញ្ហាទាក់ទងទៅនឹង' 'ភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ'។ កិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក មាត្រា ១២(១)។ ច្បាប់ស្តីពី អ.វ.ត.ក មាត្រា ២០ថ្មី, មាត្រា ២៣ថ្មី, មាត្រា ៣៣ថ្មី។ នៅក្នុងករណីបែបនេះ និងនៅក្នុងតែករណីបែបនេះប៉ុណ្ណោះ គេអាចស្វែងរក 'ការណែនាំ' ក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ'។ ដូចដើងទំព័រខាងលើ។ ដូច្នេះ ការទទួលស្គាល់នីតិវិធីថ្មី

43. ការបន្តយោងទៅលើ អវតក ថាជា "ស្ថាប័នអន្តរជាតុនីយកម្ម"[138] គឺគ្រាន់តែជាពិពណ៌នាដោយគ្មានអានុភាពផ្លូវច្បាប់ទេ។ ហើយករណីដែលថាយុត្តាធិការលើរឿងក្តីបានពង្រីករហូតដល់បទល្មើសអន្តរជាតិ ឬថាចៅក្រមមួយចំនួនរបស់ អ.វ.ត.ក មិនមែនជាចៅក្រមជាតិនោះ វាមិនបានប្រែក្លាយ អ.វ.ត.ក ឱ្យទៅជាតុលាការអន្តរជាតិវិញនោះទេ[139]។ តាមពិតទៅ ឈ្មោះរបស់សាលាក្តីនេះ គឺអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបញ្ជាក់ករណីនេះដោយស្វ័យប្រវត្តិទៅហើយ[140]។

44. ហេតុដូច្នេះ វាជាគោលការណ៍នីត្យានុកូលភាពរបស់*កម្ពុជា* ដោយសារតែគោលការណ៍នេះមានអត្ថិភាពនៅចន្លោះឆ្នាំ១៩៧៥ លើឆ្នាំ១៩៧៩ ដែលត្រូវតែអនុវត្ត[141]។ គោលការណ៍នោះមានចែងយ៉ាងច្បាស់បំផុតនៅមាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលពុំមានចែងពីការលើកលែង ដូចជាគោលការណ៍ដែលមានចែងនៅក្នុងមាត្រា ១៥(២) នៃ ICCPR ។ សេចក្តីយោងចំពោះ "ច្បាប់" នៅក្នុងមាត្រាខាងលើ អាចត្រូវបកស្រាយថាជា *ច្បាប់នៅ ជាធរមាននៅប្រទេស កម្ពុជានៅពេលវេលាដែលពាក់ព័ន្ធ* ។

---

ឬការងាកចេញពី 'នីតិវិធីជាធរមាន' អាចត្រូវបានធ្វើ យុត្តិកម្មដោយយោងទៅលើករណីលើកលែងផ្លូវច្បាប់ជាក់លាក់មួយក្នុងចំណោមករណីលើកលែងផ្លូវច្បាប់ជាក់លាក់ទាំង នេះតែប៉ុណ្ណោះ។

[138] *សូមមើល* ឯកសារ **D-427/3/6**, 'ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ', ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០, ERN 00626531–00626650 ('ចម្លើយតបរបស់ ក.ស.ព'), កថាខណ្ឌទី១៣៨ ។

[139] កត់សម្គាល់៖ តុលាការជាតិ ជាទម្លាប់ អនុវត្តច្បាប់អន្តរជាតិ (ស្ថិតនៅក្រោមភាពម៉ឺងម៉ាត់នៃគោលការណ៍នីត្យានុកូលភាពជាតិរបស់តុលាការទាំងនោះ)។ ហើយវាមិនមែនចំឡែកទេសម្រាប់តុលាការជាតិដែលមានចៅក្រមអន្តរជាតិនោះ ជាពិសេសនៅក្នុងបណ្តារដ្ឋជាសមាជិកនៃក្រុមប្រទេស Commonwealth ។

[140] សូម្បីតែ "វិសាមញ្ញ" មួយ, អវតក នៅក្នុងការវិភាគចុងក្រោយ គឺជាតុលាការកម្ពុជា ។ តាមពិតសាលាក្តីនេះមានតួនាទីដែលមានតែមួយ នៅក្នុងប្រព័ន្ធច្បាប់ជាតិ តែវានៅតែ (ព្រមជាមួយតុលាការធម្មតាដទៃទៀតរបស់កម្ពុជា) ផ្នែកមួយយ៉ាងសំខាន់នៃប្រព័ន្ធនោះ ។ ភាពសខុសប្លែកគ្នាដែលបានបញ្ជាក់កាលពីលើកមុនដោយ កសព (នៅកថាខណ្ឌទី១៣៧-១៤២ នៃចម្លើយតបរបស់ខ្លួន) សង្កត់ធ្ងន់ពីលក្ខណៈពិសេសរបស់សាលាក្តីនេះ ប៉ុន្តែ សហព្រះរាជអាជ្ញាមិនបានផ្តល់យុត្តិកម្មតុលាការនេះជាកម្មសិទ្ធិរបស់គោលការណ៍ដែលបានបង្កើតឡើងនៅកម្រិតជាតិ ដែលទទួលបានការការពារតិចជាងគោលការណ៍ដែលបង្កើតនៅកម្រិតអន្តរជាតិ ។

[141] *សូមមើល* A CASSESE_(Ed), THE OXFORD COMPANION TO INTERNATIONAL CRIMINAL JUSTICE (Oxford 2009), p 438 (គោលការណ៍នីត្យានុកូលភាពទាមទារថា មនុស្សម្នាក់អាចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោស ប្រសិនបើនៅពេលគាត់ប្រព្រឹត្តអំពើជាក់លាក់ អំពើនោះត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ដោយបទប្បញ្ញត្តិច្បាប់) (បញ្ជាក់បន្ថែម) ។

## ២. ច្បាប់ព្រហ្មទណ្ឌជាតិនៅពេលហេតុការណ៍ដែលបានចោទប្រកាន់បានកើតឡើង មិនបានចែងកំណត់បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬ បទឧក្រិដ្ឋកម្មសង្គ្រាម ជាបទល្មើសព្រហ្មទណ្ឌឡើយ

45. ដូចដែលបានកត់សម្គាល់ខាងលើ របបច្បាប់ជាតិជាធរមាននៅពេលហេតុការណ៍ដែលបាន ចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ បានកើតឡើង មិនបានកំណត់បទល្មើសទាំងឡាយ ដូចមានចែងចាប់ពីមាត្រា ៤ ដល់ មាត្រា ៦ នៃច្បាប់ អ.វ.ត.ក ថាជាបទល្មើសព្រហ្មទណ្ឌឡើយ។ ដោយកុំគិតពីឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ ១៩៧៩ នោះប្រព័ន្ធទ្វិកនិយមរបស់ប្រទេសកម្ពុជា ហាមឃាត់មិនឱ្យយកនិយាមអន្តរជាតិបែបនេះ (ដែលអាច ឬ មិនអាចមានអត្ថិភាពនាពេលនោះ) មកអនុវត្តដោយផ្ទាល់នៅក្នុងអំឡុងពេលតែមួយនោះ។ លើសពីនេះទៀត ច្បាប់អនុវត្តចំពោះបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋកម្មសង្គ្រាម មិនត្រូវបានគេអនុម័តនៅមុន ឬនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ អាស្រ័យហេតុនេះ បទល្មើសអន្តរជាតិទាំងនេះ "*មិនអាចអនុវត្តបាននៅក្នុងអំឡុពេលដែលពាក់ព័ន្ធនោះទេ*"[142] ។

46. ហេតុដូច្នេះ អំណះអំណាងដែលបានលើកឡើងថា "បញ្ហាដែលចោទឡើងថាតើច្បាប់អន្តរជាតិអាច ឬ មិនអាចអនុវត្តដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជា នឹងមិនមានបង្កើតជាផលវិបាកអ្វីចំពោះសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក នោះឡើយ"[143] គឺជាការភ័ន្តច្រឡំ។ ដោយហេតុថាច្បាប់ជាតិមិនបានចែងកំណត់ជាចាំបាច់ថាទង្វើភាគច្រើនដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយជាបទល្មើសព្រហ្មទណ្ឌ មូលដ្ឋានមួយទៀតតែមួយគត់នោះគឺការអនុវត្តច្បាប់អន្តរជាតិ។ ប៉ុន្តែ ដូចមានហេតុផលលើកឡើងនៅក្នុងកថាខណ្ឌមុនៗ ច្បាប់អន្តរជាតិទាំងនេះមិនអាចអនុវត្តបាននៅក្នុង

[142] សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០២ ('ដើម្បីអាចឱ្យអំពើមួយត្រូវចាត់ចូលជាបទល្មើសនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ខណៈដែលអំពើនោះមិនត្រូវបានចាត់ជាបទល្មើសនៅក្នុងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិក្នុងពេល ដែលអំពើនោះកើតឡើងនោះទេ នោះច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវចែងអំពីបទល្មើសនៃអំពើនោះដោយច្បាស់លាស់ឬដោយតុណ្ហីភាព ហើយអំពើនោះក៏ត្រូវតែជាបទល្មើសនៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិ *ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជានៅខណៈពេលដែលអំពើនោះកើតឡើង*ផងដែរ') (សេចក្តីបញ្ជាក់បន្ថែម)។ កត់សម្គាល់៖ គោលជំហររបស់ ស.ច.ស ទាក់ទិននឹងបញ្ហានេះ គឺត្រឹមត្រូវតាមគតិយុត្តិ។

[143] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៤។

ប្រទេសកម្ពុជានាចន្លោះឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៩ទេ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនដែលជាផ្នែកមួយនៃប្រព័ន្ធច្បាប់ជាតិដោយផ្ទាល់នោះទេ[144]។

47. ដូចគ្នានេះដែរ សំណើរបស់ ក.ស.ច.ស ថា នួន ជា អាចបានដឹងដោយទូលំទូលាយ អំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម ពីព្រោះ នួន ជា ត្រូវបានចោទប្រកាន់ថាជាសមាជិកមួយរូបនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា[145] មិនសមស្របឡើយ។ ទោះបី នួន ជា មានប្រភពនៃច្បាប់អន្តរជាតិលើបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង/ឬ បទឧក្រិដ្ឋកម្មសង្គ្រាម នាពេលនោះក៏ដោយ "ច្បាប់" បែបនេះ មិនមានអានុភាពចងកាតព្វកិច្ចលើ នួន ជា អនុលោមតាមប្រព័ន្ធច្បាប់ជាតិកម្ពុជា"។ ហេតុដូច្នេះ ករណីដែលគោលការណ៍នីត្យានុកូលភាព (ដែល ស.ច.ស យកមកធ្វើជាមូលដ្ឋាននោះ) នឹងមិនរំលោភលើការចោទប្រកាន់ នួន ជា ចំពោះបទល្មើសអន្តរជាតិ គឺមិនសមស្របទេ។

48. ទាក់ទងនឹងចំណុចនេះ សេចក្តីសម្រេចដែលមានសារៈប្រយោជន៍នោះ គឺសេចក្តីសម្រេចរបស់តុលាការ *Tribunal Supremo* នៃប្រទេសអេស្ប៉ាញនៅក្នុងរឿងក្តី *Scilingo*[146]។ នៅសវនាការជំនុំជម្រះ *Audiencia Nacional* ផ្តន្ទាទោសជនជាប់ចោទចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវដាក់បញ្ចូលក្នុងច្បាប់ប្រទេសអេស្ប៉ាញនៅឆ្នាំ២០០៤។ អំពើល្មើសដែលត្រូវបានចោទប្រកាន់បានកើតឡើងនៅចន្លោះឆ្នាំ១៩៧៦ និងឆ្នាំ១៩៨១ នៅមុនបទល្មើសនេះត្រូវបានចាត់ជាបទល្មើសជាតិទៅទៀត។ នៅពេលឧទ្ធរណ៍ ការសង្កត់ធ្ងន់ទៅលើប្រព័ន្ធច្បាប់អេស្ប៉ាញដែលមានចរិតលក្ខណៈជាប្រព័ន្ធទ្វីបនិយម[147] និងការសំអាងលើគោលការណ៍នីត្យានុកូលភាពរបស់ប្រទេស

---

[144] សហព្រះរាជអាជ្ញាបានអះអាងដោយការជឿជាក់ថា "គេមិនអាចអះអាងថាការចូលរួមការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត រំលោភលើរំលោភលើផ្លូវភេទ ការធ្វើឱ្យទៅជាទាសករ ការសម្លាប់រង្គាល ឬការឃុំខ្លួន ដោយខុសច្បាប់ ការធ្វើទារុណកម្ម និងការសម្លាប់ឈ្លើយសឹកសង្គ្រាម មិនមែនជាអំពើល្មើស *នៅក្នុងប្រព័ន្ធច្បាប់សំខាន់ៗ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ* ។ ចម្លើយតបរបស់ កសព នៅត្រង់កថាខណ្ឌទី១៦៤ (បញ្ជាក់បន្ថែម) ។ វាអាចជារឿងពិតដែរ ។ តែគេមិនអាចអះអាងថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រល័យនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្ម សង្គ្រាម ដែលមានកំណត់និយមន័យក្នុងច្បាប់បង្កើត អវតក ត្រូវបានកំណត់ជាបទល្មើសនៅក្នុងអំឡុងពេលដូចគ្នា ។

[145] សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៥-១៣០៧។

[146] សូមមើល *Tribunal Supremo, Sala de lo Penal, Segunda Sentencia, Sentencia No* 798/2007, *Recurso Casacion (P) No* 10049/2006 P (សេចក្តីសម្រេច *Scilingo*) ។

[147] សេចក្តីសម្រេច *Scilingo Sexto*, § 4, នៅកថាខណ្ឌទី១ ។

អេស្បាញ[148] តុលាការបានសម្រេចថា *Scilingo* មិនត្រូវបានផ្តន្ទាទោស ដោយអនុលោមតាមក្រមតាមសហកាលទេ ដោយសារ (i) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ជាតិមិនទាន់ដាក់បញ្ចូលឲ្យទៅជាច្បាប់ក្នុងច្បាប់ប្រទេសអេស្បាញ នៅពេលប្រព្រឹត្តបទល្មើស ដែលត្រូវចោទប្រកាន់នោះទេ និង(ii) ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចអនុវត្តដោយផ្ទាល់បានដែរ[149]។ ជាចុងក្រោយ តុលាការកាត់ទោសជនជាប់ចោទចំពោះបទល្មើសជាតិ ដូចជា ការធ្វើមនុស្សឃាត និងការឃុំខ្លួនខុសច្បាប់[150]។ នួន ជា មិនអាចត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មអន្តរជាតិ ដែលមិនមែនជាផ្នែកនៃប្រព័ន្ធច្បាប់កម្ពុជា នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្តឡើយ[151] ។

## ៣. ច្បាប់ អ.វ.ត.ក មិនចែងកំណត់ថា បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬ បទឧក្រិដ្ឋកម្មសង្គ្រាម ជាបទល្មើសព្រហ្មទណ្ឌឡើយ

49. សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ច្បាប់ អវតក ខ្លួនឯងបានចាត់ជាបទល្មើសនៅប្រទេសកម្ពុជានូវឧក្រិដ្ឋកម្មនានាដែលត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ[152]។ វាមិន មែនដូច្នេះនោះទេ។ ច្បាប់ អ.វ.ត.ក គ្រាន់តែផ្តល់យុត្តាធិការដល់សាលាក្តីលើបទល្មើសទាំងឡាយដូចមានចែងចាប់ពីមាត្រា ៣ (ថ្មី) ដល់មាត្រា ៦។ ចំណុចនេះបង្ហាញឃើញច្បាស់តាមរយៈឃ្លោងឃ្លានៃបទប្បញ្ញត្តិទាំងនេះ ដែលគ្រាន់តែអនុញ្ញាតឱ្យ អ.វ.ត.ក "នាំមកកាត់សេចក្តី" ចំពោះជនជាប់ចោទពីបទបទល្មើសជាតិ បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម។ ដោយសរសេរព្រាងយុត្តាធិការនៅក្នុងភាសាមួយក្នុងលក្ខណៈកម្រិត មាត្រា

[148] សេចក្តីសម្រេច *Scilingo Sexto*, § 4, នៅកថាខណ្ឌទី១ "*Tribunal Supremo* ក៏បានពិភាក្សាបទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (មាត្រា ៧) និងសង្កត់ធ្ងន់ថាអនុសញ្ញានេះអនុញ្ញាតឲ្យរដ្ឋជាភាគីជំរុញការអនុវត្តការ ការពារនៅក្នុងនីតិវិធីនៅចំពោះមុខតុលាការជាតិ ។ ដូចខាងលើ នៅកថាខណ្ឌទី២។ ក៏ដូចគ្នានឹង ICCPR ដែរ ។ សូមមើល កថាខណ្ឌទី៩ ខែបណ្តឹងនេះ ។

[149] សេចក្តីសម្រេច *Scilingo Sexto*, §1, នៅកថាខណ្ឌទី១, §4 នៅកថាខណ្ឌទី៥ ។

[150] តុលាការថែមទាំងបានទទួលស្គាល់ថាអំពើជាក់លាក់ដែលជាកម្មវត្ថុនៃបណ្តឹងអាជ្ញា ជាឧក្រិដ្ឋកម្មប្រឆាំងនឹង មនុស្សជាតិក្រោមច្បាប់អន្តរជាតិ ដែលអាចទុកថាពាក់ព័ន្ធដើម្បីអនុវត្តយុត្តាធិការលំអង្គហេតុនេះ ។ សូមមើលសេចក្តីសម្រេច *Scilingo Septimo, Octavo* ។ សម្រាប់ការពិភាក្សាជាភាសាអង់គ្លេសនៃករណីនេះ សូមមើល Beth Van Schaack, *Crimen Sine Lege: Judicial Lawmaking at the Intersection of Law and Morals*, 97 GEORGETOWN LAW JOURNAL 119, 163–165

[151] សូមមើល *Mpambara* សេចក្តីបន្ទាន់បង្គំ, តុលាការស្រុកទីក្រុងឡាអេ ចុះនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នៅកថាខណ្ឌទី៣៦ ដល់៤៤ (ក្នុងចំណោមបញ្ហាដទៃទៀត សេចក្តីសម្រេចបានសំអាងលើសាលដីកាក្នុងករណី *Bouterse* របស់តុលាការកំពូលប្រទេសហូឡង់ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០០១ ។

[152] សូមមើលកថាខណ្ឌទី១៣០៥-១៣០៧ នៃដីកាដំណោះស្រាយ ។

ទាំងនេះមិនផ្តល់អានុភាពជាបទល្មើសព្រហ្មទណ្ឌ[153] អនុលោមតាមច្បាប់សារធាតុ ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ឡើយ។

50. គោលការណ៍នីត្យានុកូលភាពខ្លួនឯងបានបែងចែកពីភាពខុសគ្នាយ៉ាងខ្លាំងរវាងយុត្តាធិការ និងមូលដ្ឋាននៃបទល្មើសព្រហ្មទណ្ឌ អនុលោមតាមច្បាប់សារធាតុ[154]។ បើទោះជាការប្រែប្រួលជាអានុភាពប្រតិសកម្មនៃលក្ខខណ្ឌនៃការចោទប្រកាន់ ដែលមិនមែនសម្រាប់ការកំណត់បទល្មើសព្រហ្មទណ្ឌ (ឧទាហរណ៍ បទបញ្ញត្តិស្តីពីនីតិវិធី ឬយុត្តាធិការ) ជាទូទៅ គឺមិនស្ថិតនៅក្រោមគោលការណ៍នីត្យានុកូលភាព[155] ការប្រែប្រួល*ក្រោយព្រឹត្តហេតុ* ចំពោះច្បាប់សារជាតិ គឺស្ថិតនៅក្រោមគោលការណ៍នេះ[156]។ ភាពខុសគ្នានេះ វាមិនសមហេតុផលទេក្នុងការទាញការសន្និដ្ឋានបទល្មើសព្រហ្មទណ្ឌចេញពីយុត្តាធិការ ។ និយាយឱ្យងាយទៅ វិសាលភាពនៃបទល្មើសព្រហ្មទណ្ឌរវាងការប្រព្រឹត្តិបទល្មើសដែលបានចោទប្រកាន់ និងការចោទប្រកាន់នាពេលក្រោយនោះ មិនគួរត្រូវបានគេពង្រីកឡើយ[157]។ លើសពីនេះទៅទៀត សញ្ញាណដែលលើកឡើងថា បទបញ្ញត្តិស្តីពីយុត្តាធិការចែងកំណត់ដោយតុណ្ហីភាពថា បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងប្រទេសកម្ពុជា ជាបទល្មើសព្រហ្មទណ្ឌនោះ សញ្ញាណនេះប៉ះពាល់លើលក្ខខណ្ឌនៃភាពអាចប្រមើលមើលឃើញ និងភាពអាចដឹងយ៉ាងទូលំទូលាយថាមានច្បាប់ចែងនៃគោលការណ៍នីត្យានុកូលភាព។

---

[153] សូមមើល ការជំទាស់លើយុត្តាធិការ លេខយោង៥៩ខាងលើ អំពីការញែករវាងយុត្តិការដើម្បីបង្កាប់ និងយុត្តិការបង្ខំ។

[154] *ដូចលេខយោងខាងលើ។*

[155] *សូមមើល* ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Delalic និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-21-A, 'សាលក្រមt', ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១, កថាខណ្ឌ១៧៩-១៨០; *cf រឿងក្តី Streletz, Kessler, & Krenz តទល់នឹង Germany*, ECtHR សំណុំរឿងលេខ 34044/96 & 35532/97 & 44801/98, "សាលក្រម", ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០១, កថាខណ្ឌ៧៩-៨១; សាលក្រមខុច កថាខណ្ឌ៣៤។

[156] *សូមមើល* RA KOK, STATUTORY LIMITATIONS IN INTERNATIONAL CRIMINAL LAW (Asser 2001), ទំព័រ ២៩១-២៩២។

[157] *សូមមើល* FERDINANDUSSE, លេខយោង៣៥ខាងលើ, ទំព័រ ២២៣។ សូមមើល ផងដែរ [តុលាការធម្មនុញ្ញប្រទេសប៊ែលហ្ស៊ិក Erdal ទល់នឹង ក្រុមប្រឹក្សារដ្ឋមន្ត្រី សេចក្តីសម្រេចរបស់តុលាការធម្មនុញ្ញ លេខ 73/2005; ILDC 9 (BE 2005) par. B7 (សម្រេចថា គោលការណ៍នៃ អានុភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមានឥទ្ធិពលទៅលើការពង្រីកវិសាលភាពតាមទីកន្លែង (*ratione loci*) នៃបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌដែលមានពីមុនស្រាប់៖ ច្បាប់ដែលពង្រីក វិសាល ភាព តាមទីកន្លែង (*ratione loci*) នៃបទឧក្រិដ្ឋ ដែលមានចែងរួចហើយនៅក្នុងក្រមព្រហ្មទណ្ឌ (ប្រទេសប៊ែលហ្ស៊ិក) ('ក្រមព្រហ្មទណ្ឌ') គឺជាច្បាប់សារធាតុ ដែលច្បាប់ទាំងនោះបានបង្កើតនូវមូលដ្ឋានគតិយុត្តិ សម្រាប់ការចោទប្រកាន់នៅ ក្នុងប្រទេសប៊ែលហ្ស៊ិក។ ដូច្នេះ ច្បាប់ទាំងនោះ មិនអាច យកមកអនុវត្តជាប្រតិសកម្មបានឡើយ)]។

51. ទោះជាអ្នកពង្រាងច្បាប់ អវតក មានចេតនា [ដោយគ្មានមន្ទិលសង្ស័យ] ផ្ដល់អំណាចឲ្យអវតក ប្រើយុត្តាធិការលើ [...] លើបទល្មើសអន្តរជាតិ[158] ក៏ការអនុញ្ញាតឲ្យសាលាក្ដីនេះប្រើយុត្តាធិការលើបទល្មើសទាំងនេះ ដោយគ្មានការធ្វើឲ្យទៅជាបទល្មើសនៅក្នុងច្បាប់ជាតិឲ្យបានច្បាស់លាស់ក៏ដោយ នឹងរំលោភលើការធានានៃការជំនុំជម្រះក្ដីដោយយុត្តិធម៌[159] ។

### *៤. គោលការណ៍នីត្យានុកូលភាពអន្តរជាតិ មិនចែងកំណត់អំពីបទល្មើសព្រហ្មទណ្ឌជាតិ*

52. ទោះបីវាគិតគូរអំពីការចោទប្រកាន់នៅក្នុងស្រុកលើបទល្មើសអន្តរជាតិនៅក្នុងករណីមួយចំនួនក៏ដោយ គោលការណ៍នីត្យានុកូលភាពអន្តរជាតិ ទោះបីវាមានអត្ថិភាពក៏ដោយ ក៏មិនអាចបញ្ចូលបទល្មើសព្រហ្មទណ្ឌ អនុលោមតាមច្បាប់សារធាតុ ចូលទៅក្នុងប្រព័ន្ធច្បាប់ជាតិដែលមានស្រាប់នោះឡើយ។ ដូចតាមរយៈភស្តុតាងនៃការអនុវត្តរបស់រដ្ឋដែលបានពិភាក្សាមុនៗ គោលការណ៍ *មិនមានបទល្មើស*អន្តរជាតិ ស្ថិតនៅក្រោមចំណុះអធិបតេយ្យជាតិ (រួមទាំងគោលការណ៍នីត្យានុកូលភាពរបស់ប្រទេសកម្ពុជាខ្លួនឯងផងដែរ)។ ការលើកគោលការណ៍នេះឡើង (មិនថាមានចេតនាល្អបែបណាឡើយនោះ[160]) តាមនិយាម មិនមានអានុភាពលើច្បាប់ជាតិឡើយ ប្រសិនបើច្បាប់ជាតិ

---

[158] សូមមើលចម្លើយតបរបស់ កសព នៅកថាខណ្ឌទី ១៣៥ ។

[159] ដូចខាងលើ ។ ផ្ទុយពីជំហររបស់ កសព តាមពិតវាមាន "បុរេលក្ខខណ្ឌបន្ថែមទៀត" ទាក់ទងនឹងការអនុវត្តច្បាប់អន្តរជាតិទាំងនេះ ។ ចម្លើយតបរបស់ កសព នៅកថាខណ្ឌទី១៣៥ ។ ដូចបានកត់សំគាល់រួចហើយ បានកំណត់ជាក់លាក់ឲ្យទៅបទល្មើសដោយច្បាប់ជាតិ ចំពោះអំពើនានាដែលជាចំណោទនេះ គឺជាបុរេលក្ខខណ្ឌដើម្បីអនុវត្តគោលការណ៍ព្រហ្មទណ្ឌ អន្តរជាតិនៅក្នុងប្រព័ន្ធច្បាប់ជាតិ ។ តាមពិត កសព បានយល់ព្រមជាមួយមេធាវីការពារក្ដីនៅពេលថ្លែងថា ច្បាប់ អវតក ផ្ដល់ឲ្យ អវតក តែយុត្តាធិការទាក់ទងនឹងអំពើដែលមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ និងអាចផ្ដន្ទាទោស នៅពេលដែលអំពើនោះបានកើតឡើង ប៉ុណ្ណោះ ។

[160] សូមមើល សាលដីកាស្ដីពី JCE កថាខណ្ឌ ៤៧ (អង្គបុរេជំនុំជម្រះយល់ឃើញថា ឋានៈរបស់ អ.វ.ត.ក 'មិនមានផលប៉ះពាល់លើដីកាដែលត្រូវបានជំទាស់ ដែលសម្រេចថា [ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] អាចអនុវត្តបានចំពោះមុខ អ.វ.ត.ក។ វាពិតជាមិនមានផលប៉ះពាល់មែន នៅពេលពិចារណាពាក្យច្បាស់លាស់នៃមាត្រា១ និងមាត្រា២ នៃច្បាប់ អ.វ.ត.ក ដែលគោលបំណងនៃច្បាប់នេះ គឺដើម្បីកាត់សេចក្ដីមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុស ត្រូវខ្ពស់បំផុតចំពោះ [...] ការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញា អន្តរជាតិនិងទំនៀមទម្លាប់អន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជា [...]។ នៅក្នុងករណីនេះ ច្បាប់អ.វ.ត.ក ក៏ចែងយ៉ាងច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញត្រូវតែបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ក្នុងគោល បំណងនេះ')។ កត់សម្គាល់៖ ចំពោះហេតុផលដែលបានពិភាក្សាដោយសង្ខេបនេះ បំណងប្រាថ្នា និងគោលបំណងតែមួយគត់ដើម្បី 'កាត់សេចក្ដី' ចារីដែលត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មអន្តរជាតិ គឺជាយុត្តិកម្មមិនគ្រប់គ្រាន់ សម្រាប់ការ កំណត់ (ដោយមានគោលបំណង) ថាជាបទល្មើសព្រហ្មទណ្ឌជាតិ។ អំណះអំណាងរបស់ អ.ប.ជ នៅក្នុងករណីនេះផ្ដល់ជាយោបល់ថា ឆន្ទៈនយោបាយបច្ចុប្បន្ននេះ គួរតែមានសារសំខាន់ជាងគោលការណ៍ច្បាប់ដែលបានកំណត់។

មិនបានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ។ ហេតុដូច្នេះ មាត្រា ៣៣(២)នៃច្បាប់ អ.វ.ត.ក ដែលចែងយោងលើមាត្រា១៥នៃកតិកាសញ្ញាអន្តរជាតិ មិនបានធ្វើឱ្យបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋកម្មសង្គ្រាម ក្លាយជាបទល្មើសព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាឡើយ ពីព្រោះតែបទល្មើសអន្តរជាតិទាំងនេះមិនអាចអនុវត្តបានឡើយនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។

53. "មូលហេតុក្នុងការចាកចេញពីសេចក្ដីសម្រេច [លើកមុន] ដែលបានបញ្ជាក់ពីយុត្តាធិការរបស់ អវតក លើច្បាប់អន្តរជាតិ"[161] គឺជាការសង្កត់បញ្ជាក់ដោយមិនត្រឹមត្រូវទៅលើគោលការណ៍នីត្យានុកូលភាពអន្តរជាតិ។ ការលើកមកសំអាងម្ដងទៀតនៃមាត្រា ១៥ នៃ ICCPR[162] បានខកខានមិនបានពិចារណាលើបទប្បញ្ញត្តិដទៃទៀតនៃកតិកាសញ្ញាតែមួយ គឺបទប្បញ្ញត្តិដែល "រក្សានូវភាពមិនអាចរំលោភបាននៃច្បាប់ទាំងឡាយដែលផ្ដល់ការការពារកម្រិតខ្ពស់ដល់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាងបទប្បញ្ញត្តិផ្សេងៗនៅក្នុង ICCPR"[163] ។ មាត្រា ៥(២) នៃ ICCPR (ដែលអាចអនុវត្តចំពោះនីតិវិធីនេះតាមរយៈស្មារតីនៃរដ្ឋធម្មនុញ្ញកម្ពុជា[164]) ហាមឃាត់ចំណុចនេះ ឬតុលាការជាតិពីការធ្វើបដិប្បញ្ញត្តិគោលការណ៍នីត្យានុកូលភាពយ៉ាងតឹងរឹងរបស់កម្ពុជាដែលមិនមានការលើកលែង ដែលខុសពីមាត្រា ១៥ នៃ ICCPR ។ ហេតុដូច្នេះ អង្គហេតុដែលថាការអនុវត្តប្រព័ន្ធអន្តរជាតិ ដែលបង្កើតដោយច្បាប់ អវតក នឹងមិនរំលោភ មាត្រា ១៥ គឺមិនមានការពាក់ព័ន្ធទេ[165]។

---

[161] សូមមើលចម្លើយតប នៅកថាខណ្ឌទី១៣៦ (ដែលបានលើកមកសំអាងឯកសារ D97/16/10, សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត លើសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ERN 00486521–00486589 នៅកថាខណ្ឌទី៤៥, ៤៧-៤៨,៦៩, ៨៩ ។ ករណី 001, ឯកសារ E118 "សាលក្រម" ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០ ERN 00572517–00572797,នៅកថាខណ្ឌទី៣០ ។ ឯកសារ C-22/1/74 "សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន អៀង សារី" ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ , ERN 00232976–00233004,នៅកថាខណ្ឌទី ១២-១៣ ។

[162] សូមមើលចម្លើយតប នៅកថាខណ្ឌទី១៤៥-១៤៦, ១៦០-១៦៤ ។

[163] ឯកសារ **D427/1/6**, បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ 00617486–00617631 ("បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី") (សំអាង M Novak, អនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, (ប្រែសម្រួលលើកទី២) ទំព័រ ១១៨ (NP Engel 2005))។

[164] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ (ចែងថាព្រះរាជាណាចក្រកម្ពុជាត្រូវទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញាទាក់ទងនឹងសិទ្ធិមនុស្ស [...]" ។

[165] កត់សំគាល់: នេះគឺជាការពិត ដោយមិនគិតដល់មាត្រា ៥(២) ។ មាត្រា ១៥ មិនបាន (មិនអាច) ធ្វើឲ្យទៅជាបទល្មើសទេ តែគ្រាន់កំណត់បទដ្ឋានជាអប្បបរមាដែលអាចអនុវត្តចំពោះច្បាប់ជាតិ ។ ស្របពេលជាមួយគ្នានេះវាបន្សល់ទុកនូវឱកាសដើម្បីការបង្កើនការ

## ៥. ការកំណត់បទល្មើសព្រហ្មទណ្ឌដោយអានុភាពប្រតិសកម្ម រំលោភលើគោលការណ៍នីត្យានុកូលភាពជាតិ

54. ក្នុងគោលបំណងបង្ហាញទឡ្ហីករណ៍ យើងសន្មតថា អង្គជំនុំជម្រះនេះជឿថា ច្បាប់ អ.វ.ត.ក បាន កំណត់បទល្មើសទាំងឡាយដូចមានចែងចាប់ពីមាត្រា ៤ ដល់ មាត្រា ៦ ថាជាបទល្មើស ព្រហ្មទណ្ឌ ច្បាប់ធ្វើឡើងតាមអានុភាពប្រតិសកម្មបែបនេះរំលោភលើគោលការណ៍នីត្យានុកូលភាពរបស់ ប្រទេសកម្ពុជា[166]។ ការធ្វើឱ្យទៅជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើកើតមុននៅក្នុងប្រព័ន្ធច្បាប់ មួយ ខកខានបំពេញលក្ខខណ្ឌនៃភាពអាចប្រមើលមើលឃើញថាមានគោលការណ៍ *មិនមានបទល្មើស*ជាតិ។ តាមទឡ្ហីករណ៍ បើទោះជាអាញ្ញត្រកម្មចំពោះគោលការណ៍នីត្យានុកូលភាព អន្តរជាតិ (កតិកាសញ្ញាអន្តរជាតិ មាត្រា ១៥(២)) អាចអនុវត្តទៅបាន ប្រសិនបើ អ.វ.ត.ក គឺជា សាលាក្តីអន្តរជាតិមួយ ដូចសាលាក្តី ICTY សាលាក្តី SCSL វាជាហេតុផលមិនត្រឹមត្រូវដែល លើកឡើងថា នួន ជា អាចទំនងមើលឃើញអំពីបទល្មើសព្រហ្មទណ្ឌ ដោយផ្អែកលើមូលដ្ឋាន ច្បាប់ អន្តរជាតិនៅក្នុងតុលាការជាតិកម្ពុជា។ និយាយមួយបែបទៀតនោះគឺ វាពិបាកយល់ថាតើបុគ្គលមួយ រូបដែលដំណើរការងារក្នុងប្រព័ន្ធទ្វិកនិយមនៅក្នុងប្រទេស ដែលទទួលការការពារតាមគោលការណ៍ *មិនមានបទល្មើស* យ៉ាងរឹងមាំង អាច (ឬ គួរ) យល់ឃើញថា ការការពារបែបនេះនឹងត្រូវបានគេដក ហូតចេញវិញនាថ្ងៃណាមួយ ជាពិសេសតាមរយៈដំណើរការដាក់ទណ្ឌកម្មតាមច្បាប់អន្តរជាតិ ដែល អះអាងថាប្រកាន់ខ្ជាប់ និងលើកកំពស់នីតិរដ្ឋនោះ។

---

ការពារកាន់តែច្រើន ដូចការការពារ ដែលផ្តល់ដោយមាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។ ដោយពិចារណាលើកត្តាទាំងនេះ ព្រមជាមួយ និយមន័យច្បាស់នៃគោលការណ៍នីត្យានុកូលភាព មាត្រា ១៥ សន្មតយ៉ាងពិតប្រាកដនៃការធ្វើឱ្យទៅជាបទល្មើសជាតិ ។

[166] សូមមើលករណី O'Keefe, លេខយោង៥៩ ខាងលើ, នៅទំព័រ៧៤៣ ("ការអនុវត្តន៍យុត្តាធិការបញ្ញត្តិដោយផ្អែកលើមូលដ្ឋាននៃទំនាក់ទំនងផ្នែកយុត្តាធិការដែលបានបង្កើតនូវការទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើស គឺជាទម្រង់មួយនៃការដាក់ទោសព្រហ្មទណ្ឌដែលមានប្រតិសកម្ម ដូច្នេះអ្វីដែលមិនអាចទទួលយកបាននោះ គឺដោយសារតែបំរាមផ្នែកព្រហ្មទណ្ឌថ្នាក់ជាតិលើអង្គសេចក្តី និងការដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្ត ហើយវាក៏មិនមែនគ្រាន់តែជាសមត្ថកិច្ចដែលទាក់ទងនឹងនីតិវិធីថ្នាក់ជាតិប៉ុណ្ណោះទេ ពោលគឺទម្រង់នៃការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌបែបនេះ អាចយកទៅអនុវត្តលើជនជាប់ចោទបានបន្ទាប់តែពីមានការប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ។ [...] ការអនុវត្តយុត្តាធិការបញ្ញត្តិរបស់រដ្ឋមួយដោយផ្អែកទៅលើទំនាក់ទំនងផ្នែកយុត្តាធិការ មិនត្រូវបានបំពេញឡើយ រហូតបន្ទាប់ពីមានការប្រព្រឹត្តបទល្មើស មានន័យថា ក្នុងខណៈពេលដែលកំពុងប្រព្រឹត្តបទល្មើសនោះ ជនល្មើស មិនត្រូវបានហាមឃាត់ដោយច្បាប់របស់រដ្ឋនោះទេ ដូច្នេះហើយការចោទប្រកាន់ និងការដាក់ទណ្ឌកម្មជាបន្តបន្ទាប់ប្រឆាំងអ្នកប្រព្រឹត្តដោយផ្អែកតែលើច្បាប់របស់រដ្ឋដែលមានលក្ខណៈមិនច្បាស់លាស់នោះ គឺវាបំពានទៅនឹងគោលការណ៍នីត្យានុកូលភាព")។

55. ជំហរដែលថ្លែងពីលើកមុនថា ច្បាប់ អវតក "មិនមែនជាច្បាប់ដែលមានអានុភាពជាប្រតិសកម្ម"[167] គឺជាការភាន់ច្រឡំ។ តាមការជាក់ស្តែង ការអនុវត្តយុត្តាធិការរបស់តុលាការនឹងបង្កើតឱ្យមានការទទួលផលវិបាកផ្នែកព្រហ្មទណ្ឌតាមប្រតិសកម្មនៃច្បាប់ ដែលនាំឱ្យរំលោភបំពានយ៉ាងច្បាស់លើបទប្បញ្ញត្តិនៃមាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។ សរុប សេចក្តីមក នួន ជា នឹងប្រឈមការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ដែលពុំមែនជាបទល្មើសដែលត្រូវផ្តន្ទាទោសនៅប្រទេសនេះនៅមុនការអនុម័តច្បាប់បង្កើត អវតក ឡើយ។ ទោះជាវាអាចលើកស្ទួយគោលបំណងយុត្តិធម៌របស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[168] ក៏វាជាការអនុវត្តផ្ទុយនឹងគោលការណ៍នីត្យានុកូលភាពដែរ។

56. ប្រសិនបើគោលការណ៍នីត្យានុកូលភាព "សំខាន់បំផុតនោះ គឺជា "គោលការណ៍យុត្តិធម៌មួយ"[169] គោលការណ៍នេះមិនគួរត្រូវបានគេយកមកប្រើប្រាស់ដើម្បីបម្រើការងារសម្រាប់ជារបៀបវារៈនៃរបបអាណានិគមថ្មី ដែលជម្រុញដោយច្បាប់អន្តរជាតិនោះឡើយ ដែលរបៀបវារៈនៃរបបនេះគឺចង់បន្ថយអានុភាពនៃសិទ្ធិរបស់បុគ្គលតាមអានុភាពប្រតិសកម្មនៅក្នុងក្របខណ្ឌជាតិ។ ភាពតានតឹងដែលបានង្កើតឡើងដោយភាពខុសគ្នារវាងវិធីសាស្ត្រជាតិ និងអន្តរជាតិចំពោះគោលការណ៍ *មិនមានបទល្មើស*នោះ ត្រូវតែលុបបំបាត់ចោល អនុលោមតាមគោលការណ៍*វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ។* ក្រៅពីរំលោភសិទ្ធិរបស់ នួន ជា នៅក្នុងរដ្ឋធម្មនុញ្ញ ក្នុងការទទួលបានការចោទប្រកាន់ "ឱ្យស្របតាមច្បាប់" ការអនុញ្ញាតឱ្យគោលការណ៍នីត្យានុកូលភាពអន្តរជាតិមកជាន់លើច្បាប់ជាតិដែលផ្តល់ការការពារជាងនោះ នឹងប៉ះពាល់ដល់អធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា[170]។

## ឃ. ការស៊ើបអង្កេតរបស់តុលាការលើសំណុំរឿង០០២

---

[167] ចម្លើយតប នៅកថាខណ្ឌទី១៦៦ ។

[168] សូមមើល Cassese នៅអក្សរក្នុងលេខយោងទី២៥ នៅទំព័រទី៤៣៨-៤៣៩ ។

[169] សេចក្តីសម្រេចលើរឿងក្តី Milutinovic, IT-99-37-AR72, កថាខណ្ឌ ៣៧ (ដកស្រង់ តុលាការយោធាអន្តរជាតិនៅណ្យូរ៉ែមប៊ើក) ។

[170] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ (សេចក្តីសម្រេចលេខ ០៤០/០០២/២០០១) គឺមិនពាក់ព័ន្ធទេ ដោយសារវាដាក់កម្រិតត្រឹមតែធម្មនុញ្ញភាពនៃការពន្យារអាជ្ញាយុកាលនៃបទល្មើសរបស់ច្បាប់ អវតក ចំពោះតែបទល្មើសជាតិ និងបទល្មើសដទៃទៀត ដែលមិនជាប់ពាក់ព័ន្ធនឹងការអនុវត្តនៅកម្រិតជាតិនៃបទល្មើស ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនបានពិចារណាលើអានុភាពរបស់គោលការណ៍នីត្យា នុកូលភាពកម្ពុជា ទាក់ទងនឹងបទប្បញ្ញត្តិព្រហ្មទណ្ឌអន្តរជាតិ ដែលមានចែងនៅក្នុងមាត្រា ៤-៦ នៃច្បាប់ អវតក ឡើយ ។ តាមឧត្តមគតិរបស់ខ្លួន ក្រុមប្រឹក្សាធម្មនុញ្ញប្រហែលជាបានទទួលស្គាល់យ៉ាងត្រឹមត្រូវថាយុត្តាធិការរបស់ អវតក មិនអាចធ្វើឱ្យជាបទល្មើស តាមប្រតិសកម្មនៃច្បាប់នៅក្នុងអង្គជំនុំជម្រះរបស់កម្ពុជា ។

## មានទិការ: និងបង្ហាញឲ្យឃើញពីភាពអយុត្តិធម៌

*១. ការជ្រៀតជ្រែកដោយខុសច្បាប់ពីសំណាក់រដ្ឋាភិបាល បានរាំងស្ទះដល់ការប្រមូលភស្តុតាងសំខាន់ៗ*

57. ដូចបានរៀបរាប់ពីខាងលើ រាជរដ្ឋាភិបាលបានជ្រៀតជ្រែកក្នុងសកម្មភាពផ្សេងៗរបស់ អ.វ.ត.ក ជាច្រើនលើកច្រើនគ្រា។ សហមេធាវីបានព្យាយាមជំទាស់នឹងការជ្រៀតជ្រែកទាំងនេះតាមគ្រប់មធ្យោបាយដែលមាន។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលនៃការខិតខំប្រឹងប្រែងរួមគ្នានោះបានក្លាយជាអាសារបង់ ដោយសារៈ ការប៉ុនប៉ងរបស់សហមេធាវីត្រូវបានច្រានចោលដោយសំអាងហេតុដែលមិនគួរឲ្យជឿ និងមិនប្រក្រតី។ នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល ចៅក្រមនិងសហព្រះរាជអាជ្ញាកម្ពុជាបានអនុវត្តដោយស្របតាមជំហររបស់រាជរដ្ឋាភិបាល ដែលធ្វើឲ្យបង្អាក់ដោយប្រសិទ្ធិភាពចំពោះរាល់ការព្យាយាមរបស់សហមេធាវី ក្នុងការកែតម្រូវបញ្ហាដ៏ធ្ងន់ធ្ងរនេះ។ ថ្វីត្បិតតែមានការគាំទ្រអង្គហេតុជាច្រើន គ្មានការស៊ើបអង្កេតណាមួយត្រូវបានធ្វើឡើងឡើយ ហើយក៏គ្មានបុគ្គល ឬស្ថាប័នណាត្រូវបានគេដាក់ទណ្ឌកម្មដែរ ហើយសូម្បីតែការព្រមានណាមួយនោះក៏គ្មានដែរ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ អង្គហេតុទាំងនេះមានភាពច្បាស់លាស់៖ ការជ្រៀតជ្រែកផ្នែកនយោបាយនេះមានភាពច្បាស់ក្រឡែត និងតាមការសន្មតរបស់មេធាវីការពារក្តីកំពុងតែបន្ត[171]។ មិនមែនជាការប៉ាន់ស្មានទេ (ដូចគ្នាដែរចំពោះផលប៉ះពាល់នៃអំពើពុករលួយ) នួនជា *ត្រូវបាន* "រារាំងមិនឲ្យទទួលយកនូវអត្ថប្រយោជន៍ដែលអាចមានទាំងប៉ុន្មាន ដែលអាចលេចចេញពីសក្ខីកម្មរបស់មន្ត្រីទាំងប្រាំមួយរូបនោះ"[172]ឡើយ។ ការជ្រៀតជ្រែកបែបនេះពិតជាបាន "បង្អាក់ដល់ការស៊ើបអង្កេតតុលាការ" [173]។

*២. ការស៊ើបអង្កេតដែលមានភាពលម្អៀង និងមានវិការ:*

*បណ្តាលឲ្យមានការរំលោភបំពានលើនីតិវិធី និងអង្គសេចក្តីសំខាន់ៗ*

---

[171] *កំណត់សម្គាល់ពិសេស៖* មេធាវីការពារក្តីត្រឹមតែអាចជំទាស់អំពើឧទាហរណ៍នានានៃការជ្រៀតជ្រែករបស់រដ្ឋាភិបាល *ពីអ្វីដែលខ្លួនបានដឹង*តែប៉ុណ្ណោះ។ ដោយពុំចាំបាច់រៀបរាប់វែងឆ្ងាយនោះ ការជ្រៀតជ្រែកដោយខុសច្បាប់ភាគច្រើន កើតឡើងឆ្ងាយពីការមើលឃើញរបស់សាធារណជនទៅទៀត។ គេមិនបានដឹងពីមូលហេតុដែលធ្វើឲ្យសាក្សីមួយចំនួនត្រូវបានកំណត់មកផ្តល់ចម្លើយ ថាតើអាចមានការជ្រៀតជ្រែកពីរដ្ឋាភិបាលនៅក្នុងដំណើរការជ្រើសរើសឬទេ ហើយថាតើ រាជរដ្ឋាភិបាលកម្ពុជាមានឱកាសប្រើឥទ្ធិពលទៅលើចម្លើយជាសារវ័ន្ត ជាមុនឬទេ។ ដោយពិចារណាឃើញថា រាជរដ្ឋាភិបាលមិនចូលលូកលាន់ជាចំហទៅក្នុងកិច្ចការរបស់តុលាការ មានហេតុផលណាដែលជឿថា រដ្ឋាភិបាលមានឆន្ទះ និងជំរុញឲ្យមានការប្រើប្រាស់ឥទ្ធិពលមកលើតុលាការ តាមវិធីបិទបាំង។

[172] សេចក្តីសម្រេច អបជ លើសំណើសុំកោះហៅសាក្សី កថាខណ្ឌ ១២។

[173] *ដូចជើងទំព័រខាងលើ។*

58. វិការៈដ៏ធ្ងន់ធ្ងរបានរារាំងមិនឱ្យការស៊ើបអង្កេតរបស់តុលាការអាចចាប់ផ្តើមបាន។ អ្វីដែលជាបញ្ហាធំបំផុតនោះប្រហែលជាវិធីសាស្ត្រដែលមានភាពលម្អៀងក្នុងការស៊ើបអង្កេតនេះ។ និន្នាការនេះត្រូវបានបង្ហាញឱ្យឃើញច្បាស់តាមរយៈការបដិសេធជាប្រចាំរបស់ ក.ស.ច.ស ចំពោះសំណើសុំឱ្យបើកកិច្ចស៊ើបសួររបស់សហមេធាវី។ ស្ទើរតែគ្រប់សំណើទាំងអស់ ទោះបីជាមានសំអាងហេតុគ្រប់គ្រាន់ និងរៀបចំឡើងក្នុងគោលបំណងធ្វើឱ្យកិច្ចស៊ើបសួរនេះជាប្រយោជន៍ដល់ នួន ជា ក៏ដោយ ក៏ត្រូវបានបដិសេធយ៉ាងលឿន ដោយជាញឹកញាប់ការបដិសេធនេះមានសំអាងហេតុផ្លូវច្បាប់ប្រកបដោយភាពមន្ទិល។ ហើយនៅពេលដែល អ.ប.ជ ចេញដីកាឱ្យ ស.ច.ស ពិចារណាឡើងវិញនូវការបដិសេធរបស់ខ្លួន ជាញឹកញាប់នោះ លទ្ធផលនៃការពិចារណាឡើងវិញនោះ គឺ *បន្ត* ការបដិសេធជួយជ្រោមជ្រែងដល់សហមេធាវី។ ជាការពិត ក.ស.ច.ស បានច្រានចោលជាប្រចាំចំពោះសំណើសុំឱ្យបើកកិច្ចស៊ើបសួរដោយសំអាងលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះមួយក្នុងរយៈកាលមួយសមស្របរបស់ នួន ជា ដើម្បីបិទកិច្ចស៊ើបសួរជាប្រញាប់ នៅមុនថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២00៩ គឺដើម្បីបន្តការឃុំខ្លួនជាបណ្តោះអាសន្នរបស់ នួន ជា តែប៉ុណ្ណោះ។ ទោះបីជាមានតួនាទីជាភ្នាក់ងារស៊ើបអង្កេតជួសមុខឱ្យរាល់ភាគី វាច្បាស់ណាស់ថា ស.ច.ស មិនមានចំណាប់អារម្មណ៍ក្នុងការបើកកិច្ចស៊ើបសួរដោយត្រូវពិចារណាពីស្ថានភាពនៃបរិបទពាក់ព័ន្ធ ឬឱ្យតម្លៃដល់ការស្វែងរកឱ្យបានខ្លាំងក្លានូវភស្តុតាងដោះបន្ទុកឡើយ។ ផ្ទុយទៅវិញ ក.ស.ច.ស បានកំណត់កិច្ចការរបស់ខ្លួនត្រឹមតែស្វែងរកសម្ភារៈគាំទ្រដល់ការចោទប្រកាន់នានាដែលមាននៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ ក.ស.ព តែប៉ុណ្ណោះ។ ជាក់ស្តែង ចៅក្រម Lemonde ផ្ទាល់បានដើរហួសឆ្ងាយពីតួនាទីនេះដោយបញ្ជាក់ពីជំហរនេះជាមួយនឹងមន្ត្រីជាន់ខ្ពស់របស់លោក[174]។

59. អ្វីដែលបន្ថែមទៅនឹងភាពលម្អៀងរបស់ ក.ស.ច.ស គឺកង្វះខាតតម្លាភាពដែលបានកើតមាននៅក្នុងការស៊ើបអង្កេតទាំងមូល។ ភាគីទាំងឡាយមិនធ្លាប់ដែលទទួលការជូនដំណឹងអ្វីទាល់តែសោះអំពីសំអាងហេតុជាមូលដ្ឋានក្នុងការធ្វើ (ឬមិនធ្វើ ដែលកត់មានជាញឹកញាប់) ការបើកកិច្ចស៊ើបសួរជាក់លាក់នានា។ ពាក់ព័ន្ធនឹងបញ្ហានេះ ស.ច.ស តែងបានលើកឡើងដដែលៗពីតម្រូវការនៃភាពសម្ងាត់នៃវិជ្ជាជីវៈ។ ប៉ុន្តែ វិធីសាស្ត្រដែលត្រូវមានការសម្ងាត់ហួសហេតុនេះ ដែលជាការពិតចាំបាច់ត្រូវអនុវត្តជាមួយសាធារណជន គឺជាការមិនចាំបាច់ត្រូវអនុវត្ត និងមិនបំរើផលប្រយោជន៍ដល់ *បណ្តាភាគី* ដែលគួរតែទទួលបានការអនុញ្ញាតឱ្យត្រួតពិនិត្យ និងដេញដោលទាំងលើការប្រព្រឹត្ត និងខ្លឹមសារនៃកិច្ចការរបស់ ក.ស.ច.ស ក្នុងដំណើរការទាំងមូល។ ការសម្ងាត់បែបនេះ ដែលជាបញ្ហា

---

[174] *សូមមើល* កថាខណ្ឌ ១៩, *ដូចកថាខណ្ឌខាងលើ*។

នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលមានវិធានការការពារនីតិវិធីដ៏រឹងមាំ បានបង្កជាបញ្ហាច្រើននៅក្នុងបរិបទជាក់ស្តែងរបស់កម្ពុជា។ សហមេធាវីគ្មានមធ្យោបាយនឹងអាចដឹងបានទេ ថាតើវិធីសាស្ត្រស៊ើបអង្កេតដោះបន្ទុកសំខាន់ៗមិនត្រូវបានអនុវត្តដោយសារតែមានការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលឬយ៉ាងណានោះ។ ដូចបានលើកឡើងពីខាងលើ សហមេធាវីព្យាយាមពិនិត្យ លើចម្លើយសាក្សី ប្រភពដើមឯកសារ និងសង្វាក់នៃការរក្សាភស្តុតាងចាប់តាំងពីឆ្នាំ១៩៧៩ ត្រូវបានធ្វើឲ្យខកខានដោយសារតែការសម្ងាត់នៃកិច្ចស៊ើបសួរ។

60. ដោយសារតែកង្វះខាតតម្លាភាពនៃវិធីសាស្ត្ររបស់ ស.ច.ស សហមេធាវីត្រូវដេញដោលពីគុណភាពលទ្ធផលការងារជាក់ស្តែងរបស់ ក.ស.ច.ស ដែលនោះគឺចម្លើយសាក្សី។ ដូចបានកត់សម្គាល់រួចមក ហើយនៅក្នុងសំណើស្នើឲ្យបើកកិច្ចស៊ើបសួររបស់សហមេធាវី កំណត់ទាំងនេះទទួលរងនូវវិការៈផ្នែកគុណវិស័យយ៉ាងធ្ងន់ធ្ងរ។ ជាពិសេស មន្ត្រីស៊ើបអង្កេត ក.ស.ច.ស៖ តែងតែខកខានមិនបានបញ្ជាក់ឲ្យគ្រប់គ្រាន់ពីប្រភពនៃការដឹងឮ ខ្វះការប្រុងប្រយ័ត្នអំពីការគម្រាមកំហែងនៃ "ចម្លើយមានភាពលម្អៀង" របស់សាក្សីដែលអាចកើតមាននៅក្នុងរយៈកាលក្រោយឆ្នាំ១៩៧៩ ព្រមទាំងជាញឹកញាប់ខកខានក្នុងការតាមដានចំពោះតម្រុយដោះបន្ទុក *បឋម* ឬភាពមិនស៊ីសង្វាក់គ្នានៅក្នុងការដំណើររឿងដាក់បន្ទុក។ បើទោះជាវត្តមានរបស់សហមេធាវីនៅក្នុងកិច្ចសម្ភាសន៍អាចប៉ះពាល់ដល់ចម្លើយដាក់បន្ទុក ឬធ្វើមានតុល្យភាពចំពោះចម្លើយដោះបន្ទុក ភាគីទាំងឡាយត្រូវបានរារាំងមិនឲ្យចូលរួមក្នុងដំណើរនេះទេ។ លើសពីនេះទៀត ដូចបានកត់សម្គាល់រួចមកហើយ ការព្យាយាមរបស់ សហមេធាវីក្នុងការកែលម្អគុណភាពមិនល្អនៃកិច្ចសម្ភាសន៍ទាំងនេះ តាមរយៈការដាក់ជូននូវសំណើស្នើឲ្យបើកកិច្ចស៊ើបសួរក្នុងគោលដៅស្តាប់ចម្លើយសាក្សីមួយចំនួនឡើងវិញ ផ្តល់នូវការគាំទ្រ និង/ឬមិនយល់ព្រមលើចម្លើយនោះ ព្រមទាំងលាតត្រដាងនូវសាក្សី និងតម្រុយផ្សេងៗបន្ថែមទៀត ស្ទើរតែទាំងអស់ត្រូវបានបដិសេធចោល។

61. ដោយសារតែវិធីសាស្ត្ររួមរបស់ ក.ស.ច.ស នួន ជា ត្រូវបាន "រារាំងមិនឲ្យទទួលយកនូវអត្ថប្រយោជន៍អាចទទួលបានដែលអាចកើតចេញពី" ការស្វែងរកភស្តុតាងជួសមុខឲ្យខ្លួនគាត់ផ្ទាល់[175]។ ការបង្ហាញឲ្យឃើញនូវភាពលម្អៀង កង្វះខាតនូវតម្លាភាព និងវិធីសាស្ត្រដែលមានមន្ទិលរបស់ ស.ច.សនេះ បាន "បង្អាក់ដល់កិច្ចស៊ើបអង្កេតតុលាការ"[176] ដែលធ្វើឲ្យខូចប្រយោជន៍ដល់ ជនជាប់ចោទ។

---

[175] មតិជំទាស់ កថាខណ្ឌ១២។

[176] *ដូចជើងទំព័រខាងលើ*។

## ខ. វិការៈជាសត្យានុម័តបែបនេះ ដោយវិការៈ នីមួយៗ និងលើសពីនេះទៀត (*fortiori*) នៅពេលពិចារណាលើវិការៈទាំងអស់ជារួម បានបង្កឲ្យមានព្យសនកម្មដែលមិនអាចជួសជុលបានដល់សិទ្ធិរបស់ នួន ជា ក្រោមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិជាធរមាន

62. នៅពេលដែលសំណុំរឿងក្តីប្រឆាំង នួន ជា បានឈានដល់ដំណាក់កាលជំនុំជម្រះ មានតែពេលនេះទេដែលអាចធ្វើការពិចារណានូវអ្វីដែលបាន (និងមិនបាន) ធ្វើឡើងនៅក្នុងដំណើរការស៊ើបអង្កេត។ ដោយពិចារណាទៅលើវិការៈជាច្រើនដូចបានលើកឡើងពីខាងលើ សេចក្តីសន្និដ្ឋានតែមួយគត់ដែលអាចទាញបាននោះគឺថា ជនជាប់ចោទមិនអាចទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌មួយនៅចំពោះមុខអង្គជំនុំជម្រះនេះទេ។ ទោះបីជាវាអាចទៅរួចនៅក្នុង *ទ្រឹស្តី* ថា ការរំលោភបំពានមួយចំនួនលការជំនុំជម្រះយុត្តិធម៌មួយចំនួន អាចនឹងជួសជុលសងបានតាមរយៈតុលាការជំនុំជម្រះដែលមានលក្ខណៈនយោបាយ និងជាក់ស្តែងក្នុងការធ្វើការជួសជុលនេះក៏ដោយ ការកែលម្អ *សំណុំរឿងក្តីនេះ* ឲ្យមានបទដ្ឋាន “យុត្តិធម៌” មួយអាចទទួលយកបាននោះ មិនអាចធ្វើទៅបានទេ។ ការរំលោភបំពានទាំងនោះមានលក្ខណៈធ្ងន់ធ្ងរ និងរាលដាលយ៉ាងខ្លាំង។ វាមិនអាចទៅរួចទេដែលថាអង្គជំនុំជម្រះសាលាដំបូងអាច “ជួសជុល” ការរំលោភបំពានទាំងនោះ ដោយមិនចេញដីកាបង្គាប់ឲ្យបើកកិច្ចស៊ើបអង្កេតថ្មីមួយទាំងស្រុងនោះទេ ដែលលទ្ធផលនៃការស៊ើបអង្កេតថ្មីនេះមិនសមស្រប និងមិនយុត្តិធម៌ដោយសារតែវ័យ និងស្ថានភាពរាងកាយ/ផ្លូវចិត្តរបស់ជនជាប់ចោទ។ បញ្ហានៃការជ្រៀតជ្រែកនយោបាយ ការលម្អៀង និងវិការៈផ្នែកវិធីសាស្ត្រ ជាក់ស្តែង បានធ្វើឲ្យព្យសនកម្មបច្ចុប្បន្នមិនអាចនឹងជួសជុលបាន។

63. ដោយសារតែការស៊ើបអង្កេតមានវិការៈ សហមេធាវីមិនមានលទ្ធភាពក្នុងការត្រៀមលក្ខណៈឲ្យបានគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះឡើយ ហើយសហមេធាវីនឹងមិនមានលទ្ធភាពក្នុងការដាក់ជូនរាល់ទឡ្ហីករណ៍ពាក់ព័ន្ធទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះ ឬបើមិនដូច្នោះទេ មានឥទ្ធិពលពិតប្រាកដទៅលើលទ្ធផលនៃកិច្ចដំណើរការនីតិវិធីនោះដែរ។ ការរាំងស្ទះដោយសារ ក.ស.ច.ស នៅគ្រប់ពេល (និងការហាមមិនឲ្យបើកកិច្ចស៊ើបសួរដោយខ្លួនឯង) ពេលនេះសហមេធាវីអាចបង្ហាញជូនដល់អង្គជំនុំជម្រះនូវបញ្ជីឈ្មោះសាក្សី ដែលមានចំនួនច្រើនជាងបន្តិចនៃតម្រុយត្រូវស៊ើបអង្កេតដែលត្រូវបានបដិសេធកាលពីពេលមុន។ ដើម្បីតែកោះហៅតែបុគ្គលមួយចំនួនតូច ក្នុង

ចំណោមបុគ្គលទាំងអស់ ជំនួសឲ្យសហមេធាវី អង្គជំនុំជម្រះសាលាដំបូង នឹងត្រូវចំណាយពេលវេលា និងធនធានរូបវន្តលើសពីសមត្ថភាពបច្ចុប្បន្នរបស់ខ្លួនទៅទៀត[177]។

64. ទោះបីជា វាអាចដែលថា ភាពយុត្តិធម៌ជារួមនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអាចត្រូវបាន វាយតម្លៃដោយត្រឹមត្រូវនៅពេលជិតមានសវនាការ រឿងក្តីនេះបង្ហាញឲ្យឃើញនូវភាពស្មុគស្មាញ ដោយឡែកចំពោះចំណុចនេះ។ ជាដំបូង វាគឺជាការសន្និដ្ឋានមួយដែលថាអង្គជំនុំជម្រះនេះនឹងមិន អាចអនុវត្តនូវរាល់ (ឬសូម្បីតែមួយផ្នែកធំនៃ) ការស៊ើបអង្កេតកែតម្រូវចាំបាច់នានា។ លើសពីនេះ ទៀតសម្ពាធនៅក្រៅតុលាការពីសំណាក់ប្រទេសជាម្ចាស់ជំនួយ រួមទាំងការទាមទារពីសង្គមកម្ពុជា ច្បាស់ជាផ្តល់នូវផលប៉ះពាល់ចំពោះការវាយតម្លៃរបស់អង្គជំនុំជម្រះនេះទៅលើសំណើនានារបស់ សហមេធាវីឲ្យកោះហៅ និងសួរដេញដោលសាក្សី និងបង្ហាញ និងដេញដោលភស្តុតាងឯកសារ។ (ពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះគ្រាន់តែត្រូវពិនិត្យមើលតុលាការពិសេសនៅសេរ៉ាឡេអូន ដែលនៅទីនោះចៅក្រមបានរងសម្ពាធយ៉ាងខ្លាំងក្នុងការបញ្ចប់សវនាការរបស់ Charles Taylor នោះ)។ ការប៉ាន់ស្មានដោយមានការអភិរក្ស ដែលមិនរួមបញ្ចូលវិធានការការកែតម្រូវផងនោះ ដូចបានតវ៉ានៅទីនេះ ឃើញថាការកាត់សេចក្តីនេះយ៉ាងហោចណាស់ត្រូវចំណាយពេលពីរឆ្នាំ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ យោងលើចំនួនសាក្សីដែលបានស្នើដោយភាគី ការកំណត់បែបនេះ ហាក់បីដូចជាសុទិដ្ឋិនិយមជ្រុល ប្រសិនបើមិនរវើរវាយជ្រុលទេនោះ។ វាមិនដូចនឹងការស៊ើបអង្កេត តាមប្រព័ន្ធច្បាប់ស៊ីវិលក្នុងប្រទេស ដែលអង្គជំនុំជម្រះមានឱកាសសមស្របក្នុងការដោះស្រាយ នូវការរំលោភបំពានទៅលើការជំនុំជម្រះដោយយុត្តិធម៌ពីដំបូង អង្គជំនុំជម្រះនេះប្រឈមនឹងកិច្ចការលំបាកខ្លាំងជាច្រើន។

65. ដូច្នេះ ដោយសារ "ករណីជាច្រើននៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងមិនធម្មតាទៅលើសិទ្ធិរបស់ [ជនជាប់ចោទ] [...] មិនអាចនឹងជួសជុលបាន"[178] និងដោយសារដូចគ្នានេះដែរ ការរំលោភបំពានទាំងនោះ "រំលោភទៅនឹងយុត្តិធម៌របស់តុលាការ"[179] នោះការបញ្ឈប់បណ្តឹងអាជ្ញាគឺជាដំណោះស្រាយដោយយុត្តិធម៌ដែលអាចទៅរួចសម្រាប់រឿងក្តីនេះ។ ដើម្បីឲ្យមាន "តុល្យភាពត្រឹមត្រូវរវាង

---

[177] *ចំណាំ* កង្វះធនធានបែបនេះ មិនមែនជាកំហុសរបស់ មេធាវីការពារក្តីទេ ហើយអនុលោមតាមច្បាប់ពាក់ព័ន្ធ វាជាយុត្តិកម្មដែលមិនអាចទទួលយកបានសម្រាប់ការរំលោភសិទ្ធិទទួលបានសវនាការត្រឹមត្រូវ ពេញលេញ និងការស៊ើបអង្កេតទូលំទូលាយ របស់ នួន ជា. ដូច ECtHR, បានលើកឡើងថា 'រដ្ឋមានកាតព្វកិច្ចរៀបចំប្រព័ន្ធច្បាប់ដើម្បីធានាឲ្យបាន នូវ សវនាការយុត្តិធម៌, សូមមើល ECtHR App No 32271/04, *Poppe v The Netherlands*, 'Judgment', 24 March 2009, para 23.

[178] *សូមមើល* កថាខណ្ឌ ២៧, *ដូចកថាខណ្ឌខាងលើ*។

[179] *ដូចជើងទំព័រខាងលើ*។

សិទ្ធិជាមូលដ្ឋានរបស់ [ជនជាប់ចោទ] និងអត្ថប្រយោជន៍នានារបស់សហគមន៍ជាតិ និង អន្តរជាតិ ចំពោះការចោទប្រកាន់ [នាពេលបច្ចុប្បន្ន]"[180] ជាជម្រើសមួយផ្សេងទៀត អង្គជំនុំជម្រះ អាចពិចារណានូវលទ្ធភាពពន្យារកិច្ចដំណើរការនីតិវិធីបណ្តោះអាសន្នសិន។ ប៉ុន្តែ អង្គជំនុំជម្រះត្រូវ ត្រៀមលក្ខណៈ មានចេតនា និងជាក់ស្តែងអាចកែតម្រូវការរំលោភបំពានដូចបានរៀបរាប់ខាងលើ។ វិធានការផ្សេងៗទៀត "នឹងបង្ហាញឲ្យឃើញនូវការខាតបង់អត្ថប្រយោជន៍ទៅលើសុចរិតភាពរបស់តុលាការ"[181] រួមទាំងប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ នួន ជា ផងដែរ។

### ច. ការអនុម័ត និងវិសោធនកម្មលើវិធាននៅកិច្ចប្រជុំ 'ពេញអង្គ' អ.វ.ត.ក គឺផ្ទុយពីរដ្ឋធម្មនុញ្ញ និង *ហួសពីសមត្ថកិច្ច* (*Ultra Vires*)

66. វិធាន អះអាងថាមានអានុភាពច្បាប់ ទាក់ទិនទៅនឹងដំណើរការនីតិវិធី នៅចំពោះមុខតុលាការនេះ ហើយរហូតមកដល់ពេលនេះ ក.ស.ច.ស អ.ប.ជ និងអង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកវិធានទាំងនេះយ៉ាងដូច្នេះ។ ទោះបីជាយ៉ាងណាក៏ដោយ វិធានមិនត្រូវបានប្រកាសឲ្យប្រើ និងមិនត្រូវបានអនុម័តដោយរដ្ឋសភាជាតិឡើយ ប៉ុន្តែវិធានទាំងនេះគ្រាន់តែត្រូវបាន*ទទួលស្គាល់*ដោយអ្នកចូលរួមនានាក្នុងកិច្ចប្រជុំពេញអង្គ អ.វ.ត.ក ប៉ុណ្ណោះ ដែលជាការអនុវត្តមួយដោយគ្មានមូលដ្ឋានផ្នែកច្បាប់ទាល់តែសោះ និងដោយគ្មានការកំណត់ណាមួយឡើយចំពោះថាតើទិដ្ឋភាពនៃនីតិវិធីកម្ពុជាជាធរមានមួយណា ស្ថិតនៅក្នុងការអនុវត្តមាត្រា ១២(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក។ ដោយសារមាត្រា ៩០ នៃរដ្ឋធម្មនុញ្ញហាមឃាត់យ៉ាងច្បាស់ក្រឡែតមិនឲ្យមានការផ្ទេរអំណាចនីតិបញ្ញត្តិបែបនេះ វិធានទាំងនេះ ជាពិសេសពាក់ព័ន្ធនឹងវិធានដែលអ្នកធ្វើសេចក្តីព្រាងមានគោលបំណងបង្កើតនីតិវិធីច្របាច់បញ្ចូលគ្នាថ្មីមួយ គឺផ្ទុយពីរដ្ឋធម្មនុញ្ញ និងគ្មានអានុភាពគតិយុត្តិជាប់កាតព្វកិច្ចឡើយ ។

67. ទោះបីជាលិខិតុបករណ៍ជាមូលដ្ឋាន ពិតជាអនុញ្ញាតឲ្យមានការអនុវត្តផ្ទុយពីនីតិវិធីកម្ពុជា ជាធរមាននៅក្នុងករណីមួយចំនួនយ៉ាងណាក៏ដោយ ក៏ការអនុវត្តផ្ទុយបែបនេះត្រូវតែភ្ជាប់ជាមួយនូវការយោង*ជាក់លាក់*ទៅលើករណីលើកលែងមួយក្នុងចំណោមករណីលើកលែងផ្លូវច្បាប់នានា។ ទាក់ទិននឹងបញ្ហានេះ បទប្បញ្ញត្តិនីមួយៗនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បង្កើតអាណត្តិមួយដែលអាចយកមកអនុវត្តបានដោយអង្គភាពមួយរបស់ អ.វ.ត.ក ប៉ុណ្ណោះ។ ឧទាហរណ៍ អំណាចដែលមានចែងក្នុងមាត្រា ៣៣ថ្មី អាចត្រូវបានអនុវត្តផ្ទាល់មុខដោយអង្គជំនុំជម្រះសាលាដំបូង និងទាក់ទិនតែ

---

[180] *ដូចជើងទំព័រខាងលើ។*

[181] *ដូចជើងទំព័រខាងលើ។*

ទៅនឹងដំណើរការនីតិវិធីជំនុំជម្រះប៉ុណ្ណោះ។ ផ្ទុយទៅវិញ សមាជិករបស់អង្គជំនុំជម្រះសាលាដំបូង ពុំមានអំណាចដើម្បីតាក់តែង ឬអនុវត្តវិធានឡើយ ឧទាហរណ៍ ទាក់ទិនទៅនឹងដំណើរការរបស់ ក.ស.ច.ស។ ក្នុងន័យនេះ អង្គភាពមួយដែលមានមន្ត្រី អ.វ.ត.ក ជាច្រើនបំពេញភារកិច្ចក្នុងគោលបំណងរួម មិនអាចអនុវត្តឲ្យបានស្របច្បាប់នូវអំណាចពេញលេញបានឡើយ។ ប៉ុន្តែ អ្នកធ្វើសេចក្តីព្រាងវិធានមានគោលបំណងធ្វើដូច្នេះ ដែលសំដៅ នៅក្នុងលក្ខណៈទូទៅប៉ុណ្ណោះ ទៅលើភាពចាំបាច់ក្នុងការបង្កើត 'ប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯងដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក[182]'។

68. សន្មតថា (ដើម្បីជាប្រយោជន៍សម្រាប់ការលើកទឡ្ហីករណ៍) រដ្ឋសភាជាតិអាចផ្ទេរអំណាចក្នុងការតាក់តែងច្បាប់ស្របតាមរដ្ឋធម្មនុញ្ញ ទៅឲ្យអង្គភាពជាក់លាក់មួយរបស់មន្ត្រី អ.វ.ត.ក ក៏កាតព្វកិច្ចបែបនេះមិនដែលត្រូវបានអនុវត្តឡើយ។ កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពុំបានបញ្ជាក់អំពីទស្សនទាននៃ 'កិច្ចប្រជុំពេញអង្គ' ឬ 'វិធានផ្ទៃក្នុង' នោះទេ កុំថាឡើយដល់ទៅបានចែងនោះ។ ដូច្នេះ ការកោះប្រជុំក្រៅអំណាចតុលាការ ដើម្បីអនុម័តនីតិវិធីនានា ដែលមានចេតនាចងកាតព្វកិច្ចភាគីទៅនឹងដំណើរការនីតិវិធីទាំងនេះ គឺ *ហួសពីសមត្ថកិច្ច*។ មានការស្នើឡើងថា ប្រសិនមានសុពលភាព វិធានផ្ទៃក្នុង 'ស្រដៀងគ្នាទៅនឹងអនុក្រឹត្យ ឬបទប្បញ្ញត្តិ ហេតុដូច្នេះទើបមានឋានានុក្រមទាបជាងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងឋានានុក្រមនៃបទប្បញ្ញត្តិ'[183]។ ប៉ុន្តែ ពុំមានការបង្ហាញថា វិធានត្រូវបានប្រកាសឲ្យប្រើ ឬអនុម័តដោយអាជ្ញាធរតាក់តែងច្បាប់ណាមួយដែលត្រូវបានគេទទួលស្គាល់នៅក្នុងប្រទេសនេះឡើយ។ ដូច្នេះ វាពុំត្រឹមត្រូវឡើយ ក្នុងការលើកឡើងថា ទោះបីយ៉ាងណាក្តី វិធានគឺជាអង្គច្បាប់ដែលមានឋានានុក្រម 'ទាបជាង'[184]។

69. ប្រសិនបើវិធានពិសេសមួយពុំបញ្ជាក់ឡើងវិញនូវនីតិវិធីដែលកំពុងអនុវត្តជាធរមាន ឬពុំត្រូវបានធ្វើយុត្តិកម្មដោយមានការយោង*ជាក់លាក់*ទៅលើករណីលើកលែងមួយ ក្នុងចំណោមករណីលើកលែងតាមផ្លូវច្បាប់នានាដែលមានបញ្ជាក់ជូនខាងលើនោះទេ[185] វិធាននោះគឺជាមោឃៈភាព ដោយពុំ

---

182 សាលដីកាបដិសេធពាក្យសុំមោឃភាព កថាខណ្ឌ ១៤។

183 *សូមមើល* ឯកសារ D-55/I/9, ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨ 'សំណើរួមរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំការពិចារណាឡើងវិញលើការវាយតម្លៃរបស់អង្គបុរេជំនុំជម្រះលើឋានានុក្រមគតិយុត្តិនៃវិធានផ្ទៃក្នុង ក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ជំទាស់នឹងដីកាបដិសេធសំណើសុំមោឃភាព', ERN 00229453–00229466 កថាខណ្ឌ៣៤។

184 *ដូចដើងទំព័រខាងលើ* កថាខណ្ឌ៣៧។

185 ដូចដែលបានកត់សម្គាល់ខាងលើ ចៅក្រម អ.វ.ត.ក អាចអនុវត្តផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក្នុងករណីចាំបាច់ ប៉ុន្តែ ចៅក្រមមិនអាចបង្កើតច្បាប់ជាទូទៅបានឡើយ។

មានឋានៈអ្វីឡើយនៅក្នុងឋានានុក្រមច្បាប់កម្ពុជា និងពុំមានអានុភាពចងកាតព្វកិច្ចឡើយនៅក្នុងតុលាការនេះ។ ដោយសារគោលបំណងដ៏ច្បាស់លាស់នៃលិខិតុបករណ៍ជាមូលដ្ឋានគឺដើម្បីប្រើជាជំនួយបន្ថែម ជាជាងប្រើជំនួសនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះ ការអនុញ្ញាតឲ្យភាពងាយស្រួលមានសារៈសំខាន់ជាងការពិចារណាអំពីនីត្យានុកូលភាព នឹងធ្វើឲ្យប៉ះពាល់ (បន្ថែមទៀត) ដល់ភាពស្របច្បាប់របស់ អ.វ.ត.ក[186]។

## ឆ. ការអនុវត្តវិធានបន្តទៀត នឹងរំលោភលើសិទ្ធិរបស់ នួន ជា

70. ទោះបីជាការបង្កើតតុលាការពិសេសមួយ ដើម្បីជំនុំជម្រះក្តីលើប្រភេទពិសេសមួយនៃចុងចោទមានលក្ខណៈត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញយ៉ាងណាក៏ដោយ ក៏ការអនុម័តគំរូខុសគ្នាទាំងស្រុងនៃនីតិវិធីដែលមានស្រាប់នៅក្នុងលក្ខណៈដែលបានពិពណ៌នាខាងលើ បង្កឲ្យមានបញ្ហា។ ទោះបីជាវិធានបញ្ជាក់ថាគ្រាន់តែ 'ច្របាច់បញ្ចូលគ្នានូវនីតិវិធីកម្ពុជាដែលមានស្រាប់សម្រាប់ដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក យ៉ាងណាក៏ដោយ'[187] ក៏តាមពិតវិធានទាំងនោះអនុវត្តហួសពីការបង្រួម ឬការដាក់បញ្ចូលនីតិវិធីដែលមានស្រាប់ឲ្យទៅជាឯកសារតែមួយ។ ដូច្នេះ នួន ជា ត្រូវបានដកហូតនូវសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តី អនុលោមតាមច្បាប់កម្ពុជា ដូចដែលមានចែងនៅក្នុងមាត្រា ១២(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក។ ដោយសារតែនីតិវិធីព្រហ្មទណ្ឌកម្ពុជាតំណាងឲ្យប្រព័ន្ធច្បាប់ដែលគាត់បានយល់ដឹង ការពុំអនុវត្តនីតិវិធីនេះដោយគ្មានការបង្ហាញហេតុផលជាក់លាក់ និងការបង្ហាញឲ្យឃើញនូវបទដ្ឋានមិនច្បាស់លាស់ និងតាមទំនើងចិត្ត *ហួសពីសមត្ថកិច្ច* គឺផ្ទុយទៅនឹងការផ្តល់សិទ្ធិឲ្យគាត់ក្នុងការទទួលបាននូវសច្ចភាពផ្លូវច្បាប់ និងភាពអាចដឹងជាមុនបាន។ ដូច្នេះ វិធាន ត្រូវតែត្រូវបានពិនិត្យពិច័យ ដើម្បីឲ្យស្របតាមនីតិវិធី ដែល

---

186 Sluiter ២០០៦, ៣១៤-៣២៦, ទំព័រ 319–320 ('បុគ្គលិកអន្តរជាតិរបស់ [អ.វ.ត.ក] ជាពិសេស អាចប្រាថ្នា ចង់បានវិធាននានាដែលមានលក្ខណៈអន្តរជាតិ ដែលត្រូវបានផ្តួចផ្តើមដោយវិធានរបស់តុលាការ ICC និង/ឬ តុលាការ ICTY ដោយ ផ្អែកលើគោលជំហរថា ស្ថានភាពទាំងមូល ទាក់ទិននឹងច្បាប់ជាតិជាធរមាន គឺមានលក្ខណៈមិនច្បាស់លាស់។ ប្រការនេះផ្ទុយ យ៉ាងច្បាស់ក្រឡែតទៅនឹងគោលបំណងរបស់អ្នកធ្វើសេចក្តីព្រាងក្នុងការអនុវត្ត ដំណើរការនីតិវិធីអនុលោមតាមច្បាប់កម្ពុជា')។

187 វិធាន, បុព្វកថា។ *កំណត់សម្គាល់ពិសេស។* យោងតាមវចនានុក្រម Random House Unabridged Dictionary (www.dictionary.com), ពាក្យ consolidate មានន័យថា៖ (i) 'ច្របាច់បញ្ចូល (ផ្នែកផ្សេងគ្នា) ឲ្យទៅជាផ្នែកតែមួយ ឬផ្នែកទាំងមូលរួមបញ្ចូលគ្នា។ បង្រួមបញ្ចូលគ្នា។ ដាក់បញ្ចូលគ្នា'។ (ii) 'បោះចោលអ្វីៗដែលមិនប្រើ ឬមិនត្រូវការ និងរៀបចំផ្នែកដែលនៅសល់'។ ឬ (iii) 'ធ្វើឲ្យរឹងមាំ ឬរឹងប៉ឹង។ ធ្វើឲ្យរឹងមាំឡើង។ ពង្រឹង'។

មានស្រាប់ជាធរមាន ហើយការអនុវត្តផ្ទុយណាមួយ ត្រូវតែធ្វើយុត្តិកម្មឱ្យបានត្រឹមត្រូវ ដូចដែល លិខិតុបករណ៍បានតម្រូវឱ្យមាន[188]។

71. ជាទូទៅ មេធាវីការពារក្តី ពុំជំទាស់ទៅនឹងការអនុវត្តផ្ទុយនឹងច្បាប់កម្ពុជាដែលមានស្រាប់ ជាក់លាក់ឡើយ ក្នុងវិសាលភាពដែលការអនុវត្តផ្ទុយនេះមានមូលដ្ឋាននៅក្នុងពាក្យពេចន៍ដ៏ច្បាស់លាស់ នៃមាត្រា ១២(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តី ជាពិសេស ជំទាស់ទៅនឹងវិធានទាំងឡាយដែលមិនអាចបំពេញនូវលក្ខខណ្ឌនៃមាត្រា ១២(១) ពីព្រោះ ៖ (i) ច្បាប់កម្ពុជា*ពិតជា*អាចដោះស្រាយបានចំពោះករណីពិសេសមួយ (ii) *ពុំ*មានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬ (iii) *ពុំ*មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិ បែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិឡើយ។ វិធានបែបនេះពុំមានមូលដ្ឋានក្នុងច្បាប់ឡើយ ហើយ សម្រាប់តែហេតុផលនេះប៉ុណ្ណោះ គឺ*ហួសពីសមត្ថកិច្ច*[189]។

## ជ. ដីកាបង្គាប់ឱ្យរៀបចំត្រូវតែទុកជាមោឃៈ ដោយសារតែដីកានេះត្រូវបានចេញ អនុលោមតាមវិធានដែល *ហួសពីសមត្ថកិច្ច*

72. សំណើសុំនេះពុំមានចេតនាលើកឡើងនូវបញ្ហាផ្នែកទ្រឹស្តីឡើយ។ ផ្ទុយទៅវិញ នួន ជា ទទួលរង ព្យសនកម្មដោយផ្ទាល់ និងជាក់ស្តែង ពីការអនុវត្តវិធានទាំងឡាយដែលយកមកធ្វើជាសំអាងដោយ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងដីកាបង្គាប់ឱ្យរៀបចំ ៖ ជាពិសេស វិធាន ២៣, ២៤, ២៩, ៣១, ៧៩, ៨០ និង ៨០*ស្ទួន*, ៨៤, ៨៥, ៨៧, ៨៩ និង ៩១*ស្ទួន*។ ក្នុងវិសាលភាពដែលបទប្បញ្ញត្តិ *ហួសពីសមត្ថកិច្ច*ទាំងនេះ បានដាក់កាតព្វកិច្ចមួយចំនួនដែលធ្វើឱ្យខូចប្រយោជន៍មកលើជនជាប់ចោទ ការប្រតិបត្តិតាមពាក្យពេចន៍នៃបទប្បញ្ញត្តិទាំងនេះ បង្កើតបានជាបញ្ហានីត្យានុកូលភាពដ៏ មានសារៈសំខាន់ និងពិតប្រាកដ។

---

188 គួរកត់សម្គាល់ថា មេធាវីការពារក្តី ផ្តោតយ៉ាងច្រើនលើ នីត្យានុកូលភាពនៃវិធានដែលទាក់ទងនឹងនីតិវិធីសវនាការ និងមិនមានបំណងដកសំណើទាំងនេះដើម្បីឱ្យមានប្រតិសកម្មនោះទេ។ អាស្រ័យហេតុនេះ ដើម្បីជួយពន្លឿនតុលាការ មេធាវីការពារក្តីរៀបចំ ដើម្បីទទួលសុពលភាពនៃការគ្រប់គ្រង និងនីតិវិធីមុនសវនាការ ទោះបីជាវាបានផ្អែកលើវិធានដែលផ្ទុយគ្នានឹងក្រមព្រហ្មទណ្ឌកម្ពុជាក៏ដោយ និងដែលមានក្នុងមាត្រាទី ១២(១) នៃកិច្ចព្រមព្រៀង។

189 កំណត់សម្គាល់។ តារាងរៀបរាប់អំពីឧទាហរណ៍មួយចំនួន ដែលវិធាននីមួយៗបង្ហាញនូវការអនុវត្តមិនត្រឹមត្រូវ តាមច្បាប់នៃមាត្រា ១២(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក។ ដោយសារតែមេធាវីការពារក្តីបានធ្វើការវិភាគបឋមនេះ ក្រោមការកំណត់ពេលវេលា ដូច្នេះមេធាវីការពារក្តីសូមរក្សាសិទ្ធិក្នុងការដាក់អញ្ញត្រកម្មបន្ថែម (នៅគ្រប់ពេល) ទៅនឹងវិធានទាំងនេះ និងវិធានដទៃទៀត នៅពេលដែលមានការមើលឃើញនូវការងាកចេញពីនីតិវិធីកម្ពុជាជាធរមានដោយគ្មានមូលដ្ឋានផ្អែកច្បាប់។

ដូច្នេះ និងដូចដែលមានការគាំទ្រដោយការវិភាគ ដែលមាននៅក្នុងឧបសម្ព័ន្ធ ក ដីកាបង្គាប់ឲ្យរៀបចំ និងកាលបរិច្ឆេទដែលកំណត់នៅក្នុងនោះ ត្រូវទុកជា មោឃៈ។ ក្នុងរយៈពេលរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះលើអញ្ញត្រកម្មនេះ អានុភាព នៃដីកាបង្គាប់ឲ្យរៀបចំ គួរតែត្រូវបានផ្អាក។ លើសពីនេះទៀត ដីកាបង្គាប់ក្រោយៗទៀត ទាក់ទិន នឹងការរៀបចំសវនាការ គួរតែត្រូវបានផ្តល់ នូវមូលដ្ឋានឲ្យបានត្រឹមត្រូវនៅក្នុងមាត្រា ១២(១) នៃ កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងកំណត់រយៈពេលឲ្យអនុវត្ត ស្របជាមួយនឹងច្បាប់ កម្ពុជាជាធរមាន[190]។

## VI. សេចក្តីសន្និដ្ឋាន

73. ដោយមានសំអាងហេតុខាងលើ សហមេធាវីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយកអញ្ញត្រកម្មទាំងនេះ ហើយចេញដីកាបង្គាប់ទៅតាមសំណូមពរចំពោះអញ្ញត្រកម្មនីមួយៗដែលមានគោលបំណងខុសៗគ្នាខាងក្រោមនេះ៖

ក. <u>អនុលោមតាមវិធាន៨៩(១)(ក)</u>៖ ស្នើឲ្យដោះលែង នួន ជា ជាបន្ទាន់ពីការឃុំខ្លួនបណ្តោះអាសន្នរបស់អង្គជំនុំជម្រះ ដោយសារមិនមានមូលដ្ឋានច្បាប់សម្រាប់ការជំនុំជម្រះ នួន ជា នៅចំពោះមុខអង្គជំនុំជម្រះនេះឡើយ[191]

ខ. <u>អនុលោមតាមវិធាន៨៩(១)(ខ)</u>៖ ស្នើឲ្យចេញដីកាបង្គាប់ឲ្យរំលត់បណ្តឹងអាជ្ញា ឬ ជាជម្រើសមួយផ្សេងទៀត ពន្យារដំណើរការនីតិវិធីទៅលើ នួន ជា[192] និង/ឬ

គ. <u>អនុលោមតាមវិធាន៨៩(១)(គ)</u>៖ ស្នើឲ្យប្រកាសមោឃភាពលើវិធានទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងការជំនុំជម្រះ និងកិច្ចដំណើរការនីតិវិធីជាបន្តបន្ទាប់។ ជាជម្រើសមួយផ្សេងទៀត ត្រូវលើកឡើងនូវ (ដោយយោងមាត្រា១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ឲ្យបានច្បាស់លាស់ និងជាក់លាក់) មូលដ្ឋានផ្សេងៗដែលយកមកធ្វើយុត្តិកម្មទៅលើការប្រាសចាកពីនីតិវិធី

---

[190] *កំណត់សម្គាល់ពិសេស៖* មេធាវីការពារក្តីដឹងយ៉ាងច្បាស់ថា ផ្អែកលើបញ្ហាជាសារវ័ន្តនៃការសម្រេចចិត្ត និងការអនុវត្តប្រភពច្បាប់ អង្គជំនុំជម្រះសាលាដំបូងនឹងដើរតួនាទីជា *អ្នកសម្រេចសេចក្តីលើរឿងក្តីរបស់ខ្លួន (iudex in sua causa)*។ បើតាមទ្រឹស្តីនៃការបែងចែកអំណាចវិញ លទ្ធផលបែបនេះមិនអាចទទួលយកបានទាល់តែសោះ។ ពេលនេះគេត្រូវកោះហៅចៅក្រម(ក្នុងចំណោមអ្នកដទៃទៀត) ដែលទទួលខុសត្រូវក្នុងការអនុម័តវិធាន និងចៅក្រមដែលរំលោភកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ឲ្យមកវាយតម្លៃពីនីត្យានុកូលភាពនៃដំណើរការនេះនឹងជួបប្រទះនូវបញ្ហាជាខ្លាំង។ អាស្រ័យហេតុនេះ មេធាវីការពារក្តីនឹងជ្រើសរើសដើរលើវិថីផ្សេងទៀតនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ដើម្បីនាំយកបញ្ហានេះដាក់ជូនស្ថាប័នដែលមានលក្ខណៈមិនលម្អៀងពិតប្រាកដដើម្បីសម្រេចសេចក្តី។

[191] *សូមមើល* កថាខណ្ឌ ៤១-៥៦ *ខាងលើ សូមមើលផងដែរ* ករណីអញ្ញត្រកម្មលើយុត្តាធិការ។

[192] *សូមមើល* កថាខណ្ឌ ៥៧-៦៥ *ខាងលើ សូមមើលផងដែរ* ករណីអញ្ញត្រកម្មលើសវនាការដោយយុត្តិធម៌។

កម្ពុជាជាធរមាន ហើយប្រកាសមោឃភាពលើដីកាបង្គាប់ឲ្យរៀបចំ និងពន្យារប្រសិទ្ធភាព របស់ដីកានោះ រហូតដល់មានសេចក្តីសម្រេចដាក់ចេញស្តីពីអញ្ញត្រកម្មនេះ[193]។

ដូចបានកត់សម្គាល់រួចមកហើយពីខាងដើម[194] សហមេធាវីសូមរក្សាសិទ្ធិក្នុងការដាក់សារណាបន្ថែម នៅពេលសវនាការបឋម ព្រមទាំងរក្សាសិទ្ធិក្នុងការដាក់ជូនសារណាជាលាយលក្ខណ៍អក្សរបន្ថែម ចាំបាច់នានាជាមុន ដើម្បីជាប្រយោជន៍ដល់យុត្តិធម៌។

សហមេធាវីការពារក្តី នួន ជា

**សុន អរុណ** Michiel PESTMAN & Victor KOPPE

193 *សូមមើល* កថាខណ្ឌ ៦៦-៧៣ *ខាងលើ សូមមើលផងដែរ* ករណីអញ្ញត្រកម្មលើវិធានផ្ទៃក្នុង។

194 *សូមមើល* កថាខណ្ឌ ៣៩-៤០ *ខាងលើ*។